ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# របាយការណ៍

## ស្តីពី

## សកម្មភាពការងារសំខាន់ៗ ប្រចាំត្រីមាសទី២ ឆ្នាំ២០១៩

អគ្គលេខាធិការដ្ឋាន ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

# សេចក្តីផ្តើម

ក្រោមឧត្តមគតិដឹកនាំប្រាកដនិយមប្រកបដោយគតិបណ្ឌិតរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា, រាជរដ្ឋាភិបាលកម្ពុជាបានអនុវត្តប្រកបដោយជោគជ័យជាផ្លែផ្កា នូវយុទ្ធសាស្ត្រ ចតុកោណ ចំនួន ៣ ដំណាក់កាលរួចមកហើយ ព្រមទាំងបានបន្តដាក់ឱ្យអនុវត្តនូវយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ ដើម្បីបន្តពង្រឹង និងពង្រីកសមិទ្ធផលនានា ដែលរដ្ឋាភិបាលសម្រេចបានក្នុងនីតិកាលទី៥ កន្លងមក ឱ្យកាន់តែមានវឌ្ឍនភាពលើគ្រប់វិស័យបន្ថែមទៀតប្រកបដោយចីរភាព។ ក្នុងរយៈពេលជាងពីរទសវត្សន៍ចុងក្រោយនេះ កម្ពុជាបានរក្សានូវកំណើនសេដ្ឋកិច្ចខ្ពស់ និងជាប្រទេសដែលសម្រេចបាននូវជោគជ័យដ៏ល្អប្រសើរលើការផ្លាស់ប្តូរស៊ីជម្រៅរចនាសម្ព័ន្ធសេដ្ឋកិច្ច និងការលើកកម្ពស់ជីវភាពប្រជាជនឱ្យកាន់តែប្រសើរឡើងទាំងផ្នែកសម្ភារ និងស្មារតី តាមរយៈការបែងចែកកំណើនសេដ្ឋកិច្ចប្រកបដោយបរិយាប័ន្ន, ការបង្កើតការងារជូនប្រជាជនដោយការទាក់ទាញវិនិយោគិនទាំងជាតិ និងអន្តរជាតិ មកវិនិយោគលើវិស័យអាទិភាពសំខាន់ៗក្នុងប្រទេស, ការធានាបាននូវសមធម៌សង្គម, ការផ្ទេរអំណាច និងស្វ័យភាពកាន់តែច្រើនដល់រដ្ឋបាលថ្នាក់ក្រោមជាតិ និងការពង្រឹងប្រសិទ្ធភាព នៃអភិបាលកិច្ចរបស់ស្ថាប័នរដ្ឋ ដែលបានធ្វើគំលាតជីវភាពរវាងអ្នកមាននិងអ្នកក្រកាន់តែខិតជិតគ្នាគួរឱ្យកត់សម្គាល់។ លើសពីនេះទៅទៀត កម្ពុជាបានប្រែក្លាយឋានៈពីប្រទេសដែលមានចំណូលទាប មកជាប្រទេសដែលមានចំណូលមធ្យមកម្រិតទាបកាលពីពេលថ្មីៗកន្លងទៅ ហើយរាជរដ្ឋាភិបាលកម្ពុជាក៏បានបន្តដាក់ចេញនូវចក្ខុវិស័យជាតិ ដែលមានឆន្ទៈមោះមុតប្រែក្លាយប្រទេសកម្ពុជាឱ្យទៅជាប្រទេសដែលមានចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ ២០៣០ និងឈានក្លាយទៅជាប្រទេសដែលមានចំណូលខ្ពស់នៅឆ្នាំ ២០៥០ ខាងមុខនេះ។

តាមរយៈនេះ ដើម្បីសម្រេចឱ្យខានតែបាននូវគោលដៅខាងលើនេះ តាមរយៈការបង្កើតជាយន្តការតាមដានឱ្យបានជាប់លាប់ និងគ្រប់ជ្រុងជ្រោយ, រាជរដ្ឋាភិបាលកម្ពុជាបាននិងកំពុងបន្តធ្វើការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃយ៉ាងច្បាស់លាស់លើការអនុវត្តមុខងារភារកិច្ចរបស់ក្រសួង-ស្ថាប័ននីមួយៗ សំដៅបង្កើន និងរក្សាឱ្យបាននូវប្រសិទ្ធភាព និងស័ក្តិសិទ្ធិភាពនៃការអនុវត្តកិច្ចការងារដោយបានតម្រូវឱ្យមានរបបរាយការណ៍ជាផ្លូវការអំពីវឌ្ឍនភាពនៃការអនុវត្តការងាររបស់អង្គភាពខ្លួនជា**ប្រចាំខែ ត្រីមាស ឆមាស ៩ខែ និងប្រចាំឆ្នាំ** ដើម្បីរាជរដ្ឋាភិបាលមានមូលដ្ឋានពិនិត្យបូកសរុប តាមដាន និងវាយតម្លៃសមិទ្ធកម្មការងារ នៃការអនុវត្តគោលបំណងគោលនយោបាយរបស់គ្រប់ក្រសួង-ស្ថាប័ន ដែលរាជរដ្ឋាភិបាលបានដាក់ចេញឱ្យអនុវត្ត ប្រកបដោយប្រសិទ្ធភាព និងផលិតភាពខ្ពស់ ព្រមទាំងអាចទទួលបាននូវព័ត៌មានគ្រប់ជ្រុងជ្រោយសម្រាប់ចាត់វិធានការដោះស្រាយ និងចាត់ចែងរៀបចំផែនការជាបន្តបានទាន់ពេលវេលា។ ក្នុងន័យនេះ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក៏មិនខុសគ្នាពីក្រសួង-ស្ថាប័នដទៃ គឺត្រូវមានកាតព្វកិច្ចរាយការណ៍ពីវឌ្ឍនភាពនៃការអនុវត្តគោលបំណងគោលនយោបាយចំនួនពីររបស់ខ្លួនដែលរាជរដ្ឋាភិបាលបានប្រគល់ជូន គឺគោលនយោបាយគ្រប់គ្រងសេដ្ឋកិច្ច និងអភិវឌ្ឍវិស័យហិរញ្ញវត្ថុ និងគោលនយោបាយគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងទ្រព្យសម្បត្តិរដ្ឋ អមដោយកម្មវិធីចំនួនប្រាំ ជូនដល់រាជរដ្ឋាភិបាលជាប្រចាំផងដែរ។ ជាក់ស្តែង ចាប់ពីឆ្នាំ ២០១៤ មក, ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ តែងតែបានរៀបចំរបាយការណ៍សកម្មភាពការងាររបស់ខ្លួន និងបានបញ្ជូនទៅទីស្តីការគណៈរដ្ឋមន្ត្រីយ៉ាងទៀងទាត់ ក្នុងគោលបំណងបង្កើនគុណភាព និងប្រសិទ្ធភាព នៃការអនុវត្តការងាររបស់គ្រប់អង្គភាពក្រោមក្រសួង ដើម្បីសម្រេចឱ្យបានតាមសូចនាករ សកម្មភាពចង្កោមសកម្មភាព និងអនុកម្មវិធីរបស់គ្រប់អង្គភាពសាមី។

របាយការណ៍សកម្មភាពការងារប្រចាំឆមាសទី១ ឆ្នាំ២០១៩ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ នាពេលនេះ ត្រូវបានរៀបចំឡើងតាមរយៈការប្រមូលធាតុចូលពីរបាយការណ៍សកម្មភាពការងារ នៃគ្រប់អង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដែលជាតួអង្គអនុវត្តផ្ទាល់ យកមកពិនិត្យចងក្រង និងធ្វើអាទិភាវូបនីយកម្មសម្រួចសកម្មភាពធំៗ ដោយទាញយកចំណុចសំខាន់ៗបញ្ចូលទៅ

ក្នុងកម្មវិធី និងអនុកម្មវិធី ជាសមត្ថកិច្ចរបស់អង្គភាពជំនាញស្របតាមគោលបំណងគោលនយោបាយរបស់ក្រសួង នឹងបង្ហាញអំពីសមិទ្ធផលការងារសំខាន់ៗ ដែលអង្គភាពនីមួយៗបានខិតខំសម្រេចបាននារយៈពេល ៦ ខែ ដើមឆ្នាំ ២០១៩ នេះ ព្រមទាំងរំលេចអំពីសូចនាករដែលមិនទាន់សម្រេចបានដើម្បីជាមូលដ្ឋានពិនិត្យ តាមដាន វាយតម្លៃ និងពង្រឹងការអនុវត្តបន្តឱ្យកាន់តែមានគុណភាពបន្ថែមទៀត។ ខ្លឹមសារក្នុងផ្នែកនីមួយៗនៃរបាយការណ៍នេះ ត្រូវបានរៀបចំពណ៌នាជាចំណុចគន្លឹះៗ ដែលអង្គភាពសម្រេចបាន ទាំងការងារប្រចាំថ្ងៃ និងការងារកែទម្រង់ ក្នុងគោលដៅធ្វើយ៉ាងណាប្រមូលផ្តុំព័ត៌មានឱ្យបានពេញលេញ គ្រប់ជ្រុងជ្រោយ និងមានសារប្រយោជន៍ពីគ្រប់ផ្នែកគាំទ្រទាំងអស់របស់ក្រសួង សំដៅបំពេញមុខងារជាសេនាធិការរបស់រាជរដ្ឋាភិបាល លើបេសកកម្មដឹកនាំ និងគ្រប់គ្រងវិស័យសេដ្ឋកិច្ចនិងហិរញ្ញវត្ថុនៅកម្ពុជាឱ្យកាន់តែមានប្រសិទ្ធភាព និងស័ក្តិសិទ្ធិភាព ព្រមទាំងដើម្បីសម្រេចឱ្យបានជោគជ័យជាផ្លែផ្កាតាមគោលការណ៍សមធមិសង្គមប្រកបដោយបរិយាប័ន្ន និងចីរភាពតរៀងទៅ។

## ១. គោលនយោបាយគ្រប់គ្រងសេដ្ឋកិច្ច និងអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ

ស្របតាមផែនការយុទ្ធសាស្ត្រថវិកា២០១៨-២០២០ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ, គោលបំណងគោលនយោបាយទី១. "ពង្រឹង និងបង្កើនប្រសិទ្ធភាពនៃការគ្រប់គ្រងសេដ្ឋកិច្ចនិងការអភិវឌ្ឍវិស័យហិរញ្ញវត្ថុ" មានកម្មវិធីចំនួន០២ ត្រូវបានដាក់ឱ្យអនុវត្ត ដើម្បីឈានទៅសម្រេចគោលបំណងគោលនយោបាយនេះ។

### ១.១. ការគ្រប់គ្រងសេដ្ឋកិច្ច[1]

ផ្នែកនេះ ត្រូវបានអនុវត្តដោយអគ្គនាយកដ្ឋានគោលនយោបាយ និងលេខាធិការដ្ឋានគណៈកម្មការផលិតភាព។ អគ្គនាយកដ្ឋានគោលនយោបាយ ដែលមានមុខងារសំខាន់ៗ ក្នុងការរៀបចំ និងតាមដានការអនុវត្តគោលនយោបាយ និងយុទ្ធសាស្ត្រពាក់ព័ន្ធវិស័យសេដ្ឋកិច្ច និងហិរញ្ញវត្ថុ, តាមដាន និងវាយតម្លៃនិន្នាការសេដ្ឋកិច្ចជាតិ តំបន់ និងពិភពលោក ក្នុងកម្រិតវិស័យធំៗ ស្ទួចនាករម៉ាក្រូសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងចូលរួមចំណែកក្នុងការងារពាក់ព័ន្ធដល់ការរៀបចំគោលនយោបាយ ពាណិជ្ជកម្ម និងហិរញ្ញវត្ថុក្រៅប្រទេស និងកិច្ចសហប្រតិបត្តិការក្នុងវិស័យហិរញ្ញវត្ថុ ក្នុងតំបន់ និងពិភពលោក[1]។ រីឯលេខាធិការដ្ឋានគណៈកម្មការផលិតភាពកម្ពុជាផ្តោតលើកិច្ចការរដ្ឋបាល និងការងារបច្ចេកទេសសិក្សាស្រាវជ្រាវ សម្រាប់គាំទ្រកិច្ចដំណើការរបស់គណៈកម្មការផលិតភាពកម្ពុជា។ ជាលទ្ធផលក្នុងឆមាសទី១ ឆ្នាំ២០១៩ អគ្គនាយកដ្ឋានគោលនយោបាយ និងលេខាធិការដ្ឋានគណៈកម្មការផលិតភាព បានអនុវត្ត និងទទួលបានវឌ្ឍនភាពដូចមានក្នុងរបាយការណ៍ខាងក្រោម÷

#### ១.១.១. ការគ្រប់គ្រងសេដ្ឋកិច្ច តាមរយៈការសិក្សា ស្រាវជ្រាវ និងផ្តល់មតិយោបល់

- បានផ្តល់មតិយោបល់លើ÷
    - o ការវាយតម្លៃការអនុវត្តយុទ្ធសាស្ត្រកែទម្រង់ប្រព័ន្ធថវិកាឆ្នាំ២០១៨-២០២៥ និងការវាយតម្លៃការអនុវត្តយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី ៤ របស់រាជរដ្ឋាភិបាល
    - o ការធ្វើបច្ចុប្បន្នភាពយុទ្ធសាស្ត្រសមាហរណកម្មពាណិជ្ជកម្មកម្ពុជា ២០១៩–២០២៣
    - o សេចក្តីព្រាងរបាយការណ៍របស់ធនាគារពិភពលោក ស្តីពី "Cambodia Future Job"
    - o ច្បាប់ស្តីពីការប្រកួតប្រជែងនិង ច្បាប់ស្តីពីកិច្ចការពារអ្នកប្រើប្រាស់
    - o ឯកសារផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ២០១៩-២០២៣
    - o របាយការណ៍ "ASEAN+3 Regional Economic Outlook (AREO) 2019" របស់ AMRO
    - o ឯកសារ "Cambodia's Voluntary National Review 2019 on the Implementation of the 2030 Agenda For Sustainable Development"
    - o របាយការណ៍សិក្សាស្តីពី "ផែនការមេដឹកជញ្ជូនពហុបំណង
- បានរៀបចំ÷
    - o ឯកសារទស្សនទានស្តីពី "ការសិក្សាលើការលើកទឹកចិត្តផ្នែកពន្ធសម្រាប់វិស័យផលិតនិងតំឡើងយានយន្ត"

[1] មាត្រា ១៤ថ្មី នៃអនុក្រឹត្យលេខ៧៥ អនក្រ.បក ចុះថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០១៧ ស្តីពីការកែសម្រួលអនុក្រឹត្យលេខ៤៨៨ ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

- o សម្របសម្រួលជាមួយវិស័យឯកជនក្នុងការរៀបចំសិក្ខាសាលាផ្សព្វផ្សាយ និងរបាយការណ៍ស្តីពី “អនុក្រឹត្យ ស្តីពីការលើកទឹកចិត្តផ្នែកពន្ធដារសម្រាប់សហគ្រាស ធុនតូច និងមធ្យម ក្នុងវិស័យអាទិភាព
  - o សេចក្តីសម្រេចតែងតាំងសមាសភាពក្រុមប្រឹក្សាបរធនបាលមូលនិធិអភិវឌ្ឍន៍សហគ្រិនភាព
  - o ត្រួតពិនិត្យចំណាយ និងរបាយការណ៍ហិរញ្ញវត្ថុរបស់គម្រោងសាកល្បងយន្តការគ្រប់គ្រងមូលនិធិជាតិអភិវឌ្ឍន៍ជំនាញ
  - o ទិន្នន័យព្យាករសេដ្ឋកិច្ចរយៈពេលខ្លី និងមធ្យម សម្រាប់មូលនិធិរូបិយវត្ថុអន្តរជាតិ
  - o ឯកសារទស្សនទាន និងចំណុចសំខាន់ៗស្តីពី “គំនិតផ្តួចផ្តើមខ្សែក្រវ៉ាត់ និងផ្លូវ (BRI)” នៅប្រទេសចិន
  - o ពិនិត្យរបាយការណ៍ហិរញ្ញវត្ថុសម្រាប់គម្រោងសាកល្បងយន្តការគ្រប់គ្រងមូលនិធិជាតិអភិវឌ្ឍន៍ជំនាញ
  - o របាយការណ៍វាយតម្លៃយុទ្ធសាស្ត្រកៀរគរចំណូលរយៈពេលមធ្យម ២០១៤-២០១៨
  - o ធ្វើការកែសម្រួលនិងបញ្ចប់ឯកសារទស្សនទានស្តីពី “ពិពិធកម្មនៃវិស័យទេសចរណ៍នៅក្នុងប្រទេសកម្ពុជា” ដែលផ្តោតលើបញ្ហាប្រឈម ឱកាស , និងទិសដៅគោលនយោបាយ
  - o ឯកសារទស្សនទានលើប្រធានបទ ការទាញសក្តានុពលនៃវិស័យកសិឧស្សាហកម្មរបស់កម្ពុជា
  - o ពិនិត្យរបាយការណ៍ និងឯកសារហិរញ្ញវត្ថុ នៃគម្រោងសាកល្បងយន្តការគ្រប់គ្រងមូលនិធិជាតិអភិវឌ្ឍន៍ ជំនាញ
  - o ផ្តល់ធាតុចូលលើផ្នែក ការវិភាគ និងវាយតម្លៃការអនុវត្តចំណូល ចំណាយថវិកា និងស្ថានភាពម៉ាក្រូសេដ្ឋកិច្ច ឆ្នាំ២០១៨ សម្រាប់រៀបចំច្បាប់ស្តីពី “ការទូទាត់ថវិកាទូទៅរបស់រដ្ឋសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៨”
  - o ផ្គូផ្គងសូចនាករស្នូល សម្រាប់តាមដាន ត្រួតពិនិត្យ និងវាយតម្លៃ រវាងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ និងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ២០១៩ - ២០២៣
  - o ប្រមូលទិន្នន័យពីក្រសួងស្ថាប័នពាក់ព័ន្ធដើម្បីធ្វើបច្ចុប្បន្នភាពរបាយការណ៍ Doing Business សម្រាប់ធនាគារពិភពលោក
- បានសិក្សាស្រាវជ្រាវ
  - o យុទ្ធសាស្ត្រវិស័យកាត់ដេរនៅកម្ពុជា និងការវាយតម្លៃទីផ្សារអចលនទ្រព្យនៅក្នុងប្រទេសកម្ពុជា” និងវិស័យអចលនទ្រព្យរបស់ប្រទេសចិន និងប្រទេសផ្សេងៗ
  - o យន្តការលើកទឹកចិត្តផ្នែកពន្ធ ដើម្បីលើកកម្ពស់វិស័យដំឡើងរថយន្តនៅកម្ពុជា ដោយធ្វើការចុះសិក្សាពីក្រុមហ៊ុន DAEHAN Auto Group និងក្រុមហ៊ុន Camko Motor ព្រមទាំងក្រុមហ៊ុនដំឡើងម៉ូតូ Suzuki និង Honda
  - o ផលប៉ះពាល់នៃការដក EBA មកលើសេដ្ឋកិច្ចប្រទេសកម្ពុជា, ការវិនិយោគរបស់ប្រទេសជប៉ុនមកកាន់កម្ពុជា ព្រមទាំងរបបអនុគ្រោះពន្ធសម្រាប់ការវិនិយោគនៅក្នុងប្រទេសកម្ពុជា
  - o ថ្លៃអគ្គិសនីក្នុងច្រវាក់ផ្គត់ផ្គង់វិស័យស្រូវអង្ករ និងយន្តការនៃយុទ្ធសាស្ត្រកាត់បន្ថយថ្លៃអគ្គិសនីសម្រាប់ការអភិវឌ្ឍវិស័យឧស្សាហកម្ម
  - o ហានិភ័យហិរញ្ញវត្ថុសាធារណៈ, ហានិភ័យនៃទីផ្សារអចលនទ្រព្យក្នុងប្រទេសកម្ពុជា និងពន្ធអចលនទ្រព្យលើសកម្មភាព Speculation
  - o ការត្រួតពិនិត្យឡើងវិញលើការវិនិយោគវិស័យកសិកម្មនៅកម្ពុជា។

### ១.១.២. ការតាមដាន និងវិភាគជាប្រចាំ លើការវិវត្តស្ថានភាពសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

- បាន÷
  - o ធ្វើបច្ចុប្បន្នភាពទិន្នន័យ និងកែសម្រួលលើរបាយការណ៍ Cambodia Macroeconomic Monitoring (CMM) ប្រចាំខែ
  - o វាយតម្លៃការអនុវត្តចំណូលឆ្នាំ ២០១៨ និងព្យាករការប្រមូលចំណូល ឆ្នាំ ២០១៩-២០២២
  - o រៀបចំឯកសារ "ក្របខ័ណ្ឌហិរញ្ញវត្ថុសាធារណៈរយៈពេលមធ្យម ២០២០-២០២២"
  - o រៀបចំអត្ថបទក្របខ័ណ្ឌគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច សម្រាប់ការរៀបចំសេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០២០
  - o រៀបចំរបាយការណ៍វឌ្ឍនភាព និង បញ្ហាប្រឈមនៃយុទ្ធសាស្ត្រកៀរគរចំណូលរយៈពេលមធ្យម ២០១៤-២០១៨
  - o ពិនិត្យលើទិន្នន័យ និងសិក្សាពីលទ្ធភាពក្នុងបែកចែកចំណាយមូលធនតាមវិស័យ ដើម្បីជាធាតុចូលក្នុងការ កែលម្អទម្រង់នៃឯកសារក្របខណ្ឌហិរញ្ញវត្ថុសាធារណៈរយៈពេលមធ្យម
  - o ត្រួតពិនិត្យ និងផ្តល់មតិយោបល់លើឯកសារ "យុទ្ធសាស្ត្រកៀរគរចំណូល ២០១៩-២០២៣"
  - o ត្រួតពិនិត្យ តាមដាន និងកែលម្អ នូវស្ថិតិសេដ្ឋកិច្ចតាមវិស័យ ដើម្បីពង្រឹងគុណភាពទិន្នន័យ
  - o ចុះតាមដានទិន្នន័យសម្រាប់របាយការណ៍សេដ្ឋកិច្ចតាមវិស័យ, MEF Database និងព្រឹត្តិបត្រស្ថិតិសេដ្ឋកិច្ច និងហិរញ្ញវត្ថុសម្រាប់ត្រីមាសទី២ ឆ្នាំ២០១៩
  - o ចុះស្រង់ថ្លៃទំនិញ និងសេវាលើទីផ្សាររាជធានីភ្នំពេញ ប្រចាំខែមិថុនា ឆ្នាំ២០១៩
  - o ចេញរបាយការណ៍ (១) ការវិវត្តថ្លៃទំនិញប្រើប្រាស់នៅរាជធានីភ្នំពេញ ប្រចាំខែឧសភា ឆ្នាំ២០១៩ (២) និន្នាការសេដ្ឋកិច្ច-សង្គម ប្រចាំខែមេសា-ឧសភា ឆ្នាំ២០១៩ (៣) តារាងប្រតិបត្តិការហិរញ្ញវត្ថុរដ្ឋ ប្រចាំខែឧសភា ឆ្នាំ២០១៩(៤) ស្ថិតិហិរញ្ញវត្ថុរបស់រាជរដ្ឋាភិបាល ប្រចាំខែឧសភា ឆ្នាំ២០១៩ និងបានផ្សព្វផ្សាយរបាយការណ៍ទាំងនេះជាភាសាខ្មែរ និងអង់គ្លេសក្នុងគេហទំព័ររបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
  - o ចេញរបាយការណ៍ (១) "នីតិវិធីនៃការកត់ត្រាគូលេខបំណុលក្រៅប្រទេសក្នុងគណនី (ការខ្ចីក្រៅប្រទេស) លេខ ៥០០២" សម្រាប់ខែមិថុនា ឆ្នាំ២០១៩ (២) ពាណិជ្ជកម្ម ប្រចាំខែឧសភា ឆ្នាំ២០១៩ (៣) ស្ថានភាពរូបិយវត្ថុនិងធនាគារ ប្រចាំខែឧសភា ឆ្នាំ២០១៩(៤) ថ្លៃទំនិញ និងសេវាលើទីផ្សារតាមបណ្តាខេត្តសម្រាប់ត្រឹមខែឧសភា ឆ្នាំ២០១៩ (៥)ព្យាករណ៍ថ្លៃសំបុត្រយន្តហោះសម្រាប់ត្រីមាសទី៣ ឆ្នាំ២០១៩
  - o ចេញតារាងទិន្នន័យថ្លៃទំនិញនិងសេវានៅរាជធានីភ្នំពេញប្រចាំខែឧសភាឆ្នាំ២០១៩
- បានបញ្ចប់÷
  - o របាយការណ៍ស្រាវជ្រាវអំពី "ចក្ខុវិស័យនៃការធ្វើទំនើបកម្មវិស័យកសិកម្មកម្ពុជា ២០៣០"
  - o ការរៀបចំយុទ្ធសាស្ត្រកៀរគរចំណូលឆ្នាំ២០១៩-២៩២៣ និងទទួលបានហត្ថលេខាពី **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ដើម្បីដាក់ឱ្យអនុវត្តជាផ្លូវការ
  - o របាយការណ៍សិក្សាស្រាវជ្រាវស្តីពី "ការវាយតំលៃសមិទ្ធផលរបស់គម្រោងជំរុញផលិតកម្មស្បៀងនៅកម្ពុជា"
- បានអនុវត្តគម្រោងសិក្សាស្រាវជ្រាវចំនួន ០៣ គម្រោង ក្នុងនោះ១. ឥទ្ធិពលនៃកំណើនប្រាក់ឈ្នួលអប្បបរមាលើសុខុមាលភាព និងផលិតភាពពលកម្ម របស់កម្មករក្នុងវិស័យកាត់ដេរនៅកម្ពុជា ឆ្នាំ២០១៩ ២. គម្រោងសិក្សាស្រាវជ្រាវស្តីពី "គំរូធុរកិច្ច

របស់សហគ្រាសធុនតូច និងមធ្យមក្នុងស្រុកនៅកម្ពុជា និង ៣.គម្រោងសិក្សាស្រាវជ្រាវស្តីពី ជម្រើសគំរូប្រាក់ឈ្នួលអប្បបរមានៅកម្ពុជា

- បានរៀបចំសិក្ខាសាលាប្រឹក្សាយោបល់ និងចែករំលែកចំណេះដឹងវិទ្យាសាស្ត្រ ស្តីពី បច្ច័យ និងជវភាពនៃបដិវត្តន៍ឧស្សាហកម្មដំណាក់កាលទី៤.០ លើរចនាសម្ព័ន្ធសេដ្ឋកិច្ច និងសង្គមនៅកម្ពុជា។

## ១.២. ការអភិវឌ្ឍវិស័យហិរញ្ញវត្ថុ

ផ្នែកនេះ ត្រូវបានអនុវត្តដោយអគ្គនាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុ, អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិគណនេយ្យ និងអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិគាំពារសង្គម។ អគ្គនាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុមានមុខងារក្នុងការគ្រប់គ្រង និងត្រួតពិនិត្យទីផ្សារ និងស្ថាប័នហិរញ្ញវត្ថុ អាជីវកម្មភ្នាល់គ្រប់ប្រភេទ អាជីវកម្មអចលនទ្រព្យ និងចូលរួមប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម[2]។ ឯអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិគណនេយ្យ បំពេញបេសកកម្មគ្រប់គ្រងអភិវឌ្ឍវិស័យគណនេយ្យនិងសវនកម្ម។ សម្រាប់អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិគាំពារសង្គមវិញ បំពេញមុខងារជាសេនាធិការគោលនយោបាយ និងបច្ចេកទេសរបស់ក្រុមប្រឹក្សាជាតិគាំពារសង្គម។ ជាលទ្ធផល អគ្គនាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុ និងអគ្គលេខាធិការដ្ឋានទាំងពីរ បានអនុវត្ត និងទទួលបានវឌ្ឍនភាពគួរឱ្យកត់សម្គាល់ដូចខាងក្រោម÷

### ១.២.១. វិស័យធានារ៉ាប់រង និងសោធន

- បានបញ្ចប់ការវិភាគនៅហ្វឹងកន្លែងលើស្ថានភាពហិរញ្ញវត្ថុ ប្រចាំត្រីមាសទី៤ ឆ្នាំ២០១៨ ប្រចាំឆ្នាំ២០១៨ និងប្រចាំត្រីមាសទី១ ឆ្នាំ២០១៩
- បានរៀបចំសិក្ខាសាលាផ្សព្វផ្សាយស្តីវិធាន និងនីតិវិធីនៃការប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្មសម្រាប់វិស័យធានារ៉ាប់រងចំនួន ០២លើក
- បានផ្តល់ និងបន្តសុពលភាពអាជ្ញាបណ្ណអាជីវកម្មជូនគ្រឹះស្ថានធានារ៉ាប់រងមួយចំនួនដូចជា÷ បានផ្តល់អាជ្ញាបណ្ណអាជីវកម្មធានារ៉ាប់រងអាយុជីវិត ០១ក្រុមហ៊ុន អាជ្ញាបណ្ណអាជីវកម្មធានារ៉ាប់រងទូទៅចំនួន ០១ក្រុមហ៊ុន និងបានសម្រេចបន្តសុពលភាពអាជ្ញាបណ្ណអាជីវកម្មធានារ៉ាប់រងទូទៅចំនួន ០១ក្រុមហ៊ុន អាជ្ញាបណ្ណអាជីវកម្មធានារ៉ាប់រងខ្នាតតូចបណ្តោះអាសន្នចំនួន ០៤ក្រុមហ៊ុន អាជ្ញាបណ្ណអាជីវកម្មជើងសាធានារ៉ាប់រងចំនួន ០១ក្រុមហ៊ុន អាជ្ញាបណ្ណអាជីវកម្មភ្នាក់ងារធានារ៉ាប់រងចំនួន ០២ក្រុមហ៊ុន និងបានបន្តវិញ្ញាបនបត្រធានារ៉ាប់រងសាខាចំនួន ០៤ក្រុមហ៊ុន



កម្រងរូបភាពពិភាក្សាការងារជាមួយគណៈប្រតិភូក្រុមប្រឹក្សាពាណិជ្ជកម្មអឺរ៉ុប-អាស៊ាន ("EU-ABC")

- បានធ្វើការសិក្សាស្រាវជ្រាវនៅលើច្បាប់ស្តីពីការប្រកួតប្រជែងរបស់ប្រទេសមួយចំនួនក្នុងតំបន់ដូចជាព្រុយណេ ម៉ាឡេស៊ី ថៃ និងសិង្ហបុរី
- បានរៀបចំ និងសិក្សាសេចក្តីព្រាងអនុក្រឹត្យស្តីពីការកំណត់ប្រភេទយានយន្តសម្រាប់កាតព្វកិច្ចធានារ៉ាប់រង ដើម្បីទទួលបានធាតុចូល
- បាននិងកំពុងសិក្សាស្រាវជ្រាវដើម្បីប្រមូលធាតុចូលក្នុងការរៀបចំច្បាប់ស្តីពីរបបសោធនឯកជនស្ម័គ្រចិត្ត

---

[2] មាត្រា ៤៨ នៃអនុក្រឹត្យលេខ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

- បានចូលរួមផ្តល់យោបល់ និងបកប្រែ លើគម្រោងបង្កើតអោយមានកិច្ចសហប្រតិបត្តិការឥណ្ឌា និងអាស៊ាន ពាក់ព័ន្ធនឹងវិស័យធានារ៉ាប់រង
- បានចូលរួមវេទិការពិភាក្សាស្តីពីការធានារ៉ាប់រងឆ្នាំ២០១៩ នៅប្រទេសជប៉ុន
- បានចូលរួមវគ្គបណ្តុះបណ្តាលស្តីពី “Insurance Policy Development and Supervision” នៅប្រទេសកូរ៉េ។

### ១.២.២. វិស័យទីផ្សារ និងស្ថាប័នហិរញ្ញវត្ថុ

- បានរៀបចំសេចក្តីព្រាងប្រកាសស្តីពី “កម្រៃសេវានៃការចុះបញ្ជីបរធនបាលកិច្ច”
- បានរៀបចំលិខិតគោរពស្នើសុំហត្ថលេខាដ៏ខ្ពង់ខ្ពស់របស់ សម្តេចតេជោនាយករដ្ឋមន្ត្រី លើសេចក្តីព្រាងអនុក្រឹត្យស្តីពី “ការចុះបញ្ជីបរធនបាលកិច្ច”
- បានរៀបចំរបាយការណ៍លើករណីការថយចុះបរធនរបស់បរធនបាលកិច្ចហិរញ្ញវត្ថុស្ថាបនាសហគមន៍កម្ពុជា និងសំណើសុំពង្រីកការវិនិយោគលើវិស័យមីក្រូហិរញ្ញវត្ថុក្នុងប្រទេសមីយ៉ាន់ម៉ា
- បានរៀបចំសិក្ខាសាលាស្តីពី “បរធនបាលកិច្ចហិរញ្ញវត្ថុ និងបរធនបាលកិច្ចនៅកម្ពុជា” និងសិក្ខាសាលា ស្តីពីដំណើរវិវឌ្ឍន៍នៃបច្ចេកវិទ្យាហិរញ្ញវត្ថុ”
- បានចូលរួមកិច្ចប្រជុំគណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ លើយុទ្ធសាស្ត្រជាតិស្តីពី បរិយាប័ន្នហិរញ្ញវត្ថុឆ្នាំ២០១៩-២០២៥ ដែលបានប្រព្រឹត្តទៅកាលពីថ្ងៃទី០៤ ខែមិថុនា ឆ្នាំ២០១៩
- បានប្រជុំកែសម្រួលឯកសារសេចក្តីព្រាងយុទ្ធសាស្ត្រជាតិស្តីពី បរិយាប័ន្នហិរញ្ញវត្ថុចុងក្រោយ កាលពីថ្ងៃទី២២ ខែមេសា ឆ្នាំ២០១៩ នៅធនាគារជាតិនៃកម្ពុជា។

### ១.២.៣. វិស័យអាជីវកម្មល្បែង និងប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម

❖ គិតត្រឹមឆមាសទី១ ឆ្នាំ២០១៩ នេះ ចំណូលសរុបប្រមូលបានពីអាជីវកម្មកាស៊ីណូសរុបចំនួន÷ **42,463,370.04 ដុល្លារ** ស្មើនឹង **169,880.50 លានរៀល** ស្មើនឹង 74.99% នៃផែនការ (226,511 លានរៀល) ក្នុងនោះប្រមូលបានពីបំណុលមានចំនួន 1,860,300 ដុល្លារ លើបំណុលសរុបចំនួន 2,384,550 ដុល្លារ នៅសល់ចំនួន 542,250 ដុល្លារ។



❖ គិតត្រឹមឆមាសទី១ ឆ្នាំ២០១៩ នេះដែរ ចំណូលប្រមូលបានពីថ្លៃអាជ្ញាបណ្ណសរុបចំនួន 2,695,000 ដុល្លារ ស្មើនឹង 10,840.55 លានរៀល ស្មើនឹង 99.55% នៃផែនការ (10,890 លានរៀល )។

❖ គិតត្រឹមឆមាសទី១ ឆ្នាំ២០១៩នេះ ចំណូលប្រមូលបានសរុបចំនួន **2,451,183,080 លានរៀល** ក្នុងនោះចំណូលកាតព្វកិច្ចប្រចាំខែចំនួន 1,891.18 លានរៀល ស្មើនឹង 75.35%នៃផែនការឆ្នាំ (2,509.70 លានរៀល) ចំណូលពីថ្លៃអាជ្ញាបណ្ណចំនួន 480.00 លានរៀល, ចំណូលពីប្រភេទឆ្នោត-ឡូតូចំនួន 80.00 លានរៀល។ (ធ្វើក្រាបលើចំណូលការស៊ីណូនេះ)




- បានរៀបចំកិច្ចប្រជុំ និងធ្វើកំណត់ហេតុ ស្តីពីការកំណត់ចំណូលកាតព្វកិច្ចកាស៊ីណូសម្រាប់ឆ្នាំ២០១៩ ជាមួយក្រុមហ៊ុនកាស៊ីណូទាំងអស់ ចាប់ពីថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០១៨ រហូតដល់បច្ចុប្បន្ន
- បានបញ្ចប់ការចុះត្រួតពិនិត្យអាជីវកម្មកាស៊ីណូប្រចាំត្រីមាសទី១ និងទី២ ឆ្នាំ២០១៩
- បានចេញលិខិតជូនដំណឹងស្តីពីការផ្តល់ឯកសារបន្ថែមសម្រាប់ធ្វើអាជ្ញាបណ្ណកាស៊ីណូចំនួន ១៥ក្រុមហ៊ុន
- ធ្វើសាលាកប័ត្របង់ចំណូលចូលថវិកាជាតិប្រចាំខែមករា ដល់ខែមិថុនា ឆ្នាំ២០១៩
- បានអញ្ជើញតំណាងក្រសួងមហាផ្ទៃ និងក្រសួងយុត្តិធម៌ ចូលរួមប្រជុំពិនិត្យពិភាក្សាលើ សេចក្តីព្រាងច្បាប់ស្តីពី "ការគ្រប់គ្រងរមណីយដ្ឋានសមាហរណ និងល្បែងពាណិជ្ជកម្ម" នៅក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានចូលរួមប្រជុំពិភាក្សាជាមួយក្រុមប្រតិបត្តិនៃគណៈកម្មការចម្រុះ លើការអនុវត្តសេចក្តីណែនាំលេខ០២៨ សណន និងលេខ០១២ សហវ ចុះថ្ងៃទី០១ ខែកញ្ញា ឆ្នាំ២០១៦ ស្តីពីការអនុវត្តវិធានការបង្រ្កាបល្បែងស៊ីសងខុសច្បាប់ និងការជំរុញឱ្យប្រតិបត្តិករល្បែងពាណិជ្ជកម្មមកបំពេញនិតិភាពអាជ្ញាបណ្ណ នៅខេត្តព្រះសីហនុ
- បានចូលរួមក្នុងក្រុមប្រតិបត្តិនៃគណៈកម្មការចម្រុះ ចុះតាមដានការអនុវត្តសេចក្តីណែនាំលេខ០២៨ សណន និង លេខ ០១២ សហវ ចុះថ្ងៃទី០១ ខែកញ្ញា ឆ្នាំ២០១៦ ស្តីពីការអនុវត្តវិធានការបង្រ្កាបល្បែងស៊ីសងខុសច្បាប់ និងស្រាវជ្រាវត្រួតពិនិត្យឯកសារគតិយុត្ត និងជំរុញកៀរគរអាជីវកម្មល្បែងកាស៊ីណូ និងអនឡាញដែលមាននៅខេត្ត ព្រះសីហនុ និងខេត្តស្វាយរៀង ឱ្យមកបំពេញនីតិភាព នៅក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

### ១.២.៤. វិស័យអាជីវកម្មអចលនវត្ថុ បញ្ចាំ និងប្រាតិភោគដោយអនុប្បទាន

- បានរៀបចំឯកសារក្រុមហ៊ុនសេវាកម្មវាយតម្លៃ និងសេវាកម្មភ្នាក់ងារអចលនវត្ថុ ជូនក្រុមហ៊ុនថ្មី ចំនួន២៣ក្រុមហ៊ុននិងលើការស្នើសុំបង់ថ្លៃអាជ្ញាបណ្ណប្រចាំឆ្នាំជូនក្រុមហ៊ុនចាស់ចំនួន៥៥ក្រុមហ៊ុន
- បានសម្រេចផ្ដល់អាជ្ញាបណ្ណថ្មីជូនក្រុមហ៊ុនអភិវឌ្ឍលំនៅឋានចំនួន ២៩ក្រុមហ៊ុនស្មើនឹង ២៩ គម្រោង
- បានរៀបចំឯកសារផ្ដល់អាជ្ញាបណ្ណថ្មីជូនក្រុមហ៊ុន/សហគ្រាសប្រកបអាជីវកម្មទទួលបញ្ចាំចំនួន ៣២ឯកសារ និង បន្តសុពលភាពអាជ្ញាបណ្ណចំនួន ១៧៤ ក្រុមហ៊ុន/សហគ្រាស
- បានរៀបចំសិក្ខាសាលាផ្សព្វផ្សាយខ្លឹមសារប្រកាសស្ដីពី "ការគ្រប់គ្រងអាជីវកម្មផ្ដល់សេវាកម្ម វាយតម្លៃ និងសេវាកម្មអចលនវត្ថុ" សម្រាប់អាជីវកម្មថ្មី នៅខេត្តព្រះសីហនុ និងសិក្ខាសាលាផ្សព្វផ្សាយខ្លឹមសារប្រកាសស្ដីពី ការគ្រប់គ្រងអាជីវកម្មអភិវឌ្ឍលំនៅឋាន ជាមួយគណៈអភិបាលខណ្ឌទាំង១២ នៃរាជធានីភ្នំពេញ
- បានរៀបចំប្រជុំក្រុមការងារចងក្រងស្ថិតិ និងសម្របសម្រួលព័ត៌មានទីផ្សារអចលនវត្ថុ
- បានរៀបចំវគ្គបណ្ដុះបណ្ដាលស្ដីពី កាតព្វកិច្ចរបស់បុគ្គលរាយការណ៍អភិវឌ្ឍលំនៅឋាន ក្នុងការប្រឆាំងការសម្អាតប្រាក់ និង ហិរញ្ញប្បទានភេរវកម្ម និងការរៀបចំរបាយការណ៍ប្រចាំខែ ប្រចាំ ឆមាស និងប្រចាំឆ្នាំ ជូនក្រុមហ៊ុនអភិវឌ្ឍលំនៅឋាន នៅថ្ងៃទី០២ ខែឧសភា ឆ្នាំ២០១៩
- បានរៀបចំប្រជុំធ្វើវិសោធនកម្មប្រកាស ៩៦៥ សហវ.ប្រក ចុះថ្ងៃទី២៤ ខែសីហា ឆ្នាំ២០១៦ ស្ដីពីការគ្រប់គ្រងអាជីវកម្មអភិវឌ្ឍលំនៅឋាន នៅថ្ងៃទី២១ ខែឧសភា ឆ្នាំ២០១៩
- បាននឹងកំពុងស្រាវជ្រាវឯកសារពីបណ្ដាប្រទេសផ្សេងៗពាក់ព័ន្ធទៅនឹងយន្តការនៃគ្រប់គ្រងហានិភ័យ ក្នុងវិស័យអចលនវត្ថុ
- បានរៀបចំ Risk Assessment Worksheet សម្រាប់វិស័យសេវាកម្មអចលនវត្ថុ និងបានធ្វើតេស្ដសាកល្បងវាយតម្លៃក្រុមហ៊ុនវាយតម្លៃ និងភ្នាក់ងារអចលនវត្ថុ ចំនួន ១៧៨ ក្រុមហ៊ុន
- បានរៀបចំ និងផ្សព្វផ្សាយសេចក្ដីប្រកាសព័ត៌មានស្ដីពីការទិញ-លក់អចលនទ្រព្យ (ដីឡូតិ៍ និងផ្ទះ) នៅលើទំព័រសារព័ត៌មាន និងតាមបណ្ដាញសង្គម
- បានរៀបចំរបាយការណ៍ស្ដីពីលទ្ធផលនៃការចុះត្រួតពិនិត្យ ស្រាវជ្រាវ និងប្រមូលព័ត៌មានអំពី អាជីវកម្មទទួលបញ្ចាំ និង ប្រាតិភោគដោយអនុប្បទាននៅរាជធានីភ្នំពេញ
- បានរៀបចំលិខិតជូនដំណឹងដល់គម្រោងអភិវឌ្ឍលំនៅឋាន ដែលគ្មានអាជ្ញាបណ្ណអភិវឌ្ឍលំនៅឋានចំនួន ២០ គម្រោង ឱ្យមកដាក់ពាក្យស្នើសុំអាជ្ញាបណ្ណអភិវឌ្ឍលំនៅឋាន
- បានចុះបេសកកម្មស្រាវជ្រាវ និងត្រួតពិនិត្យអាជីវកម្មអភិវឌ្ឍលំនៅឋាន អាជីវកម្មសេវាកម្ម អចលនវត្ថុ និងអាជីវកម្មទទួលបញ្ចាំ និងប្រាតិភោគដោយអនុប្បទានចំនួន ០៧ លើក
- បានចុះត្រួតពិនិត្យសកម្មភាពអាជីវកម្មនិងតាមដានការអនុវត្តលក្ខខណ្ឌនៃការផ្ដល់អាជ្ញាបណ្ណ របស់ក្រុមហ៊ុនអភិវឌ្ឍលំនៅឋាន នៅខេត្តកំពង់ចាម
- បានចុះត្រួតពិនិត្យ និងពង្រឹងសមត្ថភាពមន្ត្រីទទួលបញ្ចាំ និងប្រាតិភោគនៅមន្ទីរជំនាញសេដ្ឋកិច្ច និងហិរញ្ញវត្ថុ នៅខេត្តបាត់ដំបង ខេត្តមណ្ឌលគិរី និងនៅខេត្តរតនៈគិរី
- បានចុះត្រួតពិនិត្យលើការអនុវត្តកាតព្វកិច្ចតាមលក្ខខណ្ឌ នៃការផ្ដល់អាជ្ញាបណ្ណរបស់ក្រុមហ៊ុន សេវាកម្មវាយតម្លៃ និងភ្នាក់ងារអចលនវត្ថុ និងក្រុមហ៊ុនដែលពុំទាន់មានអាជ្ញាបណ្ណ នៅខេត្តព្រះសីហនុ និងខេត្តសៀមរាប

- បានចុះត្រួតពិនិត្យការអនុវត្តកាតព្វកិច្ចតាមលក្ខខណ្ឌនៃការផ្តល់អាជ្ញាបណ្ណក្រុមហ៊ុនវាយតម្លៃ និងភ្នាក់ងារអចលនវត្ថុ និងក្រុមហ៊ុនគ្រប់គ្រងអចលនវត្ថុ នៅរាជធានីភ្នំពេញ
- បានចុះត្រួតពិនិត្យសកម្មភាពអាជីវកម្មទទួលបញ្ចាំនិងទទួលប្រាតិភោគដោយអនុប្បទានក្នុងខេត្តសៀមរាប ខេត្តបន្ទាយមានជ័យ ខេត្តតាកែវ ខេត្តកំពត ខេត្តពោធិ៍សាត់ និងខេត្តបាត់ដំបង
- បានចូលរួមវគ្គបណ្តុះបណ្តាលស្តីពី ការវាយតម្លៃហានិភ័យក្នុងវិស័យកាស៊ីណូ (Casino Risk Assessment) ជាមួយនឹងជំនាញការ World Bank កាលពីថ្ងៃទី ២៥-២៨ ខែកុម្ភៈ ឆ្នាំ២០១៩ នៅ អគារ Exchange Square
- ចូលរួមប្រជុំបេសកកម្មជំនួយបច្ចេកទេសលើកទី២របស់ធនាគារពិភពលោកដើម្បីបញ្ចប់ការរៀបចំ ធ្វើ Standard Operation Procedure សម្រាប់ការប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទាន ភេរវកម្ម នៅការិយាល័យធនាគារពិភពលោក (Exchange square) កាលពីថ្ងៃទី១២-១៧ ខែមិថុនា ឆ្នាំ២០១៩បានចូលរួមកិច្ចប្រជុំ (Wrap Up Meeting) ជាមួយជំនាញការ ADB។

## ១.៣. ការគ្រប់គ្រងអភិវឌ្ឍវិស័យគណនេយ្យនិងសវនកម្ម

- ធ្វើលិខិតទៅក្រុមហ៊ុនសវនកម្មអំពីសំណើសុំបញ្ជីឈ្មោះក្រុមហ៊ុន និងអង្គភាពមិនស្វែងរកប្រាក់ចំណេញ ទាំងអស់ ដែលបានចុះធ្វើសវនកម្មសម្រាប់ការិយបរិច្ឆេទឆ្នាំ២០១៧ និង២០១៨
- បន្តពិនិត្យ និងរៀបចំឯកសារពាក្យស្នើសុំលេខអត្តសញ្ញាណកម្មរបាយការណ៍ហិរញ្ញវត្ថុ សម្រាប់អង្គភាពមិនស្វែងរកប្រាក់ចំណេញនិង ទាក់ទាង NGO មកយកលេខអត្តសញ្ញាណកម្ម
- គិតត្រឹមថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៩ ក្រុមហ៊ុនប្រកបវិជ្ជាជីវៈគណនេយ្យ និង សវនកម្មដែលមានសុពលភាពមាន ចំនួន ៤៨ ក្រុមហ៊ុន
- បានបញ្ចប់ការសម្រួលលើឯកសារស្តង់ដាគណនេយ្យសាធារណៈកម្ពុជារបាយការណ៍ហិរញ្ញវត្ថុតាម មូលដ្ឋានគណនេយ្យសាច់ប្រាក់
- ឯកសារ និងសេចក្តីព្រាងអនុក្រឹត្យស្តីពីការបង្កើតការរៀបចំ និងការប្រព្រឹត្តទៅនៃស្ថាប័នវិជ្ជាជីវៈគណនេយ្យ និង សវនកម្មកំពុងរៀបចំដើម្បីដាក់ជូនសម្តេច អគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាណាចក្រ កម្ពុជាដើម្បីចុះហត្ថលេខា
- សេចក្តីព្រាងប្រកាសស្តីពីយន្តការបែបបទ និងនីតិវិធីដោះស្រាយវិវាទគណនេយ្យ និងសវនកម្មសម្រេចបានជំពូកទី៧ និង ១៤ប្រការ
- ស្តង់ដាគណនេយ្យសាមញ្ញសម្រាប់សហគ្រាស
  - បន្តការសិក្សាបន្ថែមលើសេចក្តីព្រាងស្តង់ដាគណនេយ្យសាមញ្ញសម្រាប់សហគ្រាស
  - ប្រកាសស្តីពី "ការដាក់ឱ្យអនុវត្តស្តង់ដាគណនេយ្យសាធារណៈកម្ពុជាមូលដ្ឋានសាច់ប្រាក់" ត្រូវបានដាក់ឱ្យប្រើប្រាស់
  - អត្ថបទស្តង់ដាគណនេយ្យសាធារណៈកម្ពុជាមូលដ្ឋានសាច់ប្រាក់ត្រូវបានបញ្ចប់ការបកប្រែរួចរាល់ដែលត្រូវភ្ជាប់ ជាឧបសម្ព័ន្ធទៅនឹងប្រកាសស្តីពី "ការដាក់ឱ្យអនុវត្តស្តង់ដាគណនេយ្យសាធារណៈកម្ពុជាមូលដ្ឋានសាច់ប្រាក់"
  - បានកែសម្រួលអត្ថបទស្តង់ដា Cash Basis IPSAS (ភាសាអង់គ្លេសឱ្យស្របទៅតាមអត្ថបទស្តង់ដាគណនេយ្យសាធារណៈកម្ពុជាមូលដ្ឋានសាច់ប្រាក់)
- ស្តង់ដារបាយការណ៍ហិរញ្ញវត្ថុកម្ពុជាសម្រាប់អង្គភាពមិនស្វែងរកប្រាក់ចំណេញ

- o បានសិក្សាលើភាពខុសគ្នារវាងស្តង់ដារបាយការណ៍ហិរញ្ញវត្ថុកម្ពុជាសម្រាប់អង្គភាពមិនស្វែងរកប្រាក់ចំណេញ កម្រិត ១ និងកម្រិត ២
  - o បានសិក្សាលើរបាយការណ៍លទ្ធផលសេវា និងរបាយការណ៍លទ្ធផលហិរញ្ញវត្ថុ
  - o បានសិក្សាស្រាវជ្រាវស្វែងរកម្ចាស់ជំនួយសំខាន់ៗ ដែលបានផ្តល់ជំនួយមកកាន់អង្គភាពមិនស្វែងរកប្រាក់ចំណេញ ក្នុងប្រទេសកម្ពុជា
- ស្តង់ដាគណនេយ្យសម្រាប់គ្រឹះស្ថានសាធារណៈរដ្ឋបាល
  - o សិក្សានិងកែសម្រួលបរិបទកម្ពុជារួចរាល់ចំនួន៥ស្តង់ដា គឺ Standard 1: Financial Statements Standard 2: Expense, 3: Standard 4: Revenue, Standard 5 Intangible Assets និង Standard 6 Tangible Assets
  - o សិក្សានិងកែសម្រួលមកបរិបទកម្ពុជា គឺ Standard 8: Inventories
- ការសិក្សាស្រាវជ្រាវបន្ថែម បច្ចេកទេសស្តង់ដាទ្រព្យវិនិយោគ
  - o ប្រភពធនធានដែលជឿទុកចិត្តក្នុងការវាយតម្លៃទ្រព្យសម្បត្តិវិនិយោគ
  - o ចូលរួមពិនិត្យនិងកែសម្រួលអត្ថន័យបច្ចេកស័ព្ទគណនេយ្យនិងសវនកម្មដែលមិនទាន់មានភាពពេញលេញ និងការបកប្រែ ពាក្យពុំទាន់ស៊ីអត្ថន័យនិងពាក្យដើម
  - o ធ្វើការប្រៀបធៀបស្តង់ដា CISA Version 2018 & CISA Version 2016-2017
  - o សិក្សាអំពីសេចក្តីព្រាងនៃស្តង់ដាសវនកម្មអន្តរជាតិថ្មីៗ
  - o រៀបចំសិក្ខាសាលាផ្សព្វផ្សាយច្បាប់ស្តីពី " គណនេយ្យ និងសវនកម្ម " នៅសាកលវិទ្យាល័យធនធានមនុស្សកាលពីថ្ងៃទី ១៣ ខែមិថុនា ឆ្នាំ២០១៩
  - o រៀបចំសិក្ខាសាលាផ្សព្វផ្សាយស្តីពី " កាតព្វកិច្ចគណនេយ្យ និងសវនកម្ម និងបច្ចុប្បន្នភាពនៃច្បាប់សារពើពន្ធ "សម្រាប់សហគ្រាស អ្នកជាប់ពន្ធដែលនឹងប្រព្រឹត្តទៅនៅថ្ងៃទី ២៧ ខែមិថុនា ឆ្នាំ២០១៩។

### ១.៤. កិច្ចគាំពារសង្គម

- បានដាក់ឱ្យដំណើរការកម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនស្រ្តីមានផ្ទៃពោះ និងកុមារអាយុក្រោម ២ឆ្នាំ កាលពីថ្ងៃទី០១ ខែមិថុនា ឆ្នាំ២០១៩ ដោយប្រកាសអន្តរក្រសួង ស្តីពីការអនុវត្តកម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនស្រ្តីមានផ្ទៃពោះ និងកូនអាយុក្រោម ២ ឆ្នាំ នៃគ្រួសារមានប័ណ្ណសមធម៌ ឬប័ណ្ណអាទិភាព
- បានបញ្ចប់ការវាយតម្លៃទៅលើការអនុវត្តកម្មវិធីផ្តល់អាហារតាមសាលារៀនដោយប្រើប្រាស់កសិផល នៅក្នុងសហគមន៍ដែលបាន និងកំពុងអនុវត្តសាកល្បងដោយអង្គការស្បៀងអាហារពិភពលោក
- បាននិងកំពុងបន្តកិច្ចការសម្របសម្រួល និងសហការជាមួយក្រសួងអប់រំ យុវជន និងកីឡា និងអង្គការស្បៀងអាហារពិភពលោក អំពីការរៀបចំយន្តការផ្ទេរការគ្រប់គ្រងកម្មវិធី ឱ្យទៅជាកម្មវិធីជាតិជាជំហានស្របតាមភាពទ្រទ្រង់បាននៃថវិកា
- បានបញ្ចប់ការពិនិត្យលើទិដ្ឋភាពបច្ចេកទេស និងហិរញ្ញវត្ថុ នៃសេចក្តីព្រាងអនុក្រឹត្យ ស្តីពី "ជំនួយសង្គមសម្រាប់មនុស្សវ័យចាស់ក្រីក្រគ្មានទីពឹង" និងមជ្ឈមណ្ឌលជាតិគាំពារមនុស្សចាស់រាជធានីភ្នំពេញ របស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- បានផ្តល់យោបល់លើការរៀបចំសេចក្តីព្រាងច្បាប់ស្តីពីរបបសន្តិសុខសង្គម ដែលរៀបចំឡើងដោយក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈដែលសេចក្តីព្រាងច្បាប់នេះទទួលបានការអនុវត្តពីក្រុមប្រឹក្សាជាតិគាំពារសង្គម

- បានសិក្សាប្រៀបធៀបលើរបបសន្តិសុខសង្គម, របបសោធន, គោលនយោបាយពន្ធដារ និងយន្តការ និងនីតិវិធីទទួលពាក្យបណ្តឹង និងផ្សះផ្សាវិវាទ ក្នុងបណ្តាប្រទេសមួយចំនួន។

## ២. គោលនយោបាយគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងទ្រព្យសម្បត្តិរដ្ឋ

គោលបំណងគោលនយោបាយទី២ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុគឺ “ពង្រឹង និងបង្កើនស័ក្តិសិទ្ធភាព និងប្រសិទ្ធភាពនៃការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងទ្រព្យសម្បត្តិរដ្ឋ” ដោយមានកម្មវិធីចំនួន០៣ និងអនុវត្តកម្មវិធីចំនួន១៤ គាំទ្រ។ លទ្ធផលនៃការអនុវត្តប្រចាំឆមាសទី១ ឆ្នាំ២០១៩ នៃគោលបំណងគោលនយោបាយទី២ នេះ មានដូចក្នុងរបាយការណ៍ខាងក្រោមនេះ÷

### ២.១. ការកៀរគរចំណូលថវិកាជាតិ និងគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ

ផ្នែកខាងក្រោម ត្រូវបានអនុវត្តដោយអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា និងអគ្គនាយកដ្ឋានពន្ធដារ។ អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា មានបេសកកម្មសំខាន់ៗក្នុងនោះ÷ ១.ទទួលខុសត្រូវក្នុងការគ្រប់គ្រង ត្រួតពិនិត្យ និងប្រមូលអាករ និងកម្រៃផ្សេងៗលើទំនិញនាំចេញ ឬនាំចូល ស្របតាមប្បញ្ញត្តិ ស្តីពីគយ ព្រមទាំងច្បាប់ និងបទប្បញ្ញត្តិផ្សេងទៀតដែលពាក់ព័ន្ធនឹងការនាំចេញ នាំចូល ការធ្វើចរាចរ និងការធ្វើសន្និធិទំនិញ ២.ដាក់បទប្បញ្ញត្តិលើការធ្វើចរាចរ ការធ្វើសន្និធិ និងការដឹកជញ្ជូនឆ្លងកាត់នៃទំនិញនាំចេញ ឬនាំចូល ៣. ជំរុញការបង្ការ និងបង្ក្រាបអំពើល្មើស និងអំពើរត់ពន្ធ ៤.ចូលរួមអនុវត្តគោលនយោបាយពាណិជ្ជកម្មអន្តរជាតិ នៃព្រះរាជាណាចក្រកម្ពុជា ៥. ជំរុញអនុវត្តតាមស្តង់ដារអន្តរជាតិ និងឧត្តមានុវត្តន៍ ដែលពាក់ព័ន្ធនឹងការត្រួតពិនិត្យគយ និងការសម្រួលពាណិជ្ជកម្ម ជាពិសេស ការអនុវត្តគោលនយោបាយនៃកិច្ចសម្រួលពាណិជ្ជកម្ម តាមរយៈការគ្រប់គ្រងហានិភ័យ និងការធ្វើស្វ័យប្រវត្តិកម្មគយ[3]។ ដោយឡែកអគ្គនាយកដ្ឋានពន្ធដារ មានបេសកកម្មសំខាន់ៗផងដែរ ក្នុងនោះ ÷ ១. ផ្តល់សេវាដល់អ្នកជាប់ពន្ធរួមមាន ការផ្តល់ព័ត៌មាន អប់រំ ពន្យល់ណែនាំ ដើម្បីឱ្យអ្នកជាប់ពន្ធប្រតិបត្តិត្រឹមត្រូវ តាមច្បាប់ និងបទប្បញ្ញត្តិនានាស្តីពីពន្ធដារ ២. អនុវត្តកម្មវិធីចាប់បង្ខំ ដោយធ្វើសវនកម្ម ការអនុវត្តវិធានការតឹងទារ អនុវត្តទោសទណ្ឌ តាមការកំណត់ស្តីពីពន្ធដារ ចំពោះអ្នកជាប់ពន្ធដែលមិនបានប្រតិបត្តិត្រឹមត្រូវតាមច្បាប់ និងបទប្បញ្ញត្តិនានាស្តីពីពន្ធដារ ៣. ប្រមូលចំណូលពន្ធ តាមការអនុវត្តត្រឹមត្រូវនូវច្បាប់ និងបទប្បញ្ញត្តិនានាស្តីពីពន្ធដារ និងបង់គ្រប់គ្រាន់ចូលថវិកាជាតិ ៤. ផ្តល់សេវា និងការអប់រំអ្នកជាប់ពន្ធ ដើម្បីធានាឱ្យច្បាប់នានាស្តីពីពន្ធដារ ត្រូវបានគោរព និងអនុវត្តត្រឹមត្រូវ ៥. អនុវត្តកម្មវិធីចាប់បង្ខំ ប្រកបដោយប្រសិទ្ធភាព មានការទទួលខុសត្រូវខ្ពស់ និងស្មើភាពគ្នា ចំពោះអ្នកជាប់ពន្ធ ដែលមិនគោរពច្បាប់ និងបទប្បញ្ញត្តិស្តីពីសារពើពន្ធ ៦. អនុវត្តគោលការណ៍យុត្តិធម៌ក្នុងការអនុវត្តច្បាប់ និងបទប្បញ្ញត្តិនានាស្តីពីពន្ធដារ ដើម្បីបង្កើនជំនឿទុកចិត្ត ចំពោះរដ្ឋបាលសារពើពន្ធ ៧. បន្ថយការចំណាយរបស់រដ្ឋបាលសារពើពន្ធ ក្នុងការរៀបចំកម្មវិធី និងកិច្ចដំណើរការរបស់ក្រសួង ធ្វើឱ្យមានភាពសាមញ្ញ ចំពោះតម្រូវការផ្សេងៗ និងបន្ថយចំណាយរបស់អ្នកជាប់ពន្ធ ៨.បង្កើនសមត្ថភាព ចំណេះដឹងដល់មន្ត្រីពន្ធដារជាប្រចាំ ដើម្បីបំពេញការងារឱ្យមានប្រសិទ្ធភាព ៩.បង្កើនប្រសិទ្ធភាពក្នុងការគ្រប់គ្រង តាមរយៈគោលនយោបាយ កិច្ចដំណើរការការងារ និងប្រព័ន្ធការងារ ដែលមានភាពច្បាស់លាស់ ទំនើប និងមានការទទួលខុសត្រូវខ្ពស់ចំពោះការងាររបស់ខ្លួន[4]។ ផ្នែកនេះក៏ចូលរួមអនុវត្តដោយអគ្គនាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋ និងចំណូលមិនមែនសារពើពន្ធ[5]។ ជាលទ្ធផល អគ្គនាយកដ្ឋានបានអនុវត្ត និងទទួលបានវឌ្ឍនភាពគួរឱ្យកត់សម្គាល់ដូចខាងក្រោម÷

#### ២.១.១. ការកៀរគរចំណូលសារពើពន្ធ

---

[3] មាត្រា ៣០ នៃអនុក្រឹត្យលេខ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

[4] មាត្រា ៣៥ នៃអនុក្រឹត្យលេខ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

[5] មាត្រា ៤០ នៃអនុក្រឹត្យលេខ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

❖ វិស័យគយ និងរដ្ឋាករកម្ពុជា

- ចំណូលគយប្រមូលបាន÷ ក្នុងឆមាសទី១ ឆ្នាំ២០១៩ ចំណូលបង់ចូលរតនាគារជាតិមានប្រមាណ ៥,៩៤៤.៣ ប៊ីលានរៀល ត្រូវជា ៦៥.១% នៃផែនការច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៩ កើនឡើង ១,២០៩.២ ប៊ីលានរៀល ឬ ២៥.៥% ប្រៀបធៀបនឹងឆមាសទី១ ឆ្នាំ២០១៨។ បើគិតជាមធ្យម ចំណូលបង់ចូលរតនាគារជាតិប្រចាំខែ ក្នុងឆមាសទី១ ឆ្នាំ២០១៩ នេះមានប្រមាណ ៩៩០.៧ ប៊ីលានរៀល ក្នុង១ខែ

ក្រាហ្វិក ១ ÷ សមាសភាគចំណូលតាមក្រុមទំនិញ ឆមាសទី១ ឆ្នាំ២០១៩




ក្រាហ្វិក ២÷ ប្រៀបធៀបចំណូលតាមក្រុមទំនិញរវាងឆមាសទី១ ឆ្នាំ២០១៨ និងឆមាសទី១ ឆ្នាំ២០១៩



## ក្រាហ្វិក ៣÷ ប្រៀបធៀបចំណូលតាមប្រភេទពន្ធរវាងឆមាសទី១ ឆ្នាំ២០១៨ និងឆមាសទី១ ឆ្នាំ២០១៩




- ការនាំចេញ÷
    - ការនាំចេញផ្នែកវិនិយោគកាត់ដេរ និងមិនមែនកាត់ដេរ
        - ការនាំចេញផលិតផលកាត់ដេរក្នុងឆមាសទី១ ឆ្នាំ២០១៩ មានប្រមាណ ៣៦០.៤ ពាន់តោន ដែលមានតម្លៃសរុប ៤,៩៨៩.៦ លានដុល្លារអាមេរិក។ បើប្រៀបធៀបនឹងឆមាសទី១ ឆ្នាំ២០១៨ (៣៣៩.៩ ពាន់តោន) កើនឡើងប្រមាណ ៦% ឬ ២០.៥ ពាន់តោន។ ការកើនឡើងនេះគឺដោយសារការវិនិយោគមានការកើនឡើងជារៀងរាល់ឆ្នាំ
    - ផលិតផលផ្នែកវិនិយោគមិនមែនកាត់ដេរ រួមមាន÷
        - ការនាំចេញកង់មានប្រមាណ ៨៩២.១ ពាន់គ្រឿង ដែលមានតម្លៃសរុបប្រមាណ ១៨៦.៤ លានដុល្លារអាមេរិក។ បើប្រៀបធៀបនឹងឆមាសទី១ ឆ្នាំ២០១៨ (៩១៣.៣ ពាន់គ្រឿង) ថយចុះប្រមាណ ២.៣% ឬ ២១.២ ពាន់គ្រឿង។
        - ការនាំចេញគ្រឿងបំណែកអេឡិចត្រូនិក និងបង្គុំខ្សែភ្លើងមានប្រមាណ ១៣.២ ពាន់តោន ដែលមានតម្លៃសរុបប្រមាណ ២៤២ លានដុល្លាអាមេរិក។ បើប្រៀបធៀបនឹងឆមាសទី១ ឆ្នាំ២០១៨ (១១.៦ ពាន់តោន) កើនឡើងប្រមាណ ១៣.៤% ឬ ១.៦ ពាន់តោន
        - ចំពោះគ្រឿងបន្លាស់រថយន្តមានប្រមាណ ២.៣ ពាន់តោន ដែលមានតម្លៃសរុបប្រមាណ ៣៨.៦ លានដុល្លារអាមេរិក។ បើប្រៀបធៀបនឹងឆមាសទី១ ឆ្នាំ២០១៨ (១.៥ ពាន់តោន) កើនឡើងប្រមាណ ៥៦.២% ឬ ០.៨ ពាន់តោន។
    - ការនាំចេញស្រូវ អង្ករ កៅស៊ូ និងកសិផលផ្សេងទៀត
        - បរិមាណនាំចេញស្រូវមានសរុបចំនួន ៧៩៧.២ ពាន់តោន ដែលមានតម្លៃសរុប ១៥៤.៦ លានដុល្លារអាមេរិក។ បើប្រៀបធៀបនឹងឆមាសទី១ ឆ្នាំ២០១៨ (៨៤១.១ ពាន់តោន) ថយចុះប្រមាណ ៥.២% ឬ ៤៣.៩ ពាន់តោន។
        - បរិមាណនាំចេញអង្ករមានចំនួន ២៦៤.៥ ពាន់តោន ដែលមានតម្លៃសរុបប្រមាណ ១៩៤.៦ លានដុល្លារអាមេរិក។ បើប្រៀបធៀបនឹងឆមាសទី១ ឆ្នាំ២០១៨ (២៦៤.៣ ពាន់តោន) កើនឡើងប្រមាណ ០.១% ឬ ០.២ពាន់តោន។
        - កសិផលនាំចេញផ្សេងទៀត មានបរិមាណ ២,០១៥.៥ ពាន់តោន ដែលមានតម្លៃប្រមាណ ៣២៩ លានដុល្លារអាមេរិក។
        - (ពុំមានការប្រៀបធៀបនឹងឆមាសទី១ ឆ្នាំមុន ព្រោះកសិផលនាំចេញផ្សេងទៀតទើបចាប់ផ្តើមកត់ត្រាចាប់ពីខែមេសា ឆ្នាំ ២០១៨ មក)

- កៅស៊ូនាំចេញសរុបប្រមាណ ៦៣.៨ ពាន់តោន ដែលមានតម្លៃសរុបប្រមាណ ៨៦ លានដុល្លារអាមេរិក និងអាករនាំចេញប្រមាណ ៣.២ លានដុល្លារអាមេរិក។ បើប្រៀបធៀបនឹងឆមាសទី១ ឆ្នាំ២០១៨ (៦១.៧ ពាន់តោន) កើនឡើងប្រមាណ ៣.៣% ឬ ២.១ ពាន់តោន។

- ពន្ធអាករជាបន្ទុករដ្ឋ ÷ នៅក្នុងឆមាសទី១ ឆ្នាំ២០១៩ ពន្ធនិងអាករជាបន្ទុករដ្ឋមាន ៤ ៤.៦១៧,ប៊ីលានរៀល ឬប្រមាណ ១ ១.១៤០,លានដុល្លារអាមេរិក កើនឡើង ៧ ឬ %៨.៣៣៣ ៣.ប៊ីលានរៀល ប្រៀបធៀបឆមាសទី១ ឆ្នាំ២០១៨ ៤,២៨៤ ប៊ីលានរៀល ។ ក្នុងនោះ វិស័យវិនិយោគកាត់ដេរមានប្រមាណ ៥៦) %៧.២ ៦១៨.៤,ប៊ីលានរៀល (កើនឡើងប្រមាណ ២ ៣% ឬ.៥៩ ៦.ប៊ីលានរៀល ធៀបនឹងឆមាសទី១ ឆ្នាំ២០១៨។ វិស័យវិនិយោគមិនមែនកាត់ដេរមានប្រមាណ ៣២) %៥.១ ៤៩៩.៥,ប៊ីលានរៀល (កើនឡើងប្រមាណ ៣៧ ៦% ឬ.៤០៩ ៤.ប៊ីលានរៀល ប្រៀបធៀបនឹងឆមាសទី១ ឆ្នាំ២០១៨)

- ការបង្ក្រាបអំពើរត់ពន្ធ ÷ ក្នុងឆមាសទី១ ឆ្នាំ២០១៩ អគរ បង្ក្រាបបានបទល្មើសរត់ពន្ធចំនួន ៤២៦ ករណីធំ ៤,១៣៥ ករណីតូច និងប្រមូលប្រាក់ពន្ធអាករនិងពិន័យបន្ថែម ៣២.៩ ប៊ីលានរៀល។ ទំនិញល្មើសដែលបង្ក្រាបបានរួមមាន÷ប្រេងសាំង ៧,៥២១ លីត្រ, ប្រេងម៉ាស៊ូត ២៨,១៩២ លីត្រ, ប្រេងរំអិល ១៥,៣៤១ លីត្រ, រថយន្តចំនួន ២០៣ គ្រឿង, ទោចក្រយានយន្តចំនួន ២,៤២៨ គ្រឿង, ម៉ាស៊ីនត្រជាក់ថ្មី ២១៣ គ្រឿង, ទូរទឹកកកនិងទូរក្លាសេ ២៣ គ្រឿង ទូរស័ព្ទដៃថ្មីប្រភេទស្មាតហ្វូន ម៉ាក iPhone XS Max ចំនួន ២០៦ គ្រឿង iPad Mini និង iPad Pro ថ្មីចំនួន ៥៨ គ្រឿង នាឡិកាប្រភេទ Smart Watch ថ្មីម៉ាក Apple ចំនួន ៤០ គ្រឿង កាសប្រភេទ Airpod ថ្មីចំនួន ៣៥០ កំប្លេ ម៉ាស៊ីនភ្លើងចំនួន ០៤ គ្រឿង បារីម៉ាក Ligun ចំនួន ១,១៦៤កេស ទឹកក្រូច៧៨០ កេស ស្រាបៀរ ៣,២៧០ កេស ស្រាបរទេស ៧១៤ កេស ទឹកផ្លែឈើ ១,២៨៣ កេស ភេសជ្ជៈផ្សេងទៀតចំនួន ២២,៩២៧ កេស ខ្សែភ្លើងទម្ងន់ ២៥,០០០ គីឡូក្រាម គ្រឿងបន្លាស់រថយន្ត ១៧.២ តោន គ្រឿងឧបភោគបរិភោគចំនួន ២០៣.៥ តោន សម្ភារសំណង់ ១៨៤.៤ តោន ទំនិញផ្សេងៗ ១៨២.៨ តោន រូបិយប័ណ្ណបរទេស ប្រាក់ដុល្លារអាមេរិក ២,២០២,១០០ USD ប្រាក់យ៉េនជប៉ុន ៤,០៦៤,០៨៧ JPY និងប្រាក់យ័នចិន ១០២,៩៤៣ CNY។ ក្រៅពីនេះ បទល្មើសបានរកឃើញពីការស្កែនកុងតែន័រចូលមាន ៣៧ ទូរ ក្នុងចំណោមកុងតែន័រចូលស្កែនសរុប ១០៤,៥៧១ ដោយប្រមូលប្រាក់ពន្ធអាករបន្ថែម (មិនទាន់គិតពិន័យ) ចំនួន ២២៣,២៣០ ដុល្លារអាមេរិក។



នាវាល្បាតគយប្រតិបត្តិការគយជើងទឹក កំពុងប្រតិបត្តិការបង្ការនិងបង្ក្រាប ប្រឆាំងទប់ស្កាត់បទល្មើសគយតាមដែនសមុទ្រ នៃព្រះរាជាណាចក្រកម្ពុជា

- ការងារសវនកម្មគយ និងគ្រប់គ្រងហានិភ័យ
  - o បានពិនិត្យលើប្រតិវេទន៍គយនិងរកឃើញនូវភាពមិនប្រក្រតីចំនួន ០៣ ប្រតិវេទន៍ ប៉ះពាល់ដល់ប្រាក់ពន្ធនិងអាករចំនួន ១៩៨,៦២២,៥០០ រៀល
  - o បានកសាងកំណត់ហេតុល្មើសច្បាប់គយចំនួន ១០ ករណីនៃលទ្ធផលសវនកម្មក្រុមហ៊ុនក្រោយពេលបញ្ចេញទំនិញពីគយ ដែលប៉ះពាល់ប្រាក់ពន្ធអាករនិងពិន័យអនុគ្រោះសរុបចំនួន ១,២៤៦,៤២២,២០០ រៀល

o បានទទួលឯកសារក្រុមហ៊ុនថ្មីចំនួន ៤៣០ ក្រុមហ៊ុន ដើម្បីចុះឈ្មោះបញ្ជីក្នុងប្រព័ន្ធគ្រប់គ្រងហានិភ័យ និងបានសម្រួលដោះស្រាយជូនក្រុមហ៊ុនស្ថិតក្នុងបញ្ជីធុរជនមិនស្គាល់ចំនួន ២៧ ក្រុមហ៊ុន ឱ្យបញ្ចេញទិនិញជាបណ្តោះអាសន្ន។

❖ **វិស័យពន្ធដារនៅកម្ពុជា**

- ចំណូលពន្ធដារប្រមូលបាន ÷ ក្នុងខែមិថុនា ឆ្នាំ២០១៩ ចំណូលពន្ធ-អាករ ដែលអគ្គនាយកដ្ឋានពន្ធដារប្រមូលបាន (តាមប្រព័ន្ធគ្រប់គ្រងទិន្នន័យចំណូលអនឡាញ Online របស់អគ្គនាយកដ្ឋានពន្ធដារ ) មានចំនួន ៧៨៨,០៦ ប៊ីលានរៀល (ប្រមាណជា ១៩៧,០២ លានដុល្លារអាមេរិក) ស្មើនឹង ៨,៦១% នៃផែនការប្រចាំឆ្នាំ។ ប្រសិនបើប្រៀបធៀបនឹងចំណូលពន្ធ-អាករប្រចាំខែមិថុនា ឆ្នាំ២០១៨ ឃើញថាកើនឡើងចំនួន ២២៨,៧០ ប៊ីលានរៀល (ប្រមាណជា ៥៧,១៨ លានដុល្លារអាមេរិក) ស្មើនឹង ៤០,៨៩%។
- សម្រាប់រយៈពេល ០៦ ខែ ឆ្នាំ២០១៩ នេះ ចំណូលពន្ធ-អាករដែលអគ្គនាយកដ្ឋានពន្ធដារប្រមូលបាន (តាមប្រព័ន្ធគ្រប់គ្រងទិន្នន័យចំណូលអនឡាញ) មានចំនួន ៦ ១០៦,១៧ ប៊ីលានរៀល (ប្រមាណ ១ ៥២៦,៥៤ លានដុល្លារអាមេរិក) ស្មើនឹង ៦៦,៧១% នៃផែនការប្រចាំឆ្នាំ។ ប្រសិនបើប្រៀបធៀបនឹងរយៈពេលដូចគ្នានៃឆ្នាំ២០១៨ ឃើញថាចំណូលពន្ធ-អាករសម្រាប់រយៈពេល ០៦ ខែ ឆ្នាំ២០១៩ កើនឡើងចំនួន ១ ៣៧០,៣២ ប៊ីលានរៀល (ប្រមាណជា ៣៤២,៥៨ លានដុល្លារអាមេរិក) ស្មើនឹង ២៨,៩៤%។
- ក្នុងរយៈពេលដូចគ្នានេះឃើញថា មានការកើនឡើងផងដែរនូវរាល់ចំណូលពន្ធអាករទៅ-តាមប្រភេទពន្ធ និងតាមសកម្មភាពអាជីវកម្មសំខាន់ៗមួយចំនួន ដូចមានរៀបរាប់ក្នុងតារាងខាងក្រោម÷

**តារាងចំណូលតាមប្រភេទពន្ធគិតត្រឹមខែមិថុនា ឆ្នាំ២០១៩**

| ប្រភេទពន្ធសំខាន់ៗ | ០៦ខែ ឆ្នាំ២០១៨ | ០៦ខែ ឆ្នាំ២០១៩ | លំអៀង | | អត្រាកំណើន |
|---|---|---|---|---|---|
| | ឯកតា ÷ ប៊ីលានរៀល | | ប៊ីលានរៀល | លានដុល្លារ | |
| អាករលើតម្លៃបន្ថែម | ៩៧៥,៥១ | ១ ៣៣២,៧៩ | ៣៥៧,២៧ | ៨៩,៣១ | ៣៦,៦២% |
| ពន្ធលើប្រាក់ចំណូល | ១ ៧៣២,១៥ | ២ ១៩៩,៣២ | ៤៦៧,១៦ | ១១៦,៧៩ | ២៦,៩៧% |
| អាករពិសេស | ៥៤៤,៧៦ | ៦៧៨,៨៨ | ១៣៤,១២ | ៣៣,៥៣ | ២៤,៦២% |
| ពន្ធលើប្រាក់បៀវត្ស | ៣៤៤,៩៤ | ៣៨៧,០៧ | ៤២,១២ | ១០,៥៣ | ១២,២១% |
| ពន្ធប្រថាប់ត្រាលើអចលនទ្រព្យ | ២៥៧,៨៥ | ៣៩៣,១៩ | ១៣៥,៣៤ | ៣៣,៨៣ | ៥២,៤៨% |
| ពន្ធលើឈ្នួលផ្ទះនិងដី | ៨,៥៣ | ១៣,១៥ | ៤,៦២ | ១,១៥ | ៥៤,១៨% |

**តារាងកំណើនចំណូលពន្ធតាមសកម្មភាពអាជីវកម្មសំខាន់ៗគិតត្រឹមខែមិថុនា ឆ្នាំ២០១៩**

*(តាមប្រព័ន្ធគ្រប់គ្រងទិន្នន័យចំណូលអនឡាញ Online របស់អគ្គនាយកដ្ឋានពន្ធដារ)*

| សកម្មភាពអាជីវកម្ម | ០៦ខែ ឆ្នាំ ២០១៨ | ០៦ខែ ឆ្នាំ២០១៩ | លំអៀង | | អត្រាកំណើន ឬ ថយចុះ |
|---|---|---|---|---|---|
| | ឯកតា ÷ ប៊ីលានរៀល | | ប៊ីលានរៀល | លានដុល្លារ | |
| អាហារដ្ឋានីហារ៉ែណ | ៤៨២,៤៧ | ៦២៩,៩៩ | ១៤៧,៥១ | ៣៦,៨៧ | ៣០,៥៧% |
| សេវាហិរញ្ញវត្ថុ | ៩៥៦,៣៤ | ១ ១៣១,៥២ | ១៧៥,១៧ | ៤៣,៧៩ | ១៨,៣២% |

| | | | | | |
|---|---|---|---|---|---|
| អាជីវកម្មអចលនទ្រព្យ | ២៤៣,៤៧ | ៣៧៦,៤៤ | ១៣២,៩៧ | ៣៣,២៤ | ៥៤,៦២% |
| ស្ថាបត្យកម្មនិងសំណង់ | ២១០,០២ | ៣៤៨,០៤ | ១៣៨,០២ | ៣៤,៥០ | ៦៥,៧២% |
| ទូរគមនាគមន៍ | ២០៥,៦៥ | ២៥៣,០១ | ៤៧,៣៥ | ១១,៨៣ | ២៣,០៣% |
| សណ្ឋាគារ និងភោជនីយដ្ឋាន | ១៣៣,០១ | ១៦០,៦៤ | ២៧,៦៣ | ៦,៩០ | ២០,៧៧% |
| ផលិតភេសជ្ជៈ | ៧៦៣,០៥ | ៩៤៥,០៩ | ១៨២,០៤ | ៤៥,៥១ | ២៣,៨៦% |
| ផលិតយានយន្ត | ២០,២៩ | ២៤,៤១ | ៤,១១ | ១,០២ | ២០,២៩% |
| ផលិតសម្លៀកបំពាក់ | ១១៦,៦៧ | ១២៧,៥៦ | ១០,៨៩ | ២,៧២ | ៩,៣៤% |
| ដឹកជញ្ជូន និងទេសចរណ៍ | ១០៦,៦១ | ១១៦,១២ | ៩,៥១ | ២,៣៧ | ៨,៩២% |
| ផលិតថ្នាំជក់ | ៦៥,៨៨ | ៧០,៩២ | ៥,០៨ | ១,២៥ | ៧,៦៥% |
| កសិកម្ម | ៣៣,០០ | ៤១,៥៧ | ៨,៥៦ | ២,១៤ | ២៥,៩៧% |
| សេវាសិក្សាអប់រំ | ២៦,៣៩ | ២៨,៣៨ | ១,៩៩ | ០,៤៩ | ៧,៥៦% |
| លក់គ្រឿងឧបភោគបរិភោគ | ១៨,៦៩ | ៣៦,៤២ | ១៧,៧៣ | ៤,៤៣ | ៩៤,៨៨% |
| អាកាសយានដ្ឋាននិងកំពង់ផែ | ២០,៥៥ | ២៧,៩៣ | ៧,៣៨ | ១,៨៤ | ៣៥,៩២% |
| លក់គ្រឿងសំណង់ | ១៣,៩៧ | ១៤,៨៨ | ០,៩១ | ០,២២ | ៦,៥២% |
| លក់ភេសជ្ជៈ និងថ្នាំជក់ | ៩,៣៥ | ១០,៦៣ | ១,២៨ | ០,៣២ | ១៣,៧០% |
| លក់ផលិតផលតេលសិលា | ៦,៥៨ | ៨,០១ | ១,៤៣ | ០,៣៥ | ២១,៧៣% |

- លទ្ធផលចំណូលពន្ធតាមប្រភេទអ្នកជាប់ពន្ធ÷ សម្រាប់រយៈពេល ០៦ ខែ ឆ្នាំ២០១៩ នេះ ចំណូលពន្ធ-អាករគ្រប់ប្រភេទ ដែលប្រមូលតាមប្រព័ន្ធគ្រប់គ្រងទិន្នន័យចំណូលអនឡាញ Online របស់អគ្គនាយកដ្ឋានពន្ធដារ ត្រូវបានបែងចែកតាមប្រភេទ អ្នកជាប់ពន្ធ ដូចខាងក្រោម÷
  - o អ្នកជាប់ពន្ធធំ ចំនួន ៤ ៧៩៧,៦១ ប៊ីលានរៀល (១ ១៩៤,៤០ លានដុល្លារ) ស្មើនឹង ៧៨,៥៧%
  - o អ្នកជាប់ពន្ធមធ្យម ចំនួន ៧៧៩,៥៣ ប៊ីលានរៀល (១៩៤,៨៨ លានដុល្លារ) ស្មើនឹង ១២,៧៧%
  - o អ្នកជាប់ពន្ធតូច ចំនួន ៣៦,៨៤ ប៊ីលានរៀល (៩,២១ លានដុល្លារ) ស្មើនឹង ០,៦០%
  - o ផ្សេងៗ (ពន្ធលើឈ្នួលផ្ទះ ពន្ធលើអចលនទ្រព្យ និងពន្ធផ្សេងៗ) ចំនួន ៤៩២,១៦ ប៊ីលានរៀល (១២៣,០៤ លានដុល្លារ) ស្មើនឹង ៨,០៦%
- លទ្ធផលនៃការចុះបញ្ជីពន្ធដារ ÷ សម្រាប់ខែមិថុនា ឆ្នាំ២០១៩ មានសំណុំឯកសារស្នើសុំចុះបញ្ជីពន្ធដារ និងធ្វើបច្ចុប្បន្នភាពព័ត៌មានសហគ្រាស កំពុងដំណើរការក្នុងខែមានចំនួន ៥ ៩៩៨ សហគ្រាស ដែលក្នុងនោះបានទទួលពាក្យស្នើសុំចុះបញ្ជី និងធ្វើបច្ចុប្បន្នភាពមានចំនួន ១ ៥២២ សហគ្រាស និងសល់យោងគ្រាមុនមានចំនួន ៤ ៤៧៦ សហគ្រាស។ ជាលទ្ធផល សំណុំឯកសារដែលសម្រេចអនុញ្ញាតឱ្យចុះបញ្ជីពន្ធដារ និងធ្វើបច្ចុប្បន្នភាពព័ត៌មាន ចំនួន ១ ៩៨៣ សហគ្រាស ក្នុងនោះ÷
  - o សហគ្រាសចុះបញ្ជីថ្មី ចំនួន ១ ៩០៧ សហគ្រាស (ពន្ធធំ: ១១៩ពន្ធមធ្យម ,: ៧៨៧ និងពន្ធតូច: ១ ០០១)
  - o សហគ្រាសធ្វើបច្ចុប្បន្នភាព ចំនួន ៧៦ សហគ្រាស (ពន្ធធំ: ២៩ និងពន្ធមធ្យម: ៤៧)

- o សម្រេចផ្ដល់លិខិតបញ្ជាក់សាខាជូនសហគ្រាសបានចំនួន ៩៦ សាខាឃ្លាំង និងកែប្រែទិន្នន័យផ្សេងៗជូនសហគ្រាស-បានចំនួន ៦៣៩ ករណី ផងដែរ
- o សម្រាប់រយៈពេល ០៦ ខែ ឆ្នាំ២០១៩ នេះ មានសំណុំឯកសារស្នើសុំចុះបញ្ជីពន្ធដារ និងធ្វើបច្ចុប្បន្នភាពព័ត៌មានសហគ្រាស កំពុងដំណើរការក្នុងខែមានចំនួន ១០ ៣៨៣ សហគ្រាស ដែលក្នុងនោះបានទទួលពាក្យស្នើសុំចុះបញ្ជីនិងធ្វើបច្ចុប្បន្នភាពមានចំនួន ៦ ៩១៥ សហគ្រាស និងសល់យោងគ្រាមុនមានចំនួន ៣ ៤៦៨ សហគ្រាស។ ជាលទ្ធផលសម្រាប់រយៈពេល ០៦ ខែ ឆ្នាំ២០១៩ នេះ សំណុំឯកសារដែលសម្រេចអនុញ្ញាតឱ្យចុះបញ្ជីពន្ធដារ និងធ្វើបច្ចុប្បន្នភាពព័ត៌មាន ចំនួន ៦ ៣៦៨ សហគ្រាស ក្នុងនោះ÷
- o សហគ្រាសចុះបញ្ជីថ្មី ចំនួន ៦ ១៨៧ សហគ្រាស (ពន្ធធំ: ៥១៩ពន្ធមធ្យម ,: ២ ៩៨៧ និងពន្ធតូច: ២ ៦៨១)
- o សហគ្រាសធ្វើបច្ចុប្បន្នភាព ចំនួន ១៨១ សហគ្រាស (ពន្ធធំ: ៤៤ និងពន្ធមធ្យម: ១៣៧)
- o សម្រេចផ្ដល់លិខិតបញ្ជាក់សាខាជូនសហគ្រាសបានចំនួន ៣៦០ សាខាឃ្លាំង និងកែប្រែទិន្នន័យផ្សេងៗជូនសហ-គ្រាសបានចំនួន ២ ០៨២ ករណី ផងដែរ។ បានបដិសេធការស្នើសុំចុះបញ្ជីចំនួន ១ សហគ្រាស ដូចនេះ សំណុំឯកសារនៅសល់ចុងគ្រាមានចំនួន ៤ ០១៥ សហគ្រាស (ពន្ធធំ: ៨១ , ពន្ធមធ្យម: ២ ២៦៨ និងពន្ធតូច: ១ ៦៦៥) ។

- លទ្ធផលការងារផ្នែកសវនកម្ម ÷ សម្រាប់រយៈពេល ០៦ ខែ ឆ្នាំ២០១៩ នេះ អគ្គនាយកដ្ឋានពន្ធដារបានធ្វើសវនកម្មគ្រប់ប្រភេទលើសហគ្រាសសរុបបានចំនួន ២ ៩៣៣ ករណី មានប្រាក់ពន្ធចំនួន ២ ៧៨៨,៨០ ប៊ីលានរៀល (ប្រមាណជា ៦៩៧,២០ លានដុល្លារ)។ ប្រសិនបើប្រៀបធៀបនឹងរយៈពេលដូចគ្នា ឆ្នាំ២០១៨ ឃើញថាការធ្វើសវនកម្មសម្រាប់ឆ្នាំ២០១៩ គឺមានការកើនឡើងចំនួន ៤៦៥ ករណី (ស្មើនឹង ១៩.៦០%) និងមានប្រាក់ពន្ធកើនឡើង ចំនួន ៨៧៤,៣០ ប៊ីលានរៀល (ប្រមាណ ២១៨,៦០ លានដុល្លារ) ស្មើនឹង ៤៥,៧០%។
- លទ្ធផលការងារគ្រប់គ្រងប្រមូលបំណុលពន្ធ ÷ ក្នុងខែមិថុនា ឆ្នាំ២០១៩ អគ្គនាយកដ្ឋានពន្ធដារបានប្រមូលបំណុលពន្ធចំនួន ១៨២ សហគ្រាស សរុបចំនួន ៦២,០៩ ប៊ីលានរៀល (ប្រមាណជា ១៥,៥២ លានដុល្លារ)។ សម្រាប់រយៈពេល ០៦ ខែ ឆ្នាំ២០១៩ នេះ បំណុលពន្ធដែលអគ្គនាយកដ្ឋានពន្ធដារប្រមូលបានមានចំនួន ៤០៨,៦១ ប៊ីលានរៀល (ប្រមាណជា ១០២,១៥ លានដុល្លារ) បើប្រៀបធៀបរយៈពេលដូចគ្នាក្នុងឆ្នាំ២០១៨ មានការកើនឡើងចំនួន ២៣១,៩២ ប៊ីលានរៀល (ប្រមាណជា ៥៧,៩៨ លានដុល្លារ) ស្មើនឹង ១៣១,៣០%។
- លទ្ធផលការងារដោះស្រាយវិវាទ ÷ ក្នុងខែមិថុនា ឆ្នាំ២០១៩ បានដោះស្រាយសំណុំឯកសារបណ្ដឹងតវ៉ាចំនួន ៦ ករណី មានប្រាក់ពន្ធសរុប ៥០៩,៥៥ លានរៀល បើប្រៀបធៀបនឹងខែមិថុនា ឆ្នាំ២០១៨ គឺមានការកើឡើងចំនួន ០២ ករណី និងប្រាក់ពន្ធកើនឡើងចំនួន ១៥៧,៧៦ លានរៀល។ សម្រាប់រយៈពេល ០៦ ខែ ឆ្នាំ២០១៩ នេះ បានដោះស្រាយសំណុំឯកសារបណ្ដឹងតវ៉ាចំនួន ៣៧ ករណី មានប្រាក់ពន្ធសរុប ៤ ៤២១,៥៨ លានរៀល បើប្រៀបធៀបនឹងរយៈពេលដូចគ្នាក្នុងឆ្នាំ២០១៨ គឺថយចុះចំនួន ០១ ករណី ប៉ុន្តែប្រាក់ពន្ធកើនចំនួន ១ ១៩១,៥០ លានរៀល (ប្រមាណជា ០,២៩ លានដុល្លារ)។
- សម្រាប់រយៈពេល ០៦ ខែ ឆ្នាំ២០១៩ នេះ សហគ្រាសស្នើសុំបិទតម្រូវឱ្យធ្វើសវនកម្មមានសរុបចំនួន ២ ៧១០ សហគ្រាស ក្នុងនោះបានសម្រេចចុះធ្វើសវនកម្មបិទរួចរាល់ចំនួន ៥១៥ សហគ្រាស (ស្មើនិង ១៩%) និងកំពុងដំណើរការមានចំនួន ២ ១៩៥ សហគ្រាស ដែលក្នុងចំណោមនោះកំពុងរង់ចាំទិន្នន័យពីអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជាចំនួន ២ ០០៨ សហគ្រាស ។

**២.១.២. ការប្រមូលចំណូលមិនមែនសារពើពន្ធ និងទ្រព្យសម្បត្តិរដ្ឋ**

- សេចក្ដីព្រាងច្បាប់ស្ដីពីការគ្រប់គ្រង ការប្រើប្រាស់ និងការចាត់ចែងទ្រព្យសម្បត្តិរដ្ឋ ត្រូវបានបញ្ជូនទៅទីស្ដីការគណៈរដ្ឋមន្ត្រីដើម្បីបន្តនីតិវិធី

- ការគ្រប់គ្រងទ្រព្យសម្បត្តិឯកជនរបស់រដ្ឋ÷
  - o រៀបចំនីតិវិធី នៃការគ្រប់គ្រង និងការប្រើប្រាស់ថវិកាចំណូលពីការអនុវត្តកាតព្វកិច្ច កិច្ចសន្យារបស់ភាគីជួលទីតាំង អចលនទ្រព្យរបស់រដ្ឋ
  - o បានចូលរួមប្រជុំពិនិត្យសិក្សា និងវាយតម្លៃលើករណីបន្តកិច្ចសន្យាជួលទីតាំងសហគ្រាសរូបថត SPK
  - o បានចុះបេសកកម្មទៅខេត្តកំពង់ឆ្នាំង ដើម្បីចុះពិនិត្យសិក្សា និងវាយតម្លៃដោះដូរទីតាំងពន្ធធនាគារខេត្តកំពង់ឆ្នាំង

- ការគ្រប់គ្រងទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ ÷
  - o បានចូលរួមចុះពិនិត្យ និងវាយតម្លៃគម្រោងវិនិយោគសាងសង់សត្តឃាតដ្ឋាននៅខេត្តព្រះវិហារ
  - o បានចូលរួមចុះពិនិត្យ និងវាយតម្លៃគម្រោងស្នើសុំវិនិយោគសត្តឃាតដ្ឋាននៅខេត្តតាកែវ
  - o បានចូលរួមចុះពិនិត្យ និងវាយតម្លៃគម្រោងស្នើសុំដាក់ទុនវិនិយោគសាងសង់ផ្សារមួយ កន្លែងមានទីតាំងស្ថិតនៅខេត្តព្រៃវែង
  - o បានចូលរួមចុះពិនិត្យ និងវាយតម្លៃសំណើស្នើសុំធ្វើអាជីវកម្មចំណតរថយន្ត ការលើកដាក់ទំនិញ និង អនុវត្តគម្រោងវិនិយោគនៅច្រកទ្វារតំបន់ព្រំដែនស្វាយអាង៉ោង ស្ថិតនៅខេត្តព្រៃវែង
  - o បានចូលរួមចុះពិនិត្យ និងប្រគល់ទទួលសំណង់វិនិយោគផ្សារលើតាមលក្ខខណ្ឌនៃកិច្ចសន្យានៅខេត្តព្រះសីហនុ
  - o បានចុះពិនិត្យ និងវាយតម្លៃគម្រោងដាក់ទុនវិនិយោគលើទីតាំងផ្សាររាត្រី ដែលស្ថិតនៅក្នុងខេត្តកែប
  - o ចុះពិនិត្យ និងវាយតម្លៃគម្រោងដាក់ទុនវិនិយោគដើម្បីសាងសង់ ជួសជុល កែលំអរ ចំណតរថយន្តក្រុង ខេត្តក្រចេះ
  - o ចូលរួមចុះពិនិត្យ និងវាយតម្លៃលើគម្រោងស្នើសុំបន្តកិច្ចសន្យាម៉ៅការធ្វើអាជីវកម្ម-សេវាកម្ម បង្គន់ និងទឹក ផ្សារចាស់ និងផ្សារកណ្តាល រាជធានីភ្នំពេញ
  - o បានបេសកកម្មចុះចូលរួមពិនិត្យការអនុវត្តកិច្ចសន្យា និងសៀវភៅបន្ទុករបស់ចំណតរថយន្តស្រុករតនមណ្ឌល និងសត្តឃាតដ្ឋាន នៅខេត្តបាត់ដំបង
  - o បានបេសកកម្មចុះពិនិត្យ និងវាយតម្លៃលើគម្រោងវិនិយោគ និងធ្វើអាជីវកម្មកំពង់ចម្លង ក្នុងភូមិសាស្រ្តខេត្តកណ្តាល
  - o បានចុះពិនិត្យការអនុវត្តកិច្ចសន្យាវិនិយោគសាងសង់ផ្សារថ្មីមួយកន្លែង ស្ថិតនៅខេត្តកំពង់ឆ្នាំង
  - o ចុះត្រួតពិនិត្យ និងវាយតម្លៃសំណង់ និងហេដ្ឋានរចនាសម្ព័ន្ធវិនិយោគចំណតរថយន្តដឹកអ្នកដំណើរ និងផ្ទេរទំនិញចូល និងចេញ នៅខេត្តត្បូងឃ្មុំ
  - o ចូលរួមចុះពិនិត្យ ប្រគល់-ទទួលទីតាំង និងសំណង់ចំណតរថយន្ត ក្នុងខេត្តស្ទឹងត្រែង
- ការគ្រប់គ្រងចំណូលធនធានធម្មជាតិ
  - o បានចុះត្រួតពិនិត្យការប្រើប្រាស់ធនធានរ៉ែសំណង់នៅតាមគម្រោងសំណង់បុរី និងគម្រោងវិនិយោគ នានាក្នុងរាជធានីភ្នំពេញ ខេត្តកំពត ខេត្តកែប ខេត្តព្រះសីហនុ ខេត្តកោះកុង
  - o បន្តចុះប្រមូលព័ត៌មាន ឯកសារ និងទិន្នន័យនានាអំពីការប្រើប្រាស់រ៉ែសំណង់សម្រាប់ការចាក់បំពេញការដ្ឋាន សំណង់បុរី ការដ្ឋានសំណង់នានា និងធ្វើការត្រួតពិនិត្យផ្ទៀងផ្ទាត់ជាមួយប្រកាស និងការបង់ប្រាក់ថ្លៃសួយសាររ៉ែសំណង់ដោយអ្នកផ្គត់ផ្គង់រ៉ែសំណង់

- ការគ្រប់គ្រងចំណូលសាធារណៈ ÷

- o បានបើកផ្តល់បង្កាន់ដៃបង់ប្រាក់សរុបចំនួន ១៥២ ៨៧៦ ក្បាល ក្នុងនោះសម្រាប់ការប្រើប្រាស់ប្រមូលចំណូលនៅរដ្ឋបាលថ្នាក់ជាតិចំនួន ១៣៥ ០៤២ ក្បាល និងរដ្ឋបាលថ្នាក់ក្រោមជាតិចំនួន ១៧ ៨៣៤ ក្បាល
  - o បានបើកផ្តល់ទិដ្ឋាការស្អិតសរុបចំនួន ១ ៦០២ ៩០០ សន្លឹក ក្នុងនោះជូនក្រសួងមហាផ្ទៃ ចំនួន ១ ៣០៧ ៩០០ សន្លឹក និងក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិចំនួន ២៩៥ ០០០ សន្លឹក
  - o បានចុះបំពេញបេសកកម្មនៅទៅក្រុងហុងកុង ប្រទេសចិន ដើម្បីសិក្សាស្វែងយល់ពីការគ្រប់គ្រងលេខពិសេសផ្ទាល់ខ្លួនសម្រាប់ការចុះបញ្ជីរថយន្ត
  - o រៀបចំរបាយការណ៍ស្តីពីការរៀបចំអភិរក្ស ថែទាំជួសជុលអគារចាស់របស់សាលាខេត្តបាត់ដំបង ឱ្យក្លាយជាសារមន្ទីរប្រវត្តិសាស្ត្រខេត្តបាត់ដំបង
  - o បន្តចូលរួមប្រជុំពិភាក្សាជាមួយក្រសួងមហាផ្ទៃ និងតំណាងក្រសួង ស្ថាប័នពាក់ព័ន្ធ លើការប្រមូលចំណូលពីភ្ញៀវទេសចរណ៍បរទេស មានចំនួន ៣ សេវាថ្មី គឺការផ្តល់បណ្ណត្រួតពិនិត្យជនបរទេស ការផ្តល់បណ្ណស្នាក់នៅអចិន្ត្រៃយ៍ និងសេវាបញ្ចូលទិន្នន័យជនបរទេសស្នាក់នៅតាមសណ្ឋាគារ និងផ្ទះសំណាក់
  - o បានចូលរួមកិច្ចប្រជុំពិភាក្សាលទ្ធភាព នៃការបង្កើនធនធានថវិការដ្ឋទៅឱ្យមូលនិធិឃុំ សង្កាត់ ចាប់ពីឆ្នាំ២០២០ សម្រាប់ចំណាយអភិវឌ្ឍន៍មូលដ្ឋាន ការបង្កើតការិយាល័យចំណុះ និងមុខងាររបស់រដ្ឋបាលក្រុង ស្រុក និងការគ្រប់គ្រងនិងការបែងចែកចំណូលកម្រៃសេវារដ្ឋបាលនៃអង្គភាពច្រកចេញចូលតែមួយរាជធានី ខេត្ត
  - o បានរៀបចំរបាយការណ៍សង្ខេបលើការប្រមូលចំណូលពីការផ្តល់អាជ្ញាបណ្ណវិទ្យុទាក់ទង របស់ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍
- ការរៀបចំបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ ÷
  - o បន្តទទួលបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ (តារាងប្រៀបធៀបទ្រព្យសម្បត្តិរដ្ឋកើនឡើង-ថយចុះ) ឆ្នាំ២០១៥, ឆ្នាំ២០១៦ និងឆ្នាំ២០១៧
  - o បានចូលរួមធ្វើការត្រួតពិនិត្យ ផ្ទៀងផ្ទាត់តារាងប្រៀបធៀបកើនឡើង និងថយចុះទ្រព្យសម្បត្តិរដ្ឋប្រចាំឆ្នាំ២០១៨ បានចំនួន ២៥ រាជធានី-ខេត្ត និងនៅក្រសួងរ៉ែ និងថាមពល
  - o បានចូលរួមកំណត់តម្លៃ០៤ប្រភេទទៅលើទ្រព្យសម្បត្តិរដ្ឋបានចំនួន ២៥ រាជធានី-ខេត្ត និងនៅក្រសួងរ៉ែ និងថាមពល
  - o បានបញ្ចប់ការចុះពិនិត្យផ្ទៀងផ្ទាត់តារាងប្រៀបធៀបកើនឡើង និងថយចុះទ្រព្យសម្បត្តិរដ្ឋប្រចាំឆ្នាំ២០១៨ ជាស្ថាពរ ដែលក្នុងនោះរួមមានការកំណត់តម្លៃទ្រព្យសម្បត្តិរដ្ឋទាំង ០៤ប្រភេទ និងជំរុញការរៀបចំធ្វើវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុ ព្រមទាំងធ្វើស្ថិតិអង្គភាពប្រើប្រាស់
- ការគ្រប់គ្រងសហគ្រាសសាធារណៈ
  - o បន្តចូលរួមជាមួយក្រុមការងារអន្តរក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និង ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ ចុះត្រួតពិនិត្យ ចំណូល និងផ្ទៀងផ្ទាត់បំណុលនៅតាមបណ្តាក្រុមហ៊ុនបម្រើសេវាអ៊ីនធើណេតនានា ដើម្បីជំរុញទារបំណុលដែលបណ្តាក្រុមហ៊ុនទាំងនោះនៅជំពាក់ឱ្យបង់ចូលថវិការដ្ឋ
  - o បានបញ្ចប់ការចូលរួមធ្វើការកំណត់ទុនគ្រាដំបូងរបស់សាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ,មជ្ឈមណ្ឌលជាតិពិសោធន៍សុខាភិបាល
  - o បានចូលរួមធ្វើការកំណត់ទុនគ្រាដំបូងមូលនិធិជនពិការ បេឡាជាតិអតីតយុទ្ធជន គ្រឹះស្ថានអង្គរ បានបញ្ចប់កម្រិតក្រុមការងារនិងបន្តសុំការសម្រេចពីថ្នាក់ដឹកនាំ

- o បន្តចូលរួមធ្វើការកំណត់ទុនគ្រាដំបូងរបស់មន្ទីរពិសោធន៍សំណង់សាធារណការ, អាជ្ញាធរជាតិអប្សរា, អាជ្ញាធរសំបូរព្រៃគុក, ,អាជ្ញាធរជាតិព្រះវិហារ

- ការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធតាមរយៈបច្ចេកវិទ្យាព័ត៌មាន
  - ត្រួតពិនិត្យ តាមដានការស្នើសុំ និងបានអនុម័តលេខកូដចំណូលមិនមែនសារពើពន្ធចំនួន ១២ កូដ (ចំណូលពីការជួលដី និងអគារ ០៧ កូដ និងចំណូលផ្សេងៗ ៥ កូដ) តាមរយៈប្រព័ន្ធ NRMIS ជូនក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងក្រសួងទេសចរណ៍
  - ត្រួតពិនិត្យ តាមដានការស្នើសុំ និងអនុម័តលេខកូដចំណូលមិនមែនសារពើពន្ធចំនួន ៨០ លេខកូដ (ចំណូលពីការជួលដី និងអគារ ០១កូដ, ចំណូលពីកាតព្វកិច្ចឆ្នោត ២១កូដ, ចំណូលកាតព្វកិច្ចកាស៊ីណូ ៥៤កូដ និងចំណូលផ្សេងៗ ៤កូដ តាមរយៈប្រព័ន្ធ NRMIS ជូនក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (អគ្គនាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុ), ក្រសួងអប់រំ យុវជន និងកីឡា, ក្រសួងការបរទេសនិងសហប្រតិបត្តិការ, ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ និងក្រសួងសាធារណការ និងដឹកជញ្ជូន
  - បានរៀបចំប្រជុំក្រុមការងារ ក.ម.ព អំពីដំណើរការបង់ចំណូលតាមរយៈ E-Payment ក្នុងប្រព័ន្ធគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ NMRIS
  - បានចូលរួមប្រជុំក្រុមការងារ ក.ម.ព ជាមួយនិងធនាគារជាតិ នៃកម្ពុជា, ធនាគារអេស៊ីលីដា, ធានាគារកាណាឌីយ៉ា និងធនាគារ ABA ស្តីពីការរៀបចំការបង់ប្រាក់តាម E-Payment នៅក្នុងប្រព័ន្ធ NRMIS
  - កំពុងរៀបចំប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន សម្រាប់រៀបចំតារាងចំណូល (ច្បាប់ទូទាត់ថវិកា)
  - បានបញ្ចប់ការរៀបចំ Database សម្រាប់ការអភិវឌ្ឍន៍ប្រព័ន្ធគ្រប់គ្រងកាលវិភាគ
  - បានបញ្ចប់ការរៀបចំ Database និងការអភិវឌ្ឍន៍មុខងារគ្រប់គ្រងឯកសារចេញ-ចូលនៃប្រព័ន្ធរដ្ឋបាលឆ្លាតវៃ
  - បានបញ្ចប់រចនាទម្រង់របស់ប្រព័ន្ធគ្រប់គ្រងកាលវិភាគ និងបញ្ចូលក្នុងទម្រង់របស់ប្រព័ន្ធទាំងមូល (Integration)
  - បន្តរៀបចំអភិវឌ្ឍន៍ Coding និងការធ្វើតេស្តផ្សេងៗផងដែរសម្រាប់ការអភិវឌ្ឍប្រព័ន្ធគ្រប់គ្រងកាលវិភាគប្រជុំ ដែលជាផ្នែកមួយនៃប្រព័ន្ធរដ្ឋបាលឆ្លាតវៃ (Smart Administration System)
  - បន្តស្រាវជ្រាវ និង កែលម្អប្រព័ន្ធ NRMIS ដើម្បីឱ្យមានលក្ខណៈកាន់តែទំនើប ដំណើរការកាន់តែលឿន និងងាយស្រួលប្រើប្រាស់ (User Friendly)
  - បន្តសម្របសម្រួលការងារគាំទ្រ ក្រសួងទាំង ២៣ ដែលប្រើប្រាស់ប្រព័ន្ធ NRMIS ជាផ្លូវការ
  - បានចូលរួមកិច្ចប្រជុំ ស្តីពីការពិនិត្យលទ្ធភាពក្នុងការបង្កើនការផ្ទេរធនធានពីថវិការដ្ឋ លើផ្នែកចំណូលមិនមែនសារពើពន្ធទៅឱ្យថ្នាក់ក្រោមជាតិចាប់ពីឆ្នាំ២០២០
  - បានចុះសិក្សាស្វែងយល់អំពីនីតិវិធីនៃការប្រមូល និងកត់ត្រាចំណូលមិនមែនសារពើពន្ធ នៅខេត្តកំពង់ស្ពឺ, ខេត្តកែប, ខេត្តកំពត និងខេត្តកំពង់ឆ្នាំង។

## ២.២. ការបង្កើនប្រសិទ្ធភាព និងភាពស័ក្តិសិទ្ធិនៃការគ្រប់គ្រងចំណាយសាធារណៈ

ផ្នែកនេះ ត្រូវបានអនុវត្តដោយអគ្គនាយកដ្ឋានថវិកា និងអគ្គនាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ និងគ្រប់គ្រងបំណុល អគ្គនាយកដ្ឋានរតនាគារជាតិ អគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ និងអគ្គនាយកដ្ឋានហិរញ្ញវត្ថុថ្នាក់ក្រោមជាតិ។ អគ្គនាយកដ្ឋានថវិកាមានបេសកម្មក្នុងការគ្រប់គ្រងថវិកាជាតិហិរញ្ញប្បទានសហប្រតិបត្តិការ និងបំណុលរដ្ឋក្នុងគោលដៅធានាឱ្យមានការបែងចែកនិងធនធានថវិការដ្ឋប្រកបដោយប្រសិទ្ធភាព ស័ក្តសិទ្ធិភាព និងចីរភាព[៦]។ រីឯ អគ្គនាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ និងគ្រប់

[6] មាត្រា ១៨ នៃអនុក្រឹត្យលេខ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

គ្រងបំណុល បំពេញបេសកកម្មសំខាន់ លើការគ្រប់គ្រងហិរញ្ញប្បទានសហប្រតិបត្តិការ និងបំណុលរដ្ឋ ប្រកបដោយប្រសិទ្ធភាព ស័ក្តិសិទ្ធិភាព និងចីរភាព[7]។ អគ្គនាយកដ្ឋានរតនាគារជាតិ មានបេសកកម្មសំខាន់លើ ១. ជាបេឡាករ និងគណនេយ្យករសាធារណៈរបស់រាជរដ្ឋាភិបាល ២.គ្រប់គ្រងប្រាក់កាក់របស់រដ្ឋ និងគណនីពិសេសរបស់រតនាគារ ៣. រៀបចំគោលការណ៍និងបទបញ្ញាគណនេយ្យសាធារណៈ ៤.កាន់កាប់ និងតាមដានការអនុវត្តគណនេយ្យទូទៅ និងមជ្ឈការគណនី ៥.ធានាតុល្យភាពទូទៅនៃគណនី ៦. តម្រង់ទិសនិងតាមដានការអនុវត្តគោលនយោបាយហិរញ្ញវត្ថុ និងបំណុលសាធារណៈ ៧.សហការជាមួយធានាគារជាតិនៃកម្ពុជា ក្នុងការអនុវត្តគោលនយោបាយរូបិយវត្ថុ ៨.កសាងសេចក្តីព្រាងច្បាប់សម្រាប់ទូទាត់ថវិកាប្រចាំឆ្នាំ[8]។ អគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈមានបេសកកម្មសំខាន់ លើការគ្រប់គ្រងលទ្ធកម្មសាធារណៈ នៅក្នុងព្រះរាជាណាចក្រកម្ពុជា។ សម្រាប់អគ្គនាយកដ្ឋានហិរញ្ញវត្ថុថ្នាក់ក្រោមជាតិ បំពេញបេសកកម្មលើការគ្រប់គ្រង និងការវិភាជន៍ថវិកាថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិក្នុងប្រទេសកម្ពុជា។ អង្គភាពភាពជាដៃគូរវាងរដ្ឋនិងឯកជនក៏ត្រូវបានអនុវត្តក្នុងផ្នែកនេះផងដែរ។ អង្គភាពនេះ ជម្រុញ សម្របសម្រួល និងគ្រប់គ្រងគម្រោង តាមយន្តការភាពជាដៃគូរវាងរដ្ឋនិងឯកជន។ ជាលទ្ធផលអគ្គនាយកដ្ឋាន និងអង្គភាព បានអនុវត្ត និងទទួលបានវឌ្ឍនភាពគួរឱ្យកត់សម្គាល់ដូចខាងក្រោម÷

### ២.២.១. ការគ្រប់គ្រង និងការអនុវត្តថវិកា

- ការរៀបចំថវិកា



ពិធីបើកវគ្គបណ្តុះបណ្តាលស្តីពី “សារាចរណែនាំស្តីពីការអនុវត្តច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០១៩ និង នីតិវិធីអនុវត្តថវិការបស់គ្រឹះស្ថានសាធារណៈរដ្ឋបាល” នៅថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០១៩

  - o បានរៀបចំផ្សព្វផ្សាយសារាចរណែនាំសម្រាប់អនុវត្តថវិកាឆ្នាំ ២០១៩ ដល់ក្រសួង ស្ថាប័ន និងមន្ទីរជំនាញរាជធានី ខេត្ត
  - o បានរៀបចំអនុក្រឹត្យ និងប្រកាសស្តីពីការបែងចែកឥណទានថវិកាចំណូល ចំណាយ និងផ្ទេរសម្រាប់ការអនុវត្តឆ្នាំ ២០១៩
  - o បានរៀបចំកម្មវិធីចំណូល-ចំណាយថវិកាថ្នាក់ជាតិប្រចាំត្រីមាសទី១ ឆ្នាំ២០១៩ និងបានរៀបចំជាប្រកាសកម្មវិធីចំណូល-ចំណាយ ព្រមទាំងចែកចាយដល់គ្រប់ក្រសួង ស្ថាប័ន និងមន្ទីរជំនាញរាជធានី ខេត្ត
  - o បានរៀបចំបោះពុម្ពកូនសៀវភៅស្តីពីថវិកាសង្ខេប ឆ្នាំ ២០១៩ ចំនួន ៥០០ ច្បាប់
  - o បានរៀបចំវេទិកាសាធារណៈស្តីពីការគ្រប់គ្រងម៉ាក្រូសេដ្ឋកិច្ចនិងថវិកាឆ្នាំ២០១៩ ជូនដល់ក្រសួង ស្ថាប័ន, ដៃគូអភិវឌ្ឍន៍, វិទ្យាស្ថានស្រាវជ្រាវ, វិស័យឯកជន, អង្គការសង្គមស៊ីវិល, បណ្តាសារព័ត៌មាន, សាកលវិទ្យាល័យ និងនិស្សិត
  - o បានបន្តប្រជុំជាមួយជំនាញការបរទេស ដើម្បីសរសេរឯកសារតម្រូវការមុខងារកម្រិតខ្ពស់ និងឯកសារតម្រូវការមុខងារលម្អិត សម្រាប់ការរៀបចំប្រព័ន្ធរៀបចំផែនការថវិកា- BUDGET PLANNING SYSTEM (BPS)
  - o បានរៀបចំកិច្ចប្រជុំត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តថវិកាកម្មវិធី ប្រចាំឆ្នាំ ២០១៨ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

[7] មាត្រា ៤ នៃប្រកាសលេខ៦៦៦ ចុះថ្ងៃទី០៨ ខែមិថុនា ឆ្នាំ២០១៦ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនាយកដ្ឋាន និងអង្គភាពក្រោមឱវាទ អគ្គនាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ និងគ្រប់គ្រងបំណុល នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

[8] មាត្រា ៤៤ នៃអនុក្រឹត្យលេខ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

- o បានរៀបចំសេចក្តីព្រាងសេចក្តីណែនាំស្តីពី គោលការណ៍សម្រាប់ដំណើរការពិនិត្យ ពិភាក្សា និងសម្រេច គម្រោងថវិកាប្រចាំឆ្នាំរបស់គ្រឹះស្ថានសាធារណៈរដ្ឋបាលក្នុងក្របខណ្ឌក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- o បានរៀបចំប្រជុំផ្សព្វផ្សាយសារាចរណែនាំលេខ ០៥ សរណន ចុះថ្ងៃទី ១០ ខែមេសា ឆ្នាំ ២០១៩ ស្តីពីការរៀបចំផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ ២០២០-២០២២ នៅទីស្តីការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- o បានចូលរួមកិច្ចប្រជុំពិភាក្សាអំពីការជូនដំណឹងពីការបែងចែកចំណូលពីកម្រៃសេវាអាកាសចរស៊ីវិល និងនីតិវិធីចំណាយជូនក្រសួង-ស្ថាប័នពាក់ព័ន្ធ នៅទីស្តីការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- o បានរៀបចំកិច្ចប្រជុំពិភាក្សាជាមួយក្រុមការងារបេសកកម្មរបស់មូលនិធិរូបិយវត្ថុអន្តរជាតិ ស្តីអំពីការព្យាករណ៍ម៉ាក្រូសេដ្ឋកិច្ច “Macro Projection” នៅទីស្តីការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- o បានចូលរួមក្នុងទស្សនកិច្ចសិក្សាស្តីពី “e-Budget System” នៅប្រទេសថៃ
- o សម្រេចបាននូវកម្រងឯកសារចំនួន ៤ សំខាន់ៗ សម្រាប់ការរៀបចំប្រព័ន្ធរៀបចំផែនការថវិកា (BPS) រួមមាន÷ (១) ឯកសារព្រាងស្តីពីតម្រូវការលម្អិតរបស់អ្នកប្រើប្រាស់ប្រព័ន្ធរៀបចំផែនការថវិកា) (២) ឯកសារលំហូរនៃនីតិវិធីការងារបច្ចុប្បន្ន តាមដំណាក់កាលនៃវដ្តថវិកា (៣) នីតិវិធីអនុវត្តការងារលម្អិតនៃការរៀបចំថវិកាប្រចាំឆ្នាំ (៤) តារាងរាយឈ្មោះនូវតារាងនានា របាយការណ៍ និងឯកសារ ដែលត្រូវបានប្រើប្រាស់នៅគ្រប់ដំណាក់កាលនៃវដ្តថវិកា
- o បានរៀបចំប្រជុំពិភាក្សាលើសេចក្តីព្រាងច្បាប់ស្តីពីការទូទាត់ថវិកាទូទៅរបស់រដ្ឋសម្រាប់ការគ្រប់គ្រងឆ្នាំ ២០១៨ ប្រជុំលើកទី២ នៅទីស្តីការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

- ចំណាយចរន្ត ÷ គិតត្រឹមថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៩ អគ្គនាយកដ្ឋានថវិកាបានអនុវត្តធានាចំណាយ និងអាណត្តិកិច្ចសរុបដូចខាងក្រោម÷
  - o ក្រសួង-ស្ថាប័នស្នើសុំធានាចំណាយសរុបចំនួន **៦ ០០៦ ៤៨១លានរៀល** ស្មើនឹង ៥៨,៩% ធៀបនឹងឥណទានអនុម័តដើមឆ្នាំ២០១៨
  - o ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបានយល់ព្រមធានាចំណាយសរុបចំនួន **៥ ៩៦៧ ០២៨លានរៀល** ស្មើនឹង៥៨,៥% ធៀបនឹងឥណទានអនុម័តដើមឆ្នាំ២០១៨




  - o ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បានបោះផ្សាយអាណត្តិសរុបចំនួន **៤ ៤៦២ ៣១៩ លានរៀល** ស្មើនឹង ៤៣,៧% ធៀបនឹងឥណទានអនុម័តដើមឆ្នាំ២០១៨
  - o ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុសន្សំឥណទានបានចំនួន **៣៩ ៤៥២លានរៀល**

- ក្នុងគោលដៅអនុវត្តការងារត្រួតពិនិត្យចំណាយថវិកាចរន្តឱ្យបានរលូន ទាន់ពេលវេលានិងតាមបរិបទត្រឹមត្រូវអគ្គនាយកដ្ឋានថវិកាបាន÷
- ចំណាយវិនិយោគ ÷ គិតត្រឹមត្រីមាសទី២ ឆ្នាំ២០១៩ ស្ថានភាពឥណទានថវិកាជំពូក២១ និងជំពូក៦១មានដូចខាងក្រោម ÷
    - o ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបានយល់ព្រមផ្តល់ធានាចំណាយចំនួន **៣១៥ ៦៤៤លានរៀល** ក្នុងនោះជំពូក២១ ចំនួន ២៥៩ ១៤៨លានរៀល ប្រមាណ ១៤,១៤% នៃឥណទានប្រចាំឆ្នាំធៀបទៅឆ្នាំ២០១៨ ក្នុងរយៈពេលដូចគ្នាគឺខ្ពស់ជាង ២,១១% និងជំពូក៦១ ចំនួន ៥៦ ៤៩៦ លានរៀល ប្រមាណជា ១២,៥% នៃឥណទានប្រចាំឆ្នាំ ធៀបទៅឆ្នាំ២០១៨ ក្នុងរយៈពេលដូចគ្នាគឺទាបជាង ១៦,៩១%
    - o ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបានយល់ព្រមបើកផ្តល់ចំនួន **១០៣ ១៥៤លានរៀល** ក្នុងនោះជំពូក២១ ចំនួន ៩២ ៩០៧លានរៀល ប្រមាណ ៥,០៧% នៃឥណទានប្រចាំឆ្នាំធៀបទៅឆ្នាំ២០១៨ ក្នុងរយៈពេលដូចគ្នា គឺខ្ពស់ជាង ១,១៨% និងជំពូក៦១ ចំនួន ១០ ២៤៧លានរៀល ប្រមាណ ២,២៧%នៃឥណទានប្រចាំឆ្នាំធៀបទៅឆ្នាំ២០១៨ ក្នុងរយៈពេលដូចគ្នា គឺខ្ពស់ជាង ០,៥៥%
    - o ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុសន្សំឥណទានបានចំនួន **៥២ ៦៩២លានរៀល** ក្នុងនោះជំពូក២១សន្សំបានចំនួន ៣៥ ៨៦៥លានរៀលស្មើនឹង ៤,២៤%ធៀបទៅនិងសំណើនិងជំពូក៦១សន្សំបានចំនួន ១៦ ៨២៧លានរៀលស្មើនឹង ៤,៧៤% ធៀបទៅនិងសំណើ
    - o ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបានផ្តល់បុរេប្រទានថវិកាចំនួន **១២៥ ៩៣៨លានរៀល** ក្នុងនោះជំពូក២១ ចំនួន ៩៨ ៤៤៣លានរៀល និងជំពូក៦១ ចំនួន ២៧ ៤៩៥លានរៀល




- បានចូលរួមត្រួតពិនិត្យទីតាំងគម្រោងដែលត្រូវជួសជុល ស្តារ ហេដ្ឋារចនាសម្ព័ន្ធប្រព័ន្ធធារាសាស្ត្រ សម្រាប់ផែនការឆ្នាំ២០១៩ នៅខេត្តកណ្តាល ព្រៃវែង ស្វាយរៀង កែប ប៉ៃលិន កំពង់ចាម ត្បូងឃ្មុំ ក្រចេះ កំពង់ស្ពឺ កំពត តាកែវ កំពង់ឆ្នាំង ពោធិ៍សាត់ បាត់ដំបង បន្ទាយមានជ័យ និងខេត្តសៀមរាប
- បានពិនិត្យប្រគល់ ទទួលបញ្ចប់សុពលភាពការងារជួសជុលផ្លូវថ្នល់ដោយក្រាលកៅស៊ូ-DBST ស្ថិតក្នុងខេត្តស្ទឹងត្រែង

- បានពិនិត្យប្រគល់ ទទួលបញ្ចប់សុពលភាពការងារជួសជុលខួប ផ្លូវដោយក្រាលកៅស៊ូ-DBST ស្ថិតនៅខេត្តត្បូងឃ្មុំ និងខេត្តកំពង់ឆ្នាំង និងការងារជួសជុលផ្លូវក្រាលកៅស៊ូ DBST ស្ថិតនៅខេត្តតាកែវ
- បានចុះពិនិត្យស្ថានភាពជួសជុលបន្ទាន់ប្រព័ន្ធធារាសាស្ត្រដែលស្ថិតនៅក្នុងខេត្តបាត់ដំបង និងខេត្តឧត្តរមានជ័យ
- បានចូលរួមកិច្ចប្រជុំស្តីពីផែនការគម្រោងសាងសង់ ស្ពារ ប្រព័ន្ធធារាសាស្ត្រឆ្នាំ២០១៩ រវាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងធនធានទឹក និងឧតុនិយម
- បានចូលរួមរៀបចំឯកសារទស្សនាទានស្តីអំពីទិសដៅយុទ្ធសាស្ត្រសម្រាប់គ្រប់គ្រងការវិនិយោគសាធារណៈ
- បានរៀបចំនិងចូលរួមសិក្ខាសាលាពិគ្រោះយោបល់សេចក្តីព្រាងគោលការណ៍ណែនាំស្តីពីនីតិវិធី និងបែបបទចំណាយវិនិយោគសាធារណៈហិរញ្ញប្បទានដោយថវិកាជាតិ (គម្រោងវិនិយោគផ្ទាល់)
- បានចូលរួមពិនិត្យ វាយតម្លៃ ប្រគល់-ទទួលនិងបញ្ចប់សុពលភាពការងារសាងសង់ចំនួន ០៥គម្រោង ស្ថិតនៅខេត្តព្រៃវែង ,ខេត្តព្រះសីហនុ, ខេត្តត្បូងឃ្មុំ និងខេត្តកណ្តាល
- បានពិនិត្យប្រគល់-ទទួលការងារស្ថាបនាផ្លូវដោយក្រាលក្រួសក្រហម និងស្ថាបនាស្ពានបេតុង ស្ថិតខេត្តកំពង់ស្ពឺ និងខេត្តកំពង់ឆ្នាំង
- បានចុះធ្វើការត្រួតពិនិត្យវាយតម្លៃការងារស្ថាបនាខ្លោងទ្វារ និងជួសជុលរបង ស្ថាបនារបងថ្មី ព្រមទាំងស្ថាបនាប៉ុស្តិ៍យាមចំនួន ១កន្លែង ស្ថិតក្នុងរាជធានីភ្នំពេញ
- បានចូលរួមពិនិត្យវាយតម្លៃ ប្រគល់-ទទួល និងបញ្ចប់សុពលភាពគម្រោងមួយចំនួនដូចខាងក្រោម÷
    - o ពិនិត្យវាយតម្លៃលទ្ធផលការងារជួសជុលផ្លូវដោយក្រាលកៅស៊ូ DBST គូសគំនូសសញ្ញា ដាំបង្គោលនាំផ្លូវ ចំនួន ២០ ដើម បំពាក់ស្លាកសញ្ញាចរាចរណ៍ ចំនួន ៤កំប្លេ និងដាក់លូមូលមុខកាត់ ១ម ម ស្ថាបនាអណ្តូងលូ ចំនួន ២០កន្លែង ស្ថាបនា Sub-Inlet ចំនួន ២០កន្លែង ជួសជុលលូអ៊ុយចាស់ដោយ ជួសជុលគម្រប និងលើកកម្ពស់ជញ្ជាំងលូ ស្ថាបនាលូអ៊ុយថ្មី ស្ថាបនាអណ្តូងលូអ៊ុយ ចំនួន ២០កន្លែង ស្ថាបនាជម្រាលកម្រាលបេតុងរំដោះទឹកតាម បណ្តោយសងខាងផ្លូវ ព្រមទាំងរៀបដាក់យើបចិញ្ចើមផ្លូវ ស្ថិតក្នុងខេត្តសៀមរាប
    - o ចុះពិនិត្យប្រគល់-ទទួលការងារជួសជុលផ្លូវក្រាលកៅស៊ូ DBST ស្ថិតនៅខេត្តព្រះសីហនុ និងខេត្តកោះកុង
    - o ពិនិត្យប្រគល់-ទទួលការងារស្ថាបនាផ្លូវបេតុងជុំវិញរង្វង់មូលព្រែកតាមាក់ ស្ថិតក្នុងខេត្តកណ្តាល
- បានចូលរួមត្រួតពិនិត្យ វាយតម្លៃ និងបញ្ចប់សុពលភាពការងារចំនួន ០២គម្រោង ស្ថិតនៅស្រុកជុំគីរី ខេត្តកំពត
- បានចូលរួមត្រួតពិនិត្យ និងប្រគល់-ទទួលលើការងារស្ថាបនាផ្លូវ ស្ពាន លូ ចំនួន ០៣ គម្រោង ស្ថិតនៅខេត្តសៀមរាប និងខេត្តកំពង់ចាម
- បានចូលរួមត្រួតពិនិត្យ និងវាយតម្លៃការងារសាងសង់ផ្លូវ និងសំណង់ចំនួន ០៤គម្រោង ស្ថិតនៅខេត្តស្វាយរៀង ខេត្តកំពង់ស្ពឺ និងខេត្តព្រះវិហារ
- បានចូលរួមត្រួតពិនិត្យ វាយតម្លៃ និងបញ្ចប់សុពលភាពការងារចំនួន ០៣គម្រោង ស្ថិតនៅខេត្តតាកែវ និងខេត្តកំពង់ឆ្នាំង
- បានចុះពិនិត្យប្រគល់) ទទួលការងារស្ថាបនាកំពង់ផែដឹកអ្នកដំណើរ-Taxi Boat) ចំនួន ៦កន្លែង មានទីតាំងនៅ÷ ទីតាំងទី១ កំពង់ផែឫស្សីកែវ ទីតាំងទី២ កំពង់ផែក្រុងតាខ្មៅ ទីតាំងទី៣ កំពង់ផែច្បារអំពៅ ទីតាំងទី៤ កំពង់ផែព្រែកព្នៅ ទីតាំងទី៥ កំពង់ផែផ្សារត្រី និងទីតាំងទី៦ កំពង់ផែណាហ្គា ស្ថិតនៅក្នុងខេត្តកណ្តាល និងរាជធានីភ្នំពេញ

- បានចុះពិនិត្យនិងវាយតម្លៃលទ្ធផល និងបញ្ចប់សុពលភាពការងារជួសជុលផ្លូវដោយក្រាលក្រួស ក្រហម និងសំណង់លូ ០២គម្រោង ស្ថិតក្នុងខេត្តពោធិ៍សាត់ និងខេត្តបាត់ដំបង
- បានចូលរួមរៀបចំឯកសារទស្សនាទានស្តីអំពីទិសដៅយុទ្ធសាស្ត្រសម្រាប់គ្រប់គ្រងការវិនិយោគសាធារណៈ
- បានចូលរួមប្រជុំជាមួយក្រសួងសាធារណការនិងដឹកជញ្ជូន, ក្រសួងអភិវឌ្ឍន៍ជនបទ និងក្រសួងធនធានទឹក និងឧតុនិយម ស្តីពីផែនការគម្រោងវិនិយោគសាធារណៈ ឆ្នាំ២០១៩
- បានចូលរួមកិច្ចប្រជុំអន្តរក្រសួង រវាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ជាមួយនិងក្រសួងធនធានទឹកនិងឧតុនិយម ក្រសួងអភិវឌ្ឍន៍ជនបទ និងក្រសួងសាធារណការ និងដឹកជញ្ជូន ស្តីពីផែនការថវិកាឆ្នាំ២០១៩ ក្រោមក្របខណ្ឌថវិកា ជំពូក ៦១ (ការងារជួសជុល ថែទាំផ្លូវថ្នល់ និងប្រព័ន្ធធារាសាស្ត្រ)
- បានចូលរួមទស្សនកិច្ចសិក្សាស្តីពីក្របខ័ណ្ឌគ្រប់គ្រងការវិនិយោគសាធារណៈ នៅប្រទេសម៉ាឡេស៊ី
- បានចុះត្រួតពិនិត្យ វាយតម្លៃ និងបញ្ចប់សុពលភាពលើការងារជួសជុលផ្លូវ និងសាងសង់លូចំនួន ០២គម្រោង ស្ថិតនៅខេត្តក្រចេះ និងខេត្តស្ទឹងត្រែង
- បានចុះពិនិត្យនិងប្រគល់ទទួលបញ្ចប់សុពលភាពការងារជួសជុលផ្លូវដោយ-ក្រាលក្រួសក្រហមចំនួន ០២ខ្សែ ស្ថិតក្នុងខេត្តសៀមរាប ដែលការងារនេះអនុវត្តដោយមន្ទីរអភិវឌ្ឍន៍ជនបទខេត្តសៀមរាប
- បានចុះពិនិត្យ និងវាយតម្លៃខ្សែផ្លូវខូចខាតធ្ងន់ធ្ងរ ចំនួន ០២ខ្សែ ស្ថិតក្នុងខេត្តបាត់ដំបង
- បានចុះពិនិត្យប្រគល់ទទួលបញ្ចប់សុពលភាពការងារ-ជួសជុលផ្លូវដោយក្រាល កៅស៊ូ DBST និងស្ពានបាលូជ្រុង ចំនួន ១កន្លែង ការងារតលូមូល និងលូមូលភ្លោះសរុបចំនួន ៨កន្លែង ស្ថិតក្នុងខេត្តកំពង់ចាម
- បានចុះពិនិត្យប្រគល់ ទទួលបញ្ចប់សុពលភាពការងារជួសជុលផ្លូវដោយក្រាល កៅស៊ូ-DBST ស្ថិតនៅខេត្តកំពង់ចាម និងត្បូងឃ្មុំ
- បានចូលរួមត្រួតពិនិត្យ០២គម្រោង វាយតម្លៃ និងបញ្ចប់សុពលភាពការងារស្ពានផ្លូវចំនួន- ស្ថិតនៅខេត្តខេត្តពោធិ៍សាត់ និងខេត្តត្បូងឃ្មុំ
- បានចូលរួមពិនិត្យនិងវាយតម្លៃបញ្ចប់សុពលភាពធានាគុណភាពសំណង់ឃ្លាំងរតនាគារខេត្តស្វាយរៀង និងខេត្តពោធិ៍សាត់
- បានចុះពិនិត្យប្រគល់ទទួល-ការងារស្ពានផ្លូវដោយក្រាលក្រួសក្រហម និងស្ពានសំណង់សិល្បការស្ថិតក្នុងខេត្តកំពង់ធំ
- ពិនិត្យផែនការសកម្មភាពការងារ និងគម្រោងចំណាយឆ្នាំ ២០១៩ របស់អាជ្ញាធរអប្សរា និងសាលាខេត្តសៀមរាប ក្នុងក្របខ័ណ្ឌនៃការអនុវត្តចំណាយមូលនិធិអភិរក្ស និងអភិវឌ្ឍន៍តំបន់អង្គរ
- ពិនិត្យវាយតម្លៃនិងបញ្ចប់សុពលភាពលើការងារជួសជុលផ្លូវ និងសាងសង់លូចំនួន០២ គម្រោង ស្ថិតក្នុងខេត្តកំពង់ស្ពឺ និងខេត្តកំពង់ឆ្នាំង
- ចុះពិនិត្យនិងវាយតម្លៃបញ្ចប់សុពលភាពលើគម្រោងការងារជួសជុលផ្លូវក្រាលល្បាយថ្មភ្នំ ចំនួន ១ខ្សែ និងសាងសង់លូមូល ចំនួន ១០កន្លែង ស្ថិតក្នុងខេត្តប៉ៃលិន
- ចុះពិនិត្យបន្ទាន់ស្ថានភាពខូចខាតប្រព័ន្ធធារាសាស្ត្រចំនួន ២កន្លែង ក្នុងខេត្តឧត្តរមានជ័យ និងខេត្តបន្ទាយមានជ័យ
- ចុះត្រួតពិនិត្យ វាយតម្លៃ និងបញ្ចប់សុពលភាពលើការងារជួសជុលផ្លូវក្រាលក្រួសក្រហមចំនួន ០១ខ្សែ និងក្រាលក្រួសក្រហមទទឹង និងសាងសង់លូមូលគ្រប់ប្រភេទ ចំនួន ១៩កន្លែង ស្ថិតក្នុងខេត្តត្បូងឃ្មុំ
- ការចុះកិច្ចព្រមព្រៀង (គិតចាប់ពីខែមករា-មិថុនា ឆ្នាំ២០១៩)
  - ហិរញ្ញប្បទានឥតសំណង÷ បានចុះកិច្ចព្រមព្រៀងចំនួន ១២ គម្រោង ដែលមានទឹកប្រាក់សរុបប្រមាណចំនួន ២៨៣,១៩ លានដុល្លារអាមេរិក ដែលមានដូចខាងក្រោម÷

- ✓ ដៃគូអភិវឌ្ឍន៍ពហុភាគី÷ បានចុះកិច្ចព្រមព្រៀងចំនួន ០៦ គម្រោង ដែលមានទឹកប្រាក់សរុបចំនួន ៤៨,៣៥ លានដុល្លារអាមេរិក
- ✓ ដៃគូអភិវឌ្ឍន៍ទ្វេភាគី÷បានចុះកិច្ចព្រមព្រៀងចំនួន ០៦ គម្រោង ដែលមានទឹកប្រាក់សរុបចំនួន ២៣៤,៨៥ លានដុល្លារអាមេរិក

o ឥណទានសម្បទាន÷ បានចុះកិច្ចព្រមព្រៀងចំនួន ០៩ គម្រោង ដែលមានទឹកប្រាក់សរុបប្រមាណចំនួន ៥០៤,៦១ លានដុល្លារអាមេរិក ឬប្រមាណ ៣៦១,១៩ លានអេសដេអ៊ែរ ស្មើនឹង ២៥,៨០% នៃពិដានដែលច្បាប់អនុញ្ញាត (១ ៤០០ លានអេសដេអ៊ែរ) ដែលមានដូចខាងក្រោម÷

- ✓ ដៃគូអភិវឌ្ឍន៍ពហុភាគី÷ បានចុះកិច្ចព្រមព្រៀងសរុបចំនួន ០៤ គម្រោង ដែលមានទឹកប្រាក់សរុបចំនួន ១៦១,០៦ លានអេសដេអ៊ែរ ឬប្រមាណ ២២៥,០១ លានដុល្លារអាមេរិក
- ✓ ដៃគូអភិវឌ្ឍន៍ទ្វេភាគី÷ បានចុះកិច្ចព្រមព្រៀងសរុបចំនួន ០៥ គម្រោង ដែលមានទឹកប្រាក់សរុបចំនួនប្រមាណ ២៧៩,៦០ លានដុល្លារអាមេរិក ឬប្រមាណ ២០០,១៣ លានអេសដេអ៊ែរ

- ការដកសាច់ប្រាក់ (Disbursement) (គិតចាប់ពីខែមករា-មថុនា ឆ្នាំ២០១៩) ÷ បានដកសាច់ប្រាក់សរុបចំនួន ៣៩៧,៣៤ លានដុល្លារអាមេរិក ឬ ប្រមាណ ១ ៦០៤,២៦ ប៊ីលានរៀល ស្មើនឹង ២៨,៧៨% នៃផែនការប្រចាំឆ្នាំ ក្នុងនោះ÷
  - o ហិរញ្ញប្បទានឥតសំណង (Grant)÷ បានដកសាច់ប្រាក់សរុបចំនួនប្រមាណ ៩,៧៩ លានដុល្លារអាមេរិក ឬ ប្រមាណ ៣៩,៥២ ប៊ីលានរៀល ស្មើនឹង ៣,៣២% នៃផែនការប្រចាំ
  - o ឥណទានសម្បទាន (Concessional Loan)÷ បានដកសាច់ប្រាក់សរុបចំនួនប្រមាណ ៣៨៧,៥៥ លាន ដុល្លារអាមេរិក ឬ ប្រមាណ ១ ៥៦៤,៧៣ ប៊ីលានរៀល ស្មើនឹង ៣៥,៦៩% នៃផែនការប្រចាំឆ្នាំ ០,៣៩ ប៊ីលានរៀល ឬ ប្រមាណ ០,១០ លានដុល្លារអាមេរិក ស្មើនឹង ៩,៦៤% នៃឥណទានប្រចាំឆ្នាំ។
- ការគ្រប់គ្រងបំណុល
  - o ការទូទាត់សេវាបំណុល (គិតចាប់ពីខែមករា-មិថុនា ឆ្នាំ២០១៩) ÷ បានទូទាត់សេវាបំណុលជូនដៃគូអភិវឌ្ឍន៍សរុបចំនួនប្រមាណ ៥២០,៤២ ប៊ីលានរៀល ឬ ប្រមាណ១២៧,៩៩ លានដុល្លារអាមេរិក
  - o ការប្រមូលចំណូលពីការឱ្យប្រាក់គេខ្ចី (គិតចាប់ពីខែមករា-មិថុនា ឆ្នាំ២០១៩) ÷ បានប្រមូលចំណូលសេវាបំណុលពីឥណទាយិកសរុបចំនួនប្រមាណ ១៥៤,៩៥ ប៊ីលានរៀល ឬ ប្រមាណ ៣៨,១១ លានដុល្លារអាមេរិក
- សន្និធិបំណុល ÷ ដោយគិតទាំងបំណុលចាស់ គិតត្រឹមដំណាច់ខែមិថុនា ឆ្នាំ២០១៩នេះ កម្ពុជាមានសន្និធិបំណុលសាធារណៈសរុបចំនួនប្រមាណ ៧ ៣២៧,៦៩ លានដុល្លារអាមេរិក ក្នុងនោះ ភាគច្រើនលើសលប់ជាសន្និធិបំណុលសាធារណៈក្រៅប្រទេស ដែលមានចំនួនប្រមាណ ៧ ៣២៤,៩៤ លានដុល្លារអាមេរិក ត្រូវនឹង ៩៩,៩៦% នៃសន្និធិបំណុល សាធារណៈសរុប និង សន្និធិបំណុលសាធារណៈក្នុងប្រទេសមានចំនួនប្រមាណ ២,៧៥ លានដុល្លារអាមេរិក ត្រូវនឹង ០,០៤% នៃ សន្និធិបំណុលសាធារណៈសរុប។
  - ➢ តាមការវិភាគបង្ហាញថា ស្ថានភាពបំណុលសាធារណៈកម្ពុជាបច្ចុប្បន្នមាន "ចីរភាព" និង "ហានិភ័យកម្រិតទាប"។

### ២.២.២. ការគ្រប់គ្រងចំណាយសាធារណៈ

❖ ការគ្រប់គ្រងចំណាយសាធារណៈថ្នាក់ជាតិ

- បានអញ្ជើញតំណាងអគ្គនាយកដ្ឋានថវិកា មន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុអមបេឡាជាតិសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការស៊ីវិល (ប.ជ.ស) និងមន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុអមបេឡាជាតិអតីតយុទ្ធជន (ប.ជ.អ), នាយក ប.ជ.ស និងនាយក ប.ជ.អ ពិភាក្សាតម្រង់ទិសលើការទូទាត់បុរេប្រទានប្រាក់ឧបត្ថម្ភក្នុងពិធីបុណ្យចូលឆ្នាំប្រពៃណីជាតិឆ្នាំ ២០១៩ ជូននិវត្តជនកន្លងមក
- បានប្រជុំពិភាក្សាលើការទូទាត់ថវិកាសម្រាប់ចំណាយប្រាក់ឧបត្ថម្ភបុគ្គលិក និងចំណាយប្រតិបត្តិការកាណូតដឹកអ្នកដំណើរ ជូនក្រសួងសាធារណការនិងដឹកជញ្ជូន និងភាគីពាក់ព័ន្ធ
- បានចូលរួមកិច្ចប្រជុំពិភាក្សាអំពីបញ្ហាស្ទួនសមតុល្យ របស់ប្រតិបត្តិការឧបត្ថម្ភធនថវិកាជូនរដ្ឋបាលថ្នាក់ក្រោមជាតិ និងគ្រោងថវិកាថ្នាក់ក្រោមជាតិក្នុងរបាយការណ៍យោងនៃច្បាប់ទូទាត់ថវិកា
- បានបន្តដោះស្រាយបញ្ហាអាណត្តិបើកប្រាក់ក្នុងឆ្នាំ២០១៨ និងបន្តជំរុញការងារផ្ទៀងផ្ទាត់បិទបញ្ជីចំណូល-ចំណាយថវិកាប្រចាំឆ្នាំ២០១៨ ឱ្យបានត្រឹមត្រូវ និងទាន់ពេលវេលា
- បានចូលរួមនៅក្នុង Regional Workshop on Accelerating Cash Management Reforms ដែលសហការរៀបចំដោយ State Treasury of Vietnam and the IMF"s Fiscal Affairs Department (FAD) and Capacity Development Office in Thailand (CDOT) នៅរដ្ឋធានីហាណូយ ប្រទេសវៀតណាម រយៈពេល៤ថ្ងៃ (២៦កុម្ភៈ - ០១ មីនា ឆ្នាំ២០១៩) ដោយបានធ្វើបទបង្ហាញស្តីអំពី " គណនីទោលរតនាគារនិងការគ្រប់គ្រងសាច់ប្រាក់របស់កម្ពុជា" ជូនអង្គសិក្ខាសាលា និងសិក្ខាកាមប្រមាណ៦០នាក់ ដែលអញ្ជើញមកពីបណ្តាប្រទេសចំនួន១២
- បានរៀបចំសេចក្តីណែនាំ ស្តីពីការបើកផ្តល់ប្រាក់ឧបត្ថម្ភក្នុងឱកាសពិធីចូលឆ្នាំថ្មីប្រពៃណីជាតិខ្មែរ សម្រាប់ដាក់ឱ្យរដ្ឋបាលថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិអនុវត្ត
- បានរៀបចំកិច្ចប្រជុំជាមួយធនាគារស្ថាបនាដើម្បីសិក្សាស្វែងយល់ជាបឋមមុននឹងឈានទៅដល់ការអនុវត្ត MOU
- បានរៀបចំកិច្ចប្រជុំជាមួយតំណាងអគ្គនាយកដ្ឋានពន្ធដារ ,រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញអគ្គិសនី ,កម្ពុជា ពិភាក្សាអំពីការផ្ទេរប្រាក់ពីគណនីប្រាក់បញ្ញើរបស់រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ ដើម្បីបង់ថ្លៃអគ្គិសនី និងបង់ពន្ធ ជូនអគ្គនាយកដ្ឋានពន្ធដារ
- បានរៀបចំសេចក្តីណែនាំអំពីនីតិវិធីនៃការបង់អតិរេកថវិកាឆ្នាំ២០១៨ របស់សាលាខេត្តព្រះវិហារ
- បានចេញសេចក្តីណែនាំ ដើម្បីណែនាំដល់រតនាគារខេត្តកែប លើការកែតម្រូវកិច្ចបញ្ជិកាគណនេយ្យឃុំពងទឹក ដែលគណនេយ្យកររតនាគារខេត្តបានកត់ត្រាស្ទួននូវចំណូលបដិភាគរបស់ប្រជាពលរដ្ឋលើចំណាយអភិវឌ្ឍឃុំ និងណែនាំដល់រតនាគារខេត្តព្រះវិហារ អំពីនីតិវិធីនៃការបង់អតិរេកថវិកាឆ្នាំ២០១៨របស់សាលាខេត្តព្រះវិហារ
- បានរៀបចំកិច្ចប្រជុំជាអង្គភាពពាក់ព័ន្ធ ដើម្បីពិនិត្យនីតិវិធីចំណាយឆ្នាំ២០១៩ របស់ខណ្ឌចំនួន២ និងក្រុង ស្រុក ចំនួន៤ ដែលបានបង្កើតថ្មី
- បានប្រជុំពិភាក្សាលើការប្រូវឯកសារបណ្តផ្ទេរភារៈចំណាយទៅប្រើតារាងផ្ទេរវិភាជន៍ថវិកាឃុំ សង្កាត់ និងថវិកា ក្រុង ស្រុក ខណ្ឌ
- បានចូលរួមក្នុងវគ្គបណ្តុះបណ្តាល ស្តីពីការកំណត់មាតិកាថវិកានិងលិខិតយុត្តិការចំណាយសម្រាប់ ទូទាត់សេវាសង្គម និងការកំណត់ពិដានចំណាយថវិកាសម្រាប់សេវាសង្គមនៅរដ្ឋបាលសង្កាត់
- បានចូលរួមបេសកកម្មទៅខេត្តពោធិ៍សាត់ ជាមួយក្រុមការងារសាកល្បងផ្ទេរមុខងារ អនាម័យជនបទ ពីក្រសួងអភិវឌ្ឍន៍ជនបទ ទៅរដ្ឋបាលស្រុកគោលដៅ

- បានចូលរួមកិច្ចប្រជុំអន្តរក្រសួង ស្ថាប័ន ស្តីពីការរៀបចំសេចក្តីព្រាងគោលការណ៍ណែនាំ និងវាយតម្លៃសមិទ្ធកម្មប្រចាំឆ្នាំសម្រាប់រដ្ឋបាលក្រុង និងសម្រាប់រដ្ឋបាលខណ្ឌ
- បានចូលរួមសិក្ខាសាលាពិគ្រោះយោបល់លើសេចក្តីព្រាងសេចក្តីណែនាំស្តីពីការកំណត់មាតិកាថវិកាកម្មវិធី និងសេដ្ឋកិច្ចលើមុខសញ្ញាចំណាយគម្រោងសេវាសង្គមនៅថ្នាក់រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានប្រជុំជាមួយតំណាងអគ្គនាយកដ្ឋានហិរញ្ញវត្ថុរដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីពិនិត្យការប្រើប្រាស់អនុគណនីសម្រាប់កត់ត្រាចំណូលសារពើពន្ធរបស់រដ្ឋបាលក្រុង ស្រុក ឃុំ សង្កាត់
- បានរៀបចំសេចក្តីណែនាំស្តីពីការនិយ័តភាពនិងការកត់ត្រាចំណូលសារពើពន្ធដែលឃុំ សង្កាត់ ទទួល ពីរាជធានី ខេត្ត
- បានពិភាក្សាដើម្បីធ្វើបច្ចុប្បន្នភាពធ្វើសន្ធានកម្ម ASYCUDA សម្រាប់ចំណូលពីសេវាសាធារណៈ របស់គយ (តាមនីតិវិធីរដ្ឋទយ្យចំណូល)
- បានរៀបចំប្រជុំជាមួយធនាគារពាណិជ្ជពាក់ព័ន្ធនឹង EPA ដើម្បីស្វែងរកចំណុចឯកភាពគ្នាលើការបើក និងការប្រើប្រាស់គណនីរបស់ EPA គណនីរបស់ភ្នាក់ងារបើកផ្តល់ និងគណនីរបស់រដ្ឋទេយ្យករបុរេប្រទាន នៅធនាគារពាណិជ្ជ
- បានចូលរួមទស្សនកិច្ចសិក្សាស្តីពីការរៀបចំរបាយការណ៍ GFS របស់គ្រឹះស្ថានសាធារណៈរដ្ឋបាលជាមួយក្រុមការងារក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុនៅប្រទេសរុស្ស៊ី
- បានរៀបចំសេចក្តីព្រាងណែនាំក្នុងនាមក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ស្តីពីការប្រើប្រាស់គណនីចំណូលរបស់ EPA នៅធនាគារ ការបើកនិងការប្រើប្រាស់គណនីរបស់ភ្នាក់ងារបើកផ្តល់ និងគណនីរបស់រដ្ឋទេយ្យករបុរេប្រទាន
- បានចូលរួមផ្សព្វផ្សាយខ្លឹមសារនៃអនុក្រឹត្យលេខ ១៥ អនក្រស្តីពីការគ្រប់គ្រងថវិកា ខែមករា ឆ្នាំ២០១៩ បក ចុះថ្ងៃទី១៥. និងទ្រព្យសម្បត្តិរដ្ឋ នៃគ្រឹះស្ថានសាធារណៈរដ្ឋបាល ទិសដៅការងារថវិកានិងគណនេយ្យរបស់គ្រឹះស្ថានសាធារណៈរដ្ឋបាល
- បានរៀបចំសារាចរណែនាំស្តីពីកិច្ចបញ្ជិកាគណនេយ្យលើការផ្តល់ឧបត្ថម្ភធនសម្រាប់ត្រីមាសទី១ ដល់គ្រឹះស្ថានសាធារណៈរដ្ឋបាល
- នៅក្នុងឆមាសទី១ ឆ្នាំ២០១៩ កន្លងមកនេះការទទួលចំណូលនៅអគ្គនាយកដ្ឋានរតនាគារជាតិសរុបចំនួន **១១ ៩៣២ ៥៦៩ លានរៀល** និងបានចំណាយបើកប្រាក់បៀវត្សដូចខាងក្រោម÷
  - នៅរដ្ឋបាលកណ្តាលសរុបចំនួន **២ ១៨៥ ៥៥៣ លានរៀល**
  - នៅរាជធានី ខេត្តសរុបចំនួន **២ ១៥២ ២៥៩ លានរៀល ។**
- ប្រកាសស្តីពីបុរេលក្ខណសម្បត្តិអ្នកដេញថ្លៃត្រូវបានថ្នាក់ដឹកនាំក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុពិនិត្យនិងសម្រេច និងដាក់ឱ្យប្រើប្រាស់តាមរយៈប្រកាសលេខ ០១៤ សហវប្រក. ចុះថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០១៩
- បាន និងកំពុងរៀបចំសារាចរណែនាំស្តីពីការរៀបចំគម្រោងផែនការលទ្ធកម្មប្រចាំឆ្នាំ
- បានពិនិត្យ និងផ្តល់ទិដ្ឋាការលើឯកសារដេញថ្លៃចំនួន ២៥៥គម្រោង
- ចូលរួមចរចាថ្លៃចំនួន ៣៨៤គម្រោង
- ចូលរួមបើកឯកសារដេញថ្លៃ (លើសិទ្ធិ) ចំនួន ១៣២គម្រោង និងពិគ្រោះថ្លៃ និងស្ទង់តម្លៃ (ក្រោមសិទ្ធិ) ចំនួន ៤២៦គម្រោង
- លទ្ធកម្មដោយឡែក ២៤គម្រោង
- ត្រួតពិនិត្យឯកសារកិច្ចសន្យា ៣៨៥គម្រោង
- បានប្រគល់កិច្ចសន្យាចំនួន ២៣៧គម្រោង

- ស្នើសុំគោលការណ៍ ៣៥គម្រោង
- ចូលរួមត្រួតពិនិត្យវាយតម្លៃលទ្ធផលការងារ បញ្ចប់សុពលភាព ប្រគល់-ទទួល ទំនិញ សំណង់ និងសេវាកម្ម(ក្រោមសិទ្ធិ) ចំនួន ២៧៣គម្រោង និង(លើសិទ្ធិ)ចំនួន ៦២៣គម្រោង ។

❖ **ការគ្រប់គ្រងចំណាយសាធារណៈថ្នាក់ក្រោមជាតិ**

- ចុះបណ្តុះបណ្តាលគោលការណ៍ណែនាំស្តីពីការវាយតម្លៃសមិទ្ធកម្មរបស់រដ្ឋបាលស្រុកឆ្នាំ២០១៩
- រៀបចំប្រកាសបន្ថែមឥណទានជូនរដ្ឋបាលស្រុកដែលជាប់ចំណាត់ថ្នាក់ទទួលបានមូលនិធិវិនិយោគរដ្ឋបាលថ្នាក់ក្រោមជាតិ
- បោះផ្សាយអាណត្តិផ្ទេរធនធានមូលនិធិវិនិយោគរដ្ឋបាលថ្នាក់ក្រោមជាតិ ជូនរដ្ឋបាលស្រុក គោលដៅ
- ដាក់ឱ្យអនុវត្តគោលការណ៍ណែនាំស្តីពីការវាយតម្លៃសមិទ្ធកម្មប្រចាំឆ្នាំសម្រាប់រដ្ឋបាលក្រុង និងរដ្ឋបាលខណ្ឌ
- បានរៀបចំសារាចរណែនាំស្តីពីនីតិវិធីបច្ចេកទេសនៃការរៀបចំគម្រោងថវិការដ្ឋបាលថ្នាក់ក្រោមជាតិឆ្នាំ២០២០
- ចុះផ្សព្វផ្សាយសារាចរណែនាំស្តីពីនីតិវិធីបច្ចេកទេសនៃការរៀបចំគម្រោងថវិការដ្ឋបាល ថ្នាក់ក្រោមជាតិឆ្នាំ២០២០
- ជូនដំណឹងកញ្ចប់ថវិកាបឋមសម្រាប់ការគ្រប់គ្រងឆ្នាំ២០២០ ជូនរដ្ឋបាលរាជធានី ខេត្ត
- វិភាជន៍ និងជូនដំណឹងធនធានមូលនិធិក្រុង ស្រុក និងមូលនិធិឃុំ សង្កាត់ សម្រាប់ឆ្នាំ២០២០ ជូនរដ្ឋបាលក្រុង ស្រុក និងរដ្ឋបាលឃុំ សង្កាត់
- ផ្ទេរភារៈចំណាយមូលនិធិក្រុង ស្រុក សម្រាប់ត្រីមាសទី២ និងត្រីមាសទី៣ ជូនរដ្ឋបាលក្រុង ស្រុក
- រៀបចំប្រកាសបន្ថែមឥណទានជូនរដ្ឋបាលក្រុង ស្រុកគោលដៅអនុវត្តមុខងារសេវាអនាម័យ ជនបទ
- សេចក្តីព្រាងអនុក្រឹត្យស្តីពីការផ្ទេរធនធានបន្ថែមថវិការដ្ឋជូនរដ្ឋបាលឃុំ សង្កាត់ ត្រូវបាន ដាក់ប្រជុំពិភាក្សា
- ដាក់ឱ្យអនុវត្តសេចក្តីណែនាំស្តីពីការអនុវត្តថវិការដ្ឋបាលក្រុង ស្រុក ខណ្ឌ ដែលបង្កើតថ្មី និងចំណាយប្រាក់ឧបត្ថម្ភក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិ
- បណ្តុះបណ្តាលការរៀបចំសកម្មភាពសេវាសង្គម នៅក្នុងកម្មវិធីវិនិយោគបីឆ្នាំរំកិល និង នៅក្នុងផែនការយុទ្ធសាស្រ្តថវិការបស់ថ្នាក់ក្រោមជាតិ ជូនរដ្ឋបាលខេត្ត នៅខេត្តកំពង់ចាម
- ផ្តល់ការគាំទ្រដល់រដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការអនុវត្តថវិការបស់ខ្លួន។

### ២.២.៣. ការគ្រប់គ្រងគម្រោងយន្តការភាពជាដៃគូរវាងរដ្ឋនិងឯកជន

- បានបញ្ចប់ការរៀបចំសិក្ខាសិលាពិគ្រោះយោបល់ជាលើកទី២ នៅខែមិថុនា ឆ្នាំ២០១៩ ដើម្បីប្រមូលធាតុចូល និងកែសម្រួលសេចក្តីព្រាងនេះ មុននឹងដាក់ជូនគណៈកម្មការអន្តរក្រសួងដឹកនាំការអនុវត្តគោលនយោបាយស្តីពីការអភិវឌ្ឍយន្តការភាពជាដៃគូរវាងរដ្ឋ និងឯកជន ពិនិត្យ និងសម្រេច
- គម្រោងមជ្ឈមណ្ឌលឡូជីស្ទីកក្រុងព្រះសីហនុត្រូវបានចុះកិច្ចសន្យាជាមួយដៃគូឯកជន÷ បានរៀបចំលិខិត ទទួលស្គាល់ជំនួយបច្ចេកទេសពី IFC ដើម្បីសិក្សាធ្វើ Business Case អំពីគម្រោងនេះ
- គម្រោងអភិវឌ្ឍន៍កំពង់ផែទេសចរណ៍ក្រុងព្រះសីហនុត្រូវបានចុះកិច្ចសន្យាជាមួយដៃគូឯកជន÷ បានបំពេញបេសកកម្មដើម្បីជួបប្រជុំជាមួយតំណាងកំពង់ផែស្វយ័តក្រុងព្រះសីហនុ នៅខេត្តព្រះសីហនុ
- បានចូលរួមកិច្ចប្រជុំពហុភាគីជាមួយតំណាងរបស់ UNCDF និងតំណាងរបស់អគ្គលេខាធិការដ្ឋានអាកាសចរស៊ីវិល ដែលទាក់ទងនឹងគម្រោងមជ្ឈមណ្ឌលឧតុនិយមអាកាសចរស៊ីវិលត្រូវបានចុះកិច្ចសន្យាជាមួយដៃគូឯកជន
- បាននឹងកំពុងរៀបចំជ្រើសរើសក្រុមហ៊ុន សេវាវាយតម្លៃអចលទ្រព្យ ដើម្បីធ្វើការវាយតម្លៃលើផ្ទៃដីទំហំ ៨ហិកតា និង ៥. សេវាទីប្រឹក្សាវិស្វកម្មសំណង់ ដើម្បី វាយតម្លៃលើការចំណាយសាងសង់គម្រោង ក្នុងបរិវេណពហុកីឡាដ្ឋានមរតកតេជោ

- បានចូលរួមពិនិត្យ និងផ្តល់ធាតុចូលលើសេចក្តីព្រាង FA រវាងរាជរដ្ឋាភិបាលកម្ពុជា និងក្រុមហ៊ុន China Railway International Group មុននឹងចាប់ផ្តើមការសិក្សាសមិទ្ធិលទ្ធភាពនៃគម្រោង
- បានសម្របសម្រួលស្នើសុំក្រសួងសាធារណការ និងដឹកជញ្ជូនផ្តល់យោបល់លើបញ្ជីប៉ាន់តម្លៃ (BOQ សម្រាប់ការរៀបចំ ( RGC Work
- បានរៀបចំបញ្ជីចងក្រងឯកសារសម្រាប់គ្រប់ដំណាក់កាលនៃលក្ខខណ្ឌបង្គង់
- បានរៀបចំសម្របសម្រួលករណីសំណើសុំការបញ្ជាក់លើពន្ធកាត់ទុកលើការប្រាក់ជូនក្រុមហ៊ុនសម្បទានិក
- បានរៀបចំបញ្ជីការងារដែលពាក់ព័ន្ធនឹងដំណាក់កាលសាងសង់ហេដ្ឋារចនាសម្ព័ន្ធគម្រោង សម្រាប់ប្រើប្រាស់ផ្ទៃក្នុង
- បានចូលរួមកិច្ចប្រជុំពិភាក្សាលើកិច្ចព្រមព្រៀងក្របខ័ណ្ឌ គម្រោងផ្លូវល្បឿនលឿនភ្នំពេញ- បាវិត
- បានចូលរួមសិក្ខាសាលាស្តីពី "Public Private Partnership Risk Allocation and Contractual Provisions" នៅប្រទេសសិង្ហបុរី

**២.៣. ការផ្តល់សេវាគាំទ្រទូទៅ និងគណនេយ្យភាពក្នុងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ**

ចំណុច ២.៣.១. ត្រូវបានអនុវត្ត និងទទួលខុសត្រូវ ដោយអគ្គលេខាធិការដ្ឋាន អគ្គនាយកដ្ឋានដោះស្រាយផលប៉ះពាល់ដោយសារគម្រោងអភិវឌ្ឍន៍ វិទ្យាស្ថានសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងលេខាធិការដ្ឋានក្រុមប្រឹក្សានីតិកម្ម។ អគ្គលេខាធិការដ្ឋាន មានបេសកកម្មសំខាន់ៗលើ ១.ការផ្តល់សេវាគាំទ្រសម្រាប់ប្រក្រតីភាពនៃដំណើរការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ២. សម្របសម្រួលការងាររវាងថ្នាក់កណ្តាល និងអង្គភាពមូលដ្ឋានក្រោមឱវាទក្រសួង ពិសេសមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុរាជធានីខេត្ត ៣. ជាសេនាធិការឱ្យក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ លើផ្នែករដ្ឋបាល ហិរញ្ញវត្ថុ បុគ្គលិក ការបណ្តុះបណ្តាលនិង វិក្រិត្យការ ព័ត៌មានវិទ្យា បណ្ណសារ៩...។ អគ្គនាយកដ្ឋានដោះស្រាយផលប៉ះពាល់ដោយសារគម្រោងអភិវឌ្ឍន៍បេសកកម្ម សំខាន់លើការងារដោះស្រាយផលប៉ះពាល់ដោយសារគម្រោងអភិវឌ្ឍន៍នានា...[10]។ វិទ្យាស្ថានសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បំពេញមុខងារសំខាន់លើការបណ្តុះបណ្តាល និងវិក្រឹត្យការសមត្ថភាពមន្ត្រីរាជការលើមុខជំនាញសេដ្ឋកិច្ច និងហិរញ្ញវត្ថុ[11]។ ចំណែក ២.៣.២. ត្រូវបានអនុវត្ត និងទទួលខុសត្រូវដោយ អគ្គនាយកដ្ឋានសវនកម្មផ្ទៃក្នុង ដែលមានបេសកកម្មសំខាន់លើការងារពង្រឹងប្រព័ន្ធគ្រប់គ្រងសវនកម្មផ្ទៃក្នុងរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងនាំមុខក្នុងការអភិវឌ្ឍមុខងារសវកម្មផ្ទៃក្នុង នៅតាមបណ្តាក្រសួង ស្ថាប័ន និងសហគ្រាសសាធារណៈ[12]។ ដោយឡែកចំណុច ២.៣.៣. មានបេសកកម្មសំខាន់លើការងារធ្វើអធិការកិច្ច លើការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដោយប្រើអភិក្រម អធិការកិច្ចផ្អែកលើហានិភ័យ និងអធិការកិច្ចផ្អែកលើករណីសង្ស័យឬបណ្តឹងតវ៉ាជាក់ស្តែង[13]។ ចុងក្រោយ លេខាធិការដ្ឋានក្រុមប្រឹក្សានីតិកម្មមានមុខងាររៀបចំតាក់តែងសេចក្តីព្រាងច្បាប់និងលិខិតបទដ្ឋានគតិយុត្ត ដើម្បីធានាសុវត្ថិភាពនីត្យានុកូលភាព នៃការគ្រប់គ្រងនិងការអភិវឌ្ឍ ប្រកបដោយសង្គតិភាព និងចីរភាព នៃលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធសមត្ថកិច្ចរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ។ ជាលទ្ធផលប្រចាំឆមាសទី១ ឆ្នាំ២០១៩ អង្គភាពនីមួយៗ បានអនុវត្ត និងទទួលបានវឌ្ឍនភាពគួរឱ្យកត់សម្គាល់ដូចខាងក្រោម ÷

---

[9] មាត្រា ១០ នៃអនុក្រឹត្យលេខ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

[10] មាត្រា ៤ នៃអនុក្រឹត្យលេខ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

[11] មាត្រា ៤ នៃអនុក្រឹត្យលេខ១០៥៨ ប្រក ចុះថ្ងៃទី០៣ ខែកញ្ញា ឆ្នាំ២០១៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃនាយកដ្ឋាន និងអង្គភាពក្រោមឱវាទរបស់វិទ្យាស្ថាន

[12] មាត្រា ៥៦ នៃអនុក្រឹត្យលេខ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

[13] មាត្រា ៥២ នៃអនុក្រឹត្យលេខ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

## ២.៣.១. ការផ្តល់សេវាគាំទ្រទូទៅ

- ប្រជុំពិភាក្សារវាង IRC ក្រសួងសាមី (MPWT) និងមន្ត្រី ADB-CARM ស្តីពីការកែតម្រូវឯកសារបច្ចុប្បន្នភាពផែនការសកម្មភាពដោះស្រាយផលប៉ះពាល់ដោយសារអនុគម្រោងការស្តារប្រព័ន្ធដោះទឹកភ្លៀង នៅក្រុងបាត់ដំបង និងក្រុងបាវិត នៃគម្រោងអភិវឌ្ឍន៍សេដ្ឋកិច្ចក្រុងរបៀងភាគខាងត្បូងកម្ពុជា
- ប្រជុំពិភាក្សារវាង IRC ក្រសួងសាមីពាក់ព័ន្ធគម្រោង និងមន្ត្រី ADB-CARM ស្តីពី Country Portfolio Review ដើម្បីពិភាក្សាលើវឌ្ឍនភាពនៃការអនុវត្តគម្រោងមួយចំនួនពាក់ព័ន្ធនឹង វិស័យអភិវឌ្ឍន៍ទីក្រុង និងផ្គត់ផ្គង់ទឹកស្អាត
- បានចូលរួមកិច្ចប្រជុំស្តីពីវឌ្ឍនភាពការងាររបស់គម្រោងហេដ្ឋារចនាសម្ព័ន្ធផ្លូវល្បឿនលឿន ភ្នំពេញ-ខេត្តព្រះសីហនុ
- បានចូលរួមជាមួយក្រុមគណៈកម្មការអន្តរក្រសួង និងអនុគណៈកម្មការខេត្ត ស្តីពីការងារដោះស្រាយផលប៉ះពាល់សម្រាប់គម្រោងសាងសង់ផ្លូវក្រវាត់ក្រុងទី ៣ នៅទីស្តីការ ក្រសួងសាធារណការ និងដឹកជញ្ជូន
- ការពិនិត្យ និងអនុម័តលើ Resettlement Plan និង Resettlement Framework
- បានពិនិត្យ និងអនុម័តគម្រោងក្រុងរបៀង២ ខេត្តកំពត
- កំពុងពិនិត្យ និងកែតម្រូវផែនការសកម្មភាពដោះស្រាយផលប៉ះពាល់ទ្រព្យសម្បត្តិនានា ដោយសារគម្រោងអភិវឌ្ឍន៍សេដ្ឋកិច្ចក្រុងរបៀងភាគខាងត្បូងកម្ពុជា រួមមាន÷ អនុគម្រោងកែលម្អផ្លូវក្រុងបាវិត និងអនុគម្រោងស្តារប្រព័ន្ធដោះទឹកភ្លៀងនៅក្រុងបាត់ដំបង
- កំពុងពិនិត្យ និងកែតម្រូវផែនការសកម្មភាពដោះស្រាយផលប៉ះពាល់ទ្រព្យសម្បត្តិនានា ដោយសារគម្រោងស្តារឡើងវិញកំណាត់ផ្លូវជាតិលេខ ៥ ផ្នែកកណ្តាល (កំណាត់ផ្លូវចាស់ក្នុងខេត្តបាត់ដំបង)
- កំពុងពិនិត្យ និងកែតម្រូវផែនការសកម្មភាពដោះស្រាយផលប៉ះពាល់ទ្រព្យសម្បត្តិនានា ដោយសារគម្រោងកម្មវិធីអភិវឌ្ឍន៍ផ្នែកពាណិជ្ជកម្មស្រូវធន់នឹងអាកាសធាតុអនុគម្រោងតាសួង ខេត្តកំពង់ធំ
- ធ្វើបច្ចុប្បន្នភាពលើសៀវភៅផែនការការងារដោះស្រាយផលប៉ះពាល់ (DRP2) សហការជាមួយក្រុមការងារទីប្រឹក្សាសម្រាប់អនុគម្រោងអភិវឌ្ឍន៍ប្រព័ន្ធធារាសាស្រ្តដំណាក់ឈើក្រំ
- ត្រួតពិនិត្យ និងអនុម័តលើផែនការដោះស្រាយផលប៉ះពាល់បឋមនៃគម្រោងស្ថានីយចម្រោះទឹកកខ្វក់ក្រុងតាខ្មៅ) EDCF)
- បានចុះបេសកកម្មទៅសាលាខេត្តកំពង់ចាម សាលាខេត្តក្រចេះ និងសាលាខេត្តស្ទឹងត្រែង ដើម្បីបើកវគ្គបណ្តុះបណ្តាលស្តីពីយន្តការដោះស្រាយបណ្តឹងតវ៉ាគម្រោងអភិវឌ្ឍន៍ក្រុង ៤
- បានចូលរួមបេសកកម្ម ADB Review Mission ជាមួយក្រុមការងារ ADB , តំណាងក្រសួងសាធារណការ និងដឹកជញ្ជូន, PMU, និងក្រុមប្រឹក្សាបច្ចេកទេស នៃគម្រោងកែលម្អក្រុងជុំវិញបឹងទន្លេសាបជំហានទី ១ និង ទី ២
- បានចូលរួមបេសកកម្ម Loan Fact Finding និង Project Categorization សម្រាប់អនុវត្តគម្រោងផ្គត់ផ្គង់ទឹកស្អាត និងអនាម័យជនបទ ជំហានទី ៣ ដែលមានភូមិសាស្ត្រក្នុងខេត្តកំពង់ឆ្នាំង, ពោធិ៍សាត់, បាត់ដំបង, ព្រះវិហារ, កំពង់ធំ, ឧត្តរមានជ័យ, សៀមរាប, បន្ទាយមានជ័យ, កំពង់ស្ពឺ និងកំពត ជាមួយក្រសួងអភិវឌ្ឍន៍ជនបទ និងក្រុមបេសកកម្ម ADB
- បានចូលរួមពិធីបើកវគ្គបណ្តុះបណ្តាល ស្តីពីជំនាញបច្ចេកទេសលើការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ
- បានរៀបចំវគ្គបណ្តុះបណ្តាលស្តីពី ការរៀបចំរបាយការណ៍ហិរ“ញ្ញវត្ថុតាមស្តង់ដារគណនេយ្យសាធារណៈអន្តរជាតិ ផ្អែកលើមូលដ្ឋានសាច់ប្រាក់
- បានរៀបចំសិក្ខាសាលាស្តីពី វិធីសាស្ត្របង្រៀន និង ពិគ្រោះយោបល់សំដៅកែលម្អកម្មវិធីសិក្សានិងឯកសារបង្រៀន“ សម្រាប់វគ្គបណ្តុះបណ្តាលស្តីពី ជំនាញបច្ចេកទេសលើការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ឆ្នាំ ២០១៩

- បានរៀបចំវគ្គបណ្តុះបណ្តាលស្តីពី ) ការអភិវឌ្ឍជំនាញទន់លើគន្លឹះដើម្បីភាពជោគជ័យ និង ភាពជាអ្នកដឹកនាំ"Operacy-Key to Personal Empowerment, Success and Leadership"ជូនថ្នាក់ដឹកនាំ មន្ត្រីរាជការ និងគ្រូបង្គោលនៃវិទ្យាស្ថានសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានរៀបចំវគ្គបណ្តុះបណ្តាលស្តីពី ជូនមន្ត្រីទទួលបន្ទុកការងារពាក់ព័ន្ធនឹងការវិភាគថវិកា របស់អគ្គនាយកដ្ឋានពាក់ព័ន្ធ នៃនាក់ ៤៥ កសហវ និងក្រសួងស្ថាប័នពាក់ព័ន្ធ ចំនួន
- បានរៀបចំពិធីប្រកាសបើកវគ្គបណ្តុះបណ្តាលស្តីពី "ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ " ដែលប្រព្រឹត្តទៅនៅថ្ងៃទី១០ ខែមិថុនា នៅសណ្ឋាគារភ្នំពេញ
- បានរៀបចំពិធីបើកវគ្គបណ្តុះបណ្តាលស្តីពី ជំនាញវិជ្ជាជីវៈគណនេយ្យ Diploma of Accounting នៅទីស្តីការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- ការងាររៀបចំកម្រងសម្រង់បទប្បញ្ញត្តិគតិយុត្ត របស់ក្រុមប្រឹក្សានីតិកម្ម
    - o បានរៀបចំធ្វើបច្ចុប្បន្នកម្ម និងបោះពុម្ពកម្រងសម្រង់បទប្បញ្ញត្តិគតិយុត្តពាក់ព័ន្ធសមត្ថកិច្ចរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
    - o បច្ចុប្បន្នកម្មកម្រងសម្រង់ទ្រព្យសម្បត្តិរដ្ឋនិងចំណូលមិនមែនសារពើពន្ធ (លើកទី១)÷ ផ្ទៀងផ្ទាត់បានចំនួន៣លើក នៃអត្ថបទសរុបចំនួន ៧៦ និងបញ្ចូលកំណែរួចរាល់
    - o កម្រងសម្រង់បទប្បញ្ញត្តិគតិយុត្តពាក់ព័ន្ធកិច្ចដំណើរការស្ថាប័ន នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ÷ កំពុងធ្វើការផ្ទៀងផ្ទាត់លើកទី២ ទៅលើអត្ថបទដែលបានវាយចម្លងរួច បានចំនួន ៥១៤/១១២៣ ទំព័រ និងបានរៀបចំកាលប្បវត្តិរួចរាល់
    - o កម្រងសម្រង់បទប្បញ្ញត្តិគតិយុត្តពាក់ព័ន្ធលទ្ធកម្មសាធារណៈ÷ កំពុងផ្ទៀងផ្ទាត់កម្រិតជំនាញលើកទី៣ បានចំនួន ១២៨៨/១៨៤៦ ទំព័រ
- ផ្តល់មតិប្រឹក្សាច្បាប់ ចំនួន២៤
    - o មតិប្រឹក្សាច្បាប់ ក្រុមហ៊ុន ខូវ៉រធើរ ស្វូជីមា អ៊ិនធើណេសិនណល អ៊ិន÷ បានបញ្ចប់
    - o សេចក្តីព្រាងអនុក្រឹត្យស្តីពីការរៀបចំនិងការប្រព្រឹត្តទៅ នៃស្ថាប័នវិជ្ជាជីវៈគណនេយ្យ
    - o សេចក្តីព្រាងប្រកាសស្តីពីការដាក់ឱ្យអនុវត្តស្តង់ដារគណនេយ្យសាធារណៈកម្ពុជាមូលដ្ឋានសាច់ប្រាក់
    - o សេចក្តីព្រាងច្បាប់ស្តីពីការបង្កើតអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ
    - o សេចក្តីព្រាងច្បាប់ស្តីពីកិច្ចការពារអ្នកប្រើប្រាស់
    - o សេចក្តីព្រាងប្រកាសស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃលេខាធិការដ្ឋានមូលនិធិសហគ្រិនភាព
    - o មតិប្រឹក្សាច្បាប់លើករណីសំណើសុំការអនុញ្ញាតទទួលមូលនិធិពី Asian Fund Institution Past Mahatos-takachanaphol Fundation (Thailand)÷ បានបញ្ចប់
    - o សេចក្តីព្រាងប្រកាសស្តីពីលក្ខខណ្ឌនិងនីតិវិធី នៃការផ្តល់អាជ្ញាបណ្ណប្រកបវិជ្ជាជីវៈគណនេយ្យនិងសវនកម្ម
    - o សេចក្តីព្រាងប្រកាសស្តីពីកាតព្វកិច្ចដាក់របាយការណ៍ហិរញ្ញវត្ថុឱ្យសវនកម្មឯករាជ្យ
    - o សេចក្តីព្រាងអនុក្រឹត្យស្តីពីការធានារ៉ាប់រង
    - o សេចក្តីព្រាងប្រកាសស្តីពីការផ្តល់អាជ្ញាបណ្ណអាជីវកម្មធានារ៉ាប់រង
    - o សេចក្តីព្រាងអនុក្រឹត្យស្តីពីវិធាននិងនីតិវិធី នៃការធ្វើអធិការកិច្ចហិរញ្ញវត្ថុ
    - o សេចក្តីព្រាងច្បាប់ស្តីពីយន្តការភាពជាដៃគូរវាងរដ្ឋនិងឯកជន

- o សេចក្តីព្រាងរបាយការណ៍ឆ្លើយតបការអនុវត្តអនុសាសន៍នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋនិងនយោបាយ
- o របាយការណ៍ស្តីពីសិទ្ធិមនុស្សនៅកម្ពុជាជូនអង្គការសហប្រជាជាតិ ដើម្បីផ្សព្វផ្សាយពីលទ្ធផលកិច្ចប្រជុំក្រុមប្រឹក្សាសិទ្ធិមនុស្សអង្គការសហប្រជាជាតិលើកទី៣២ ស្តីពីយន្តការពិនិត្យឡើងវិញជាសកលតាមកាលកំណត់ (UPR) ជុំទី៣ សម្រាប់កម្ពុជា និងអនុសាសន៍
- o សេចក្តីព្រាងអនុក្រឹត្យស្តីពីការចុះបញ្ជីបរធនបាលកិច្ច
- o បានរៀបចំមតិយោបល់ដាក់ជូនក្រុមប្រឹក្សាជាតិគណនេយ្យពាក់ព័ន្ធនឹងរបាយការណ៍ស្តីពីវេទិកាសន្ទនាអំពីការអនុវត្តច្បាប់ស្តីពីគណនេយ្យនិងសវនកម្ម និងការដាក់របាយការណ៍ហិរញ្ញវត្ថុ ឆ្នាំ២០១៨
- o មតិប្រឹក្សាច្បាប់លើអនុក្រឹត្យស្តីពីវិសោធនកម្មអនុក្រឹត្យលេខ ០៧ អនក្រ.បក ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ២០០២ ស្តីពីការបង្កើតក្រុមហ៊ុនធានារ៉ាប់រងបន្តកម្ពុជា "កម្ពុជា"
- o មតិប្រឹក្សាច្បាប់លើសេចក្តីព្រាងសារាចរណែនាំស្តីពីការកំណត់លក្ខខណ្ឌក្នុងការជម្រះចេញពីបញ្ជីសារពើភណ្ឌ ទ្រព្យសម្បត្តិរដ្ឋ នូវដី និងកន្លែងស្នាក់នៅ ដើម្បីធ្វើប្រទានកម្មជូនប្រជាពលរដ្ឋ ឬមន្ត្រីរាជការទទួលបានកម្មសិទ្ធិស្របច្បាប់
- o សេចក្តីព្រាងច្បាប់ស្តីពីការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ
- o អនុក្រឹត្យស្តីពីពិន័យអន្តរការណ៍ចំពោះអំពើល្មើសទៅនឹងច្បាប់ស្តីពីគណនេយ្យនិងសវនកម្ម÷ បានចូលរួមផ្តល់យោបល់ក្នុងកិច្ចប្រជុំផ្ទៃក្នុងថ្ងៃទី១៤ មិថុនា ២០១៩ និងបានរៀបចំរបាយការណ៍ជូនឯកឧត្តមបណ្ឌិតអនុប្រធានប្រចាំការ
- o សេចក្តីព្រាងប្រកាសស្តីពីការកំណត់ការិយបរិច្ឆេទគណនេយ្យសម្រាប់សកម្មភាពដែលមានលក្ខណៈពិសេស÷ បានចូលរួមផ្តល់យោបល់ក្នុងកិច្ចប្រជុំផ្ទៃក្នុងថ្ងៃទី១៤ មិថុនា ២០១៩

- រៀបចំនិងគ្រប់គ្រងប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាននីតិកម្ម និងប្រព័ន្ធទិន្នន័យច្បាប់
  - o បានរៀបចំរចនាឧបករណ៍នីតិសាស្ត្ររបស់ក្រុមប្រឹក្សានីតិកម្ម ដែលរួមមានកម្រងសម្រង់បទប្បញ្ញត្តិគតិយុត្តពាក់ព័ន្ធការគ្រប់គ្រងនិងការអភិវឌ្ឍធនធានមនុស្សនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ, កម្រងសម្រង់បទប្បញ្ញត្តិគតិយុត្តពាក់ព័ន្ធឧស្សាហកម្មហិរញ្ញវត្ថុ និងបច្ចុប្បន្នកម្មកម្រងសម្រង់បទប្បញ្ញត្តិគតិយុត្តពាក់ព័ន្ធពន្ធដារ
  - o បានបញ្ចូលលិខិតបទដ្ឋានគតិយុត្តត្រូវបានប្រមូលថ្មី និងគ្រប់គ្រងបន្ថែមចំនួនប្រមាណ ៣០០។
- ការងារសិក្សាស្រាវជ្រាវ
  - o សេចក្តីព្រាងច្បាប់ស្តីពីការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ÷ បានរៀបចំលិខិតស្នើសុំបំភ្លឺ ពីក្រសួង-ស្ថាប័នពាក់ព័ន្ធនៃប្រទេសអូស្ត្រាលី និងបានរៀបចំឯកសារជំនួយស្មារតីសម្រាប់ទស្សនកិច្ច

### ២.៣.២ ការងារសវនកម្មផ្ទៃក្នុង

- បានបញ្ជូនផែនការសវនកម្មផ្ទៃក្នុងប្រចាំឆ្នាំ២០១៩ និងរបាយការណ៍សវនកម្មថ្នាក់មូលដ្ឋាន ខេត្តរតនគិរី មណ្ឌលគិរី ឧត្តរមានជ័យ ស្ទឹងត្រែង ប៉ៃលិន បន្ទាយមានជ័យ សៀមរាប ព្រះវិហារ បាត់ដំបង កោះកុង ព្រះសីហនុ កែប កំពង់ធំ កំពតកំពង់ចាម ស្វាយរៀង កំពង់ឆ្នាំង ព្រៃវែង តាកែវ កំពង់ស្ពឺ កណ្តាល ពោធិ៍សាត់ ត្បូងឃ្មុំ សម្រាប់ឆ្នាំ២០១៨ និងរបាយការណ៍សវនកម្មថ្នាក់កណ្តាល អគ្គនាយកដ្ឋានរតនាគារជាតិ អគ្គនាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋ និងចំណូលមិនមែនសារពើពន្ធ អគ្គលេខាធិការដ្ឋាន អគ្គលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ អគ្គនាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ និងគ្រប់គ្រងបំណុលសម្រាប់ឆ្នាំ២០១៨ ទៅអាជ្ញាធរសវនកម្មជាតិ

- បានចុះធ្វើសវនកម្មនៅអង្គភាពថ្នាក់កណ្តាលចំនួន០៥ គឺអគ្គនាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុ អគ្គនាយកដ្ឋានហិរញ្ញវត្ថុរដ្ឋបាលថ្នាក់ក្រោមជាតិ អគ្គនាយកដ្ឋានថវិកា អគ្គនាយកដ្ឋានគោលនយោបាយ និងលេខាធិការដ្ឋានក្រុមប្រឹក្សានីតិកម្ម និងថ្នាក់មូលដ្ឋានចំនួន ០៧ គឺខេត្តបន្ទាយមានជ័យ ត្បូងឃ្មុំ រតនគិរី ព្រះសីហនុ ពោធិ៍សាត់ បាត់ដំបង និងខេត្តតាកែវ
- បានបញ្ចប់ការចុះសវនកម្មនៅរាជធានីភ្នំពេញ និងថ្នាក់កណ្តាលចំនួន០២ គឺអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា និងអគ្គនាយកដ្ឋានពន្ធដារ សម្រាប់ឆ្នាំ២០១៨ និងកំពុងរៀបចំរបាយការណ៍
- បានចុះប្រមូលស្ថិតិពីអង្គភាពពាក់ព័ន្ធទទួលបានលទ្ធផលដូចខាងក្រោម÷
    - អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា:ប្រមូលបានរបាយការណ៍បញ្ចេញ-បញ្ចូលផលិតផលតេលសិលាត្រឹមខែមេសា ឆ្នាំ២០១៩។ ចំពោះស្ថិតិយានយន្តគ្រប់ប្រភេទពុំទាន់ទទួលបានឯកសារបន្ថែមនៅឡើយ
    - អគ្គនាយកដ្ឋានពន្ធដារៈ នៅពុំទាន់ទទួលបានឯកសារនៅឡើយ
    - ក្រសួងសាធារណការនិងដឹកជញ្ជូនៈ ស្ថិតិចុះបញ្ជីយានយន្តពុំទាន់ទទួលបានឯកសារបន្ថែមនៅឡើយ
    - ក្រសួងពាណិជ្ជកម្មៈ ស្ថិតិចុះបញ្ជីខ្នាតធំនិងស្ថិតិចុះបញ្ជីខ្នាតតូចនៅពុំទាន់បានទទួលឯកសារបន្ថែមនៅឡើយ (បានរៀបចំលិខិតសម្រាប់ស្នើសុំជាថ្មីរួចរាល់ ប៉ុន្តែពុំទាន់មានការឆ្លើយតប)
    - ក្រសួងរៀបចំដែនដី នគរូបនីយកម្មនិងសំណង់ៈ
    - ស្ថិតិចុះបញ្ជីដំបូង÷ ទទួលបានខេត្តពោធិ៍សាត់ ត្រឹមខែឧសភា ឆ្នាំ២០១៩
    - ស្ថិតិការផ្លាស់ប្តូរកម្មសិទ្ធិក្រោយពេលផ្ទេរកម្មសិទ្ធិ÷ ទទួលបានខេត្តព្រះសីហនុ ត្រឹមខែមិថុនា ឆ្នាំ២០១៩
    - ក្រុមហ៊ុនស្ងួតគីម៉ិចៈ ប្រមូលបានស្ថិតិតម្លៃប្រេងអន្តរជាតិត្រឹមខែឧសភា ឆ្នាំ២០១៩
    - កំពង់ផែស្វយ័តក្រុងព្រះសីហនុៈ ស្ថិតិកុងទីន័រ និងកប៉ាល់ ទទួលបានត្រឹមខែមេសា ឆ្នាំ២០១៩
    - កំពង់ផែស្វយ័តភ្នំពេញៈ ប្រមូលបានស្ថិតិទំងន់កុងទីន័រ ប្រចាំខែឧសភា ឆ្នាំ២០១៩
    - ស្ថិតិទម្ងន់ដឹកតាមរថយន្តនៅតាមបណ្តាស្ថានីយជញ្ជឹងអចល័តៈ ពុំទាន់ទទួលបានឯកសារបន្ថែមនៅឡើយ
    - ស្ថិតិ និងឯកសារពាក់ព័ន្ធការបង់ពន្ធប្រថាប់ត្រាៈ ស្នើសុំពីសាលាខណ្ឌ និងសង្កាត់នៅពេលចុះបេសកកម្ម
    - ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជាៈ ត្រៀមធ្វើការសិក្សាកំណត់ ទិន្នន័យត្រូវប្រមូលបន្ថែម។

**២.៣.៣. ការងារអធិការកិច្ច**

- បានរៀបចំរបាយការណ៍លទ្ធផលការងារអធិការកិច្ចហិរញ្ញវត្ថុប្រចាំឆ្នាំ២០១៨ គោរពរាយការណ៍ជូន ឯកឧត្តម អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានរៀបចំរបាយការណ៍លទ្ធផលការងារអធិការកិច្ចហិរញ្ញវត្ថុជំហានទី១ ឆ្នាំ២០១៩ គោរពរាយការណ៍ជូនថ្នាក់ដឹកនាំក្រសួង
- បានចេញលិខិតចាត់វិធានការសមស្រប និងកែលម្អកំហុសឆ្គងលើការអនុវត្តនីតិវិធីហិរញ្ញវត្ថុ ក្នុងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងទ្រព្យសម្បត្តិរដ្ឋ នៅរដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល និងរដ្ឋបាល ក្រុង ស្រុក សម្រាប់ការចុះអធិការកិច្ចហិរញ្ញវត្ថុក្នុងការិយបរិច្ឆេទ២០១៧
- បានរៀបចំ និងពិនិត្យលើសំណើចាត់វិធានការនៅតាមបណ្តាក្រសួង មន្ទីរជំនាញរាជធានី ខេត្តលើកទី១ ចំនួន ៨ អង្គភាពរួមមាន÷ ក្រសួងបរិស្ថាន ខេត្តក្រចេះ ស្ទឹងត្រែង កែប និងខេត្តព្រះសីហនុ

- បានបញ្ចប់ការធ្វើអធិការកិច្ចហិរញ្ញវត្ថុលើការគ្រប់គ្រងចំណូលចំណាយថវិការដ្ឋ ថវិកាបើក-ផ្តល់ពីក្រសួងសាមី ការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ ការគ្រប់គ្រងបំណុល ការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ និងកាតព្វកិច្ចត្រូវបង់ចំណូលចូលថវិការដ្ឋ ក្នុងការិយបរិច្ឆេទ ២០១៧ នៅក្រសួងអប់រំ យុវជន និងកីឡា ក្រសួងរៀបចំដែនដី នគរូបនីយកម្មនិងសំណង់ មន្ទីរពេទ្យព្រះកុសុមៈ ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បានបញ្ចប់ការធ្វើអធិការកិច្ចហិរញ្ញវត្ថុលើការគ្រប់គ្រងចំណូលចំណាយថវិការដ្ឋ ថវិកាបើក-ផ្តល់ពីក្រសួងសាមី ការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ ការគ្រប់គ្រងបំណុល ការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ និងកាតព្វកិច្ចត្រូវបង់ចំណូលចូលថវិការដ្ឋ ក្នុងការិយបរិច្ឆេទ ២០១៧ នៅក្រុមហ៊ុនកម្ពុជាអង្គរអ៊ែរ )Cambodia Angkor Air) ក្រសួងកិច្ចការនារី រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ និងក្រុមហ៊ុនហ្វ្រីនត្រេដ
- បានបញ្ចប់ការធ្វើអធិការកិច្ចហិរញ្ញវត្ថុលើការគ្រប់គ្រងចំណូលចំណាយថវិការដ្ឋ ថវិកាបើក-ផ្តល់ពីក្រសួងសាមី ការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ ការគ្រប់គ្រងបំណុល ការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ និងកាតព្វកិច្ចត្រូវបង់ចំណូលចូលថវិការដ្ឋ ក្នុងការិយបរិច្ឆេទ ២០១៨ នៅមន្ទីរសុខាភិបាល មន្ទីរពេទ្យបង្អែក/ទីភ្នាក់ងារ ប្រតិបត្តិការពិសេសស្រុកប្រតិបត្តិ/មជ្ឈមណ្ឌលបណ្តុះ/មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ មន្ទីរ ពាណិជ្ជកម្ម មន្ទីរការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ បណ្តាលវិជ្ជាជីវៈ មន្ទីរទេសចរណ៍ មន្ទីរវប្បធម៌និងវិចិត្រសិល្បៈ មន្ទីរបរិស្ថាន និងមន្ទីរធនធានទឹកនិងឧតុនិយម នៅខេត្តក្រចេះ ខេត្តព្រះសីហនុ ខេត្តព្រៃវែង ខេត្តកោះកុង ខេត្តមណ្ឌលគិរី ខេត្តកំពង់ធំ ខេត្តកំពង់ឆ្នាំង ខេត្តបាត់ដំបង រាជធានីភ្នំពេញ ខេត្តស្វាយរៀង ខេត្តប៉ៃលិន ខេត្តកែប ស្ទឹងត្រែង ខេត្តកំពត ខេត្តកំពង់ស្ពឺ ខេត្តរតនគិរី ខេត្តកណ្តាល ខេត្តតាកែវ សៀមរាប ខេត្តកំពង់ចាម ខេត្តបន្ទាយមានជ័យ ខេត្តឧត្តរមានជ័យ ខេត្តពោធិ៍សាត់ ខេត្តព្រះវិហារ និងខេត្តត្បូងឃ្មុំ
- បាននឹងកំពុងធ្វើអធិការកិច្ចហិរញ្ញវត្ថុលើការគ្រប់គ្រងចំណូលចំណាយថវិការដ្ឋ ថវិកាបើក-ផ្តល់ពីក្រសួងសាមី ការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ ការគ្រប់គ្រងបំណុល ការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ និងកាតព្វកិច្ចត្រូវបង់ចំណូលចូលថវិការដ្ឋ ក្នុងការិយបរិច្ឆេទ២០១៨ នៅក្រុមហ៊ុន Cintry(Cambodia) Ltd.
- បាននឹងកំពុងធ្វើអធិការកិច្ចហិរញ្ញវត្ថុលើការគ្រប់គ្រងចំណូល-ចំណាយថវិការដ្ឋ ថវិកាបើកផ្តល់ពីក្រសួងសាមី ការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ ការគ្រប់គ្រងបំណុល ការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ និងកាតព្វកិច្ចត្រូវបង់ចំណូលចូលថវិការដ្ឋ ក្នុងការិយបរិច្ឆេទ ២០១៨ នៅមន្ទីរសាធារណការនិងដឹកជញ្ជូន, មន្ទីរអប់រំ យុវជន និងកីឡា/ការិ.អ.យ.ក ក្រុង-ស្រុក, មន្ទីរអភិវឌ្ឍន៍ជនបទ/មជ្ឈមណ្ឌលបណ្តុះបណ្តាល ជំនាញមូលដ្ឋាន, មន្ទីរព័ត៌មាន, មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា, មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី, មន្ទីរកិច្ចការនារី/មជ្ឈមណ្ឌលអភិវឌ្ឍន៍ស្ត្រី, មន្ទីររ៉ែនិងថាមពល និងមន្ទីរឧស្សាហកម្ម និងសិប្បកម្ម នៅខេត្តកែប ខេត្តស្វាយរៀង ខេត្តក្រចេះ ខេត្តព្រះសីហនុ ខេត្តកំពត ខេត្តមណ្ឌលគិរី ខេត្តរតនគិរី ខេត្តតាកែវ ខេត្តកណ្តាល ខេត្តសៀមរាប ខេត្តបាត់ដំបង ខេត្តពោធិ៍សាត់ និងខេត្តកំពង់ធំ។

## ៣.ការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ

ដោយគ្រប់អង្គភាពទាំងអស់នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ មានតួនាទីចូលរួម អនុវត្ត លើកកម្ពស់ ក្នុងការងារកែទម្រង់ហិរញ្ញវត្ថុសាធារណៈគ្រប់ដំណាក់កាល ដើម្បីឱ្យការងារគ្រប់គ្រងសេដ្ឋកិច្ច ហិរញ្ញវត្ថុសាធារណៈ ក្នុងក្រសួង ក៏ដូចជាគ្រប់ក្រសួងស្ថាប័ន កាន់តែមានប្រសិទ្ធភាព ស័ក្តិសិទ្ធិភាព ដូចនេះ ផ្នែកទី៣ នេះ ត្រូវបានអនុវត្ត និងទទួលខុសត្រូវ ពីគ្រប់អង្គភាពទាំងអស់នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។ជាលទ្ធផល អគ្គនាយកដ្ឋាន បានអនុវត្តនិងទទួលបានវឌ្ឍនភាពគួរឱ្យកត់សម្គាល់ដូចខាងក្រោម÷




កិច្ចប្រជុំត្រួតពិនិត្យប្រចាំឆ្នាំ២០១៨ កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ នៅថ្ងៃទី២៩ ខែឧសភា ឆ្នាំ២០១៩

- បានរៀបចំកិច្ចប្រជុំស្តីពីការរៀបចំរបាយការណ៍សមិទ្ធកម្មនៃការអនុវត្តផែនការសកម្មភាពនៃត្រីមាសទី៤ និងប្រចាំឆ្នាំ២០១៨នៃការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ
- បានរៀបចំកិច្ចប្រជុំផ្សព្វផ្សាយអំពីថវិកាឆ្នាំ២០១៩ និងបញ្ជ្រាបការយល់ដឹងអំពីគោលការណ៍ណែនាំស្តីពី ការគ្រប់គ្រងហិរញ្ញវត្ថុ និងនីតិវិធីលទ្ធកម្មក្រោមកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដល់អង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានរៀបចំកិច្ចប្រជុំគណៈកម្មាធិការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ នៅថ្ងៃទី២១ ខែកុម្ភៈ ២០១៩
- បានរៀបចំកិច្ចប្រជុំពិភាក្សាលើសេចក្តីព្រាង" ផែនការសកម្មភាពសម្រាប់អនុវត្តយុទ្ធសាស្ត្រនៃការកែទម្រង់ ប្រព័ន្ធថវិកាឆ្នាំ ២០១៨-២០២៥
- បានរៀបចំកិច្ចប្រជុំត្រួតពិនិត្យប្រចាំឆ្នាំ២០១៨ នៃការអនុវត្តកម្មវិធីកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុ សាធារណៈដំណាក់កាលទី៣
- បានរៀបចំកម្មវិធីផ្សព្វផ្សាយស្តីពីកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ នៃរាជរដ្ឋាភិបាល កម្ពុជា នៅខេត្តត្បូងឃ្មុំ នៅថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០១៩
- បានរៀបចំប្រជុំក្រុមការងារបច្ចេកទេស NRMIS ជាមួយធនាគារពាក់ព័ន្ធ ដើម្បីសិក្សាស្វែងយល់អំពីនីតិវិធីទូទាត់តាមប្រព័ន្ធ e-Payment
- បានចូលរួមប្រជុំពិនិត្យ និងពិភាក្សាផ្តល់យោបល់លើសេចក្តីព្រាងប្រកាស ស្តីពីការកំណត់លក្ខណៈវិនិច្ឆ័យនៃអង្គភាពប្រើប្រាស់ព្រាងប្រកាសស្តីពីវិធាន និងនិតិវិធីលម្អិតនៃការជម្រះបញ្ជីទ្រព្យសម្បត្តិរដ្ឋចេញពីបញ្ជីសារពើភណ្ឌ និងនីតិវិធី លម្អិតនៃការរៀបចំ និងកត់ត្រាទ្រព្យសម្បត្តិរដ្ឋក្នុងបញ្ជីសារពើភណ្ឌ (ក្នុងសៀវភៅឆ្នាំគោល និងតារាងប្រៀបធៀប កើនឡើង និងថយចុះ) ជាលើកទី២
- បានចុះបេសកកម្មជាមួយក្រុមការងារកែទម្រង់ គ.ស.រ ទៅកាន់អាជ្ញាធរព្រះវិហារ និងអាជ្ញាធរជាតិអប្សរា ដើម្បីពិនិត្យការងារកំណត់ទុនគ្រាដំបូង និងការអនុវត្តថវិកា បន្តចូលរួមប្រជុំក្នុងក្របខណ្ឌក្រុមការងារបច្ចេកទេសកែទម្រង់គ្រឹះស្ថានសាធារណៈរដ្ឋបាល ដើម្បីពិនិត្យនិងវាយតម្លៃវឌ្ឍនភាពនិងការអនុវត្តថវិការបស់គ្រឹះស្ថានសាធារណៈរដ្ឋបាល នៅក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

- បានចូលរួមប្រជុំពិភាក្សាអំពីតម្រូវការនៃការកត់ត្រាចូលក្នុងប្រព័ន្ធ FMIS លើមុខទិនិញដែលត្រូវធ្វើលទ្ធកម្មសាធារណៈ ដោយផ្តើមចេញពីសំណើសុំធានាចំណាយរហូតដល់ការទូទាត់ និងបញ្ហាប្រឈមនៅក្នុងប្រព័ន្ធ FMIS
- បានទទួលជួបស្វាគមន៍ និងផ្តល់កិច្ចសហការជាមួយជំនាញការរបស់មូលនិធិរូបិយវត្ថុអន្តរជាតិ (IMF) ដោយបន្តពិភាក្សាផ្តោតសំខាន់ទៅលើការអនុវត្តគម្រោង FMIS ជំហានទី២ ក្នុងក្របខណ្ឌកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈដល់កម្ពុជា
- បានជួបប្រជុំជាមួយតំណាងប្រតិភូសហភាពអឺរ៉ុបប្រចាំកម្ពុជា ដើម្បីពិភាក្សា និងធ្វើការវាយតម្លៃនៃការអនុវត្តគោលដៅសូចនាករសមិទ្ធកម្មឆ្នាំ២០១៨ ក្រោមកិច្ចព្រមព្រៀងហិរញ្ញប្បទានឥតសំណងរវាងរាជរដ្ឋាភិបាលកម្ពុជា និងសហភាពអឺរ៉ុបចុះថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១៦ និងពិនិត្យវឌ្ឍនភាពនៃការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈជារួម
- បានទទួលជួបស្វាគមន៍ និងផ្តល់កិច្ចសហការជាមួយលោកទីប្រឹក្សា Mark Silins ដែលជាជំនាញការរបស់មូលនិធិរូបិយវត្ថុអន្តរជាតិ (IMF) ដោយពិភាក្សាផ្តោតសំខាន់ទៅលើការរៀបចំរបាយការណ៍ IPSAS ការបិទបញ្ជីគណនេយ្យ និងលំហូរការងារប្រចាំថ្ងៃ
- បានរៀបចំកិច្ចប្រជុំជាមួយអ្នកតំណាងធនាគារពិភពលោក អំពីបេសកកម្មនានាក្នុងការគាំទ្របច្ចេកទេសផ្នែកហិរញ្ញវត្ថុកម្ពុជា ក្នុងគោលបំណងគាំទ្រធនាគារជាតិនៃកម្ពុជា អភិវឌ្ឍទៅលើប្រព័ន្ធបង់ប្រាក់ជាតិនៅក្នុងប្រទេស
- បានរៀបចំប្រជុំបច្ចេកទេសស្តីអំពីការរៀបចំ Masterfile សម្រាប់របាយការណ៍ស្តង់ដារសាធារណៈ នៅក្នុងប្រព័ន្ធ FMIS
- ក្រុមការងារបច្ចេកទេសទទួលបន្ទុកបង្កើតប្រព័ន្ធគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ (ក.ម.ព) បានរៀបចំកិច្ចប្រជុំពិភាក្សាអំពីដំណើរការរៀបចំបង់ចំណូលតាមរយៈ E-payment នៅក្នុងប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ (NRMIS)
- បានចូលរួមប្រជុំពិភាក្សាការងារអនុវត្តប្រព័ន្ធ FMIS អំពីការកំណត់លេខកូដចំណាត់ថ្នាក់មូលនិធិនៃមាតិកាថវិកាក្នុងប្រព័ន្ធ FMIS និងបញ្ហាប្រឈមពាក់ព័ន្ធនឹងករណីញែកថវិកាឧបត្ថម្ភធនប្រភេទអតិរេកសម្រាប់រដ្ឋបាលរាជធានី ខេត្ត
- បានប្រជុំពិភាក្សាលើតម្រូវការលម្អិតក្នុងការធ្វើសន្ទានកម្មរវាងប្រព័ន្ធ FMIS ជាមួយនឹងប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ
- បានប្រជុំពិភាក្សាអំពីការរៀបចំធ្វើសិក្ខាសាលាផ្សព្វផ្សាយ និងវគ្គបណ្តុះបណ្តាលស្តីពីប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ (NRMIS) ជូនមន្ទីរជំនាញ សម្រាប់ជំហានទី៣
- ផ្សព្វផ្សាយឯកសារយុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធថវិការដ្ឋបាលថ្នាក់ក្រោមជាតិឆ្នាំ២០១៩ ត្រូវបានរៀបចំរួច ២០២៥- នាក់ ៤០០ ដោយមានអ្នកចូលរួមពីរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ សរុបចំនួន
- យុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធថវិការដ្ឋបាលថ្នាក់ក្រោមជាតិឆ្នាំ២០១៩ - ២០២៥÷ បាននិងកំពុងសិក្សាក្របខ័ណ្ឌគតិយុត្តដើម្បីគាំទ្រដល់សេចក្តីព្រាងយុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធលទ្ធកម្មសាធារណៈ
- យុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធលទ្ធកម្មសាធារណៈ២០១៩ - ២០២៥ ÷ បាននិងកំពុងសិក្សាក្របខ័ណ្ឌគតិយុត្តដើម្បីគាំទ្រដល់សេចក្តីព្រាងយុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធលទ្ធកម្មសាធារណៈ
- ឯកសារចក្ខុវិស័យនិងយុទ្ធសាស្ត្រ នៃមុខងារនីតិកម្មដើម្បីគាំទ្រការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ÷ កែសម្រួលខ្លឹមសារនិងឧបសម្ព័ន្ធ
- បន្តចុះបំពេញបេសកកម្មនៅខេត្តរតនគិរី ដើម្បីចូលរួមសិក្ខាសាលាស្តីពី វិធីសាស្ត្របង្រៀន និងពិគ្រោះយោបល់សំដៅកែលម្អកម្មវិធីសិក្សា និងបង្រៀនសម្រាប់វគ្គបណ្តុះបណ្តាលជំនាញបច្ចេកទេសលើការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ឆ្នាំ២០១៩

- បាននិងកំពុងរៀបចំផែនការសកម្មភាពសម្រាប់អនុវត្តឯកសារយុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធលទ្ធកម្មសាធារណៈ ២០១៩-២០២៥
- បានចងក្រងសៀវភៅថវិកាតាមចំណាត់ថ្នាក់សេដ្ឋកិច្ច សម្រាប់ការគ្រប់គ្រងឆ្នាំ ២០១៩ និងបានបញ្ចូលក្នុងប្រព័ន្ធ FMIS
- បានចូលរួមកិច្ចប្រជុំពិភាក្សាលើ ផែនការសកម្មភាព ឆ្នាំ២០១៩ - ២០២០ (GDAP 3) របស់អគ្គនាយកដ្ឋានក្រោមឱវាទក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុនៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ នៅទីស្តីការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានចូលរួមប្រជុំពិភាក្សាលើការពិនិត្យឡើងវិញនៃសេចក្តីណែនាំស្តីពីនីតិវិធីនៃការកត់ត្រាលើសន្លឹកអាណត្តិបើកប្រាក់និង នីតិវិធីនៃការកត់ត្រាក្នុងប្រព័ន្ធFMIS សម្រាប់ឆ្នាំ ២០១៩
- បានរៀបចំរបាយការណ៍សមិទ្ធកម្មនៃការអនុវត្តផែនការសកម្មភាពគម្រោង FMIS ប្រចាំត្រីមាសទី ៤ ឆ្នាំ ២០១៨ និងរៀបចំផែនការសកម្មភាពសម្រាប់គម្រោង FMIS ជំហានទី ២ ឆ្នាំ ២០១៩។
- បានរៀបចំកិច្ចប្រជុំពិភាក្សាពាក់ព័ន្ធនឹងការរៀបចំ និង ការអនុវត្តចំណាត់ថ្នាក់មូលនិធិ ( Fund Classification) នៃមាតិកាថវិកានៅក្នុងប្រព័ន្ធ FMIS នៅទីស្តីការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានរៀបចំកិច្ចប្រជុំក្រុមការងារបច្ចេកទេសកែទម្រង់គ្រឹះស្ថានសាធារណៈរដ្ឋបាល នៅទីស្តីការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានចូលរួមកិច្ចប្រជុំគណៈកម្មការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ នៅទីស្តីការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានចូលរួមក្នុងកិច្ចប្រជុំផ្សព្វផ្សាយអំពីថវិកាឆ្នាំ ២០១៩ និងបញ្ជ្រាបការយល់ដឹងអំពីគោលការណ៍ណែនាំស្តីពីការគ្រប់គ្រងហិរញ្ញវត្ថុ (FMM និងនីតិវិធីលទ្ធកម្ម) ក្រោមកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដល់អង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ នៅសណ្ឋាគារសាន់វ៉េ រាជធានីភ្នំពេញ
- បានចូលរួមកិច្ចប្រជុំត្រួតពិនិត្យតួលេខចំណូល និងចំណាយឆ្នាំ ២០១៨ សម្រាប់រៀបចំរបាយការណ៍វឌ្ឍនភាពនៃការអនុ-វត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ នៅទីស្តីការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានចូលរួមកិច្ចប្រជុំត្រួតពិនិត្យតួរលេខចំណូល និងចំណាយឆ្នាំ២០១៨ សម្រាប់រៀបចំរបាយការណ៍វឌ្ឍនភាពនៃការអនុ-វត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ នៅទីស្តីការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានប្រជុំជាមួយលោកទីប្រឹក្សា Mark Silins ដែលជាជំនាញការរបស់មូលនិធិរូបិយវត្ថុអន្តរជាតិ )IMF) ពាក់ព័ន្ធនឹងការអនុវត្តគម្រោង FMIS ជំហានទី២ នៅទីស្តីការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានរៀបចំកម្មវិធី ប្រកាសដាក់ឱ្យប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រង ហិរញ្ញវត្ថុសាធារណៈFMIS ជាផ្លូវការ នៅក្រសួង និង ប្រកាសបន្តអនុវត្តគម្រោង ២៥ ខេត្តទាំង-និង មន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រាជធានី ១០ ស្ថាប័នចំនួន-FMIS ទៅកាន់ក្រសួង១៧ ស្ថាប័នចំនួន- សម្រាប់ឆ្នាំ ២០១៩”
- បានរៀបចំប្រជុំពិភាក្សា ស្តីពីសេចក្តីព្រាង ផែនការសកម្មភាពសម្រាប់អនុវត្តយុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធថវិកាឆ្នាំ “ ២០១៨-២០២៥ នៅទីស្តីការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានរៀបចំកិច្ចប្រជុំពិនិត្យ និងពិភាក្សាលើសេចក្តីព្រាងយុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធថវិកាថ្នាក់ក្រោមជាតិឆ្នាំ២០១៩-២០២៥ និងយុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធលទ្ធកម្មសាធារណៈឆ្នាំ២០១៩ ២០២៥-នៅទីស្តីការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានផ្សព្វផ្សាយស្តីពីកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈនៃរាជរដ្ឋាភិបាលកម្ពុជានៅខេត្តមណ្ឌលគិរី
- បានរៀបចំកិច្ចប្រជុំពិភាក្សាការងារអនុវត្តប្រព័ន្ធ FMIS អំពីការកំណត់លេខកូដចំណាត់ថ្នាក់មូលនិធិនៃមាតិកាថវិកាក្នុងប្រព័ន្ធ FMIS និងបញ្ហាប្រឈមពាក់ព័ន្ធនឹងករណីញែកថវិកាឧបត្ថម្ភធនប្រភេទអតិរេកសម្រាប់រដ្ឋបាលរាជធានីខេត្ត នៅ-ទីស្តីការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

- បានចូលរួមសិក្ខាសាលាផ្សព្វផ្សាយកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដំណាក់កាលទី៣នៃរដ្ឋាភិបាលរបស់អគ្គលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ នៅខេត្តមណ្ឌលគិរី
- បានចូលរួមកិច្ចប្រជុំ PEMNA Plenary Conference ស្តីពី "Budget Restructuring and Public Debt Management for National Financial Prudence Sustainability នៅខេត្ត "Quang Ninh នៃប្រទេសវៀតណាម
- បានទទួលជួបជាមួយលោកទីប្រឹក្សា Mark Silins ដែលជាជំនាញការរបស់មូលនិធិរូបិយវត្ថុអន្តរជាតិ (IMF) ពាក់ព័ន្ធនឹងការអនុវត្តគម្រោង FMIS ជំហានទី ២
- បានចូលរួមកិច្ចប្រជុំតាមដានវឌ្ឍនភាពនៃការអនុវត្តការងាររបស់អនុក្រុមការងារទាំង ៣ ចំណុះឱ្យក្រុមការងារគ្រប់គ្រងគម្រោង FMIS និងបានរៀបចំធ្វើបទបង្ហាញអំពីវឌ្ឍនភាពការងាររបស់អនុក្រុមការងារបច្ចេកទេសទទួលបន្ទុករៀបចំនិងអភិវឌ្ឍមុខងាររៀបចំផែនការថវិកា
- បានបន្តផ្សព្វផ្សាយនូវសេចក្តីណែនាំស្តីពីការកត់ត្រានូវមាតិកា ទាំង ៧ នៃចំណាត់ថ្នាក់ថវិកា ដើម្បីបន្ស៊ីគ្នារវាងការកត់ត្រាលើ សន្លឹកអាណត្តិបើកប្រាក់ និង ប្រព័ន្ធ FMIS ដោយមានការប្រជុំជាមួយអគ្គនាយកដ្ឋានពាក់ព័ន្ធនានា ដើម្បីកែសម្រួលសេចក្តីណែនាំលេខ០០៨
- បានរៀបចំបញ្ជីមាតិកាសៀវភៅណែនាំស្តីពីការបញ្ចូលប្រតិបត្តិការចំណាយក្នុងប្រព័ន្ធ FMIS ត្រូវបានរៀបចំនិងដាក់ឱ្យអនុវត្ត
- បានរៀបចំសិក្ខាសាលាស្តីពីវិធីសាស្រ្តបង្រៀន និងពិភាក្សាពិគ្រោះយោបល់សំដៅកែលម្អកម្មវិធីសិក្សានិងឯកសារមេរៀនសម្រាប់វគ្គបណ្តុះបណ្តាលស្តីពីជំនាញបច្ចេកទេសលើការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈឆ្នាំ ២០១៩
- បានពិនិត្យ និងផ្តល់យោបល់ លើសំណើសុំទូទាត់ចំណាយថវិការបស់ក្រសួង ស្ថាប័ន ចំនួន ៣៩ រួមទាំងគ្រឹះស្ថានសាធារណៈរដ្ឋបាល ឱ្យស្របតាមបរិបទ FMIS
- ទិន្នន័យធានាចំណាយ និងការស្នើសុំទូទាត់របស់ក្រសួង ស្ថាប័នទាំងអស់ត្រូវបានចុះចូលក្នុងប្រព័ន្ធ FMIS តាំងពីចំណុចចាប់ផ្តើមរហូតដល់ចំណុចចុងក្រោយ
- បានបន្តណែនាំស្តីពីការកត់ត្រានូវមាតិកាទាំង៧ នៃចំណាត់ថ្នាក់ថវិកាដើម្បីបន្ស៊ីគ្នារវាងការកត់ត្រាលើសន្លឹកអាណត្តិបើកប្រាក់ និងប្រព័ន្ធ FMIS ដោយមានការប្រជុំជាមួយអគ្គនាយកដ្ឋានពាក់ព័ន្ធនានា ដើម្បីកែសម្រួលសេចក្តីណែនាំលេខ០០៨
- បានប្រជុំពិនិត្យ និងពិភាក្សាលើ បញ្ហាប្រឈមនានាពាក់ព័ន្ធនឹងរបាយការណ៍ដែលត្រូវ ផលិតចេញពីប្រព័ន្ធ FMIS
- បន្តរៀបចំបញ្ជីមាតិកា និងចំណុចលម្អិតព្រមទាំងជ្រើសរើសនូវករណីសម្រាប់ធ្វើជាឧទាហរណ៍ក្នុងការរៀបចំសៀវភៅណែនាំស្តីពីការបញ្ចូលប្រតិបត្តិការចំណាយក្នុងប្រព័ន្ធ FMIS
- បានរៀបចំប្រជុំត្រួតពិនិត្យផ្ទៀងផ្ទាត់របាយការណ៍សមិទ្ធកម្ម នៃការអនុវត្តផែនការសកម្មភាពប្រចាំឆ្នាំ២០១៨ និងផែនការលើកទឹកចិត្តប្រចាំឆ្នាំ២០១៩ នៃការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ
- បានរៀបចំប្រជុំស្តីពីការត្រៀមលក្ខណៈដើម្បីដាក់ឱ្យអនុវត្តប្រព័ន្ធ FMIS នៅក្រសួង-ស្ថាប័ន សម្រាប់ឆ្នាំគ្រប់គ្រងហិរញ្ញវត្ថុ២០១៩
- បានរៀបចំប្រជុំត្រួតពិនិត្យតួលេខចំណូល និងចំណាយឆ្នាំ២០១៨ សម្រាប់រៀបចំរបាយការណ៍វឌ្ឍនភាពនៃការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ
- បានរៀបចំកិច្ចប្រជុំស្តីពីការត្រួតពិនិត្យរបាយការណ៍វឌ្ឍនភាពប្រចាំត្រីមាសទី៤ ឆ្នាំ២០១៨ នៃការអនុវត្តផែនការសកម្មភាពក្រោមកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ
- បានរៀបចំកិច្ចប្រជុំស្តីពីផែនការសកម្មភាពនៃការកែទម្រង់ប្រព័ន្ធថវិកា ឆ្នាំ ២០១៨ - ២០២៥
- ផ្សព្វផ្សាយកម្មវិធីស្តីពី កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈនៃរាជរដ្ឋាភិបាលកម្ពុជា នៅខេត្តត្បូងឃ្មុំ

- បានរៀបចំកិច្ចប្រជុំ “ការត្រួតពិនិត្យរបាយការណ៍សមិទ្ធកម្មប្រចាំត្រីមាសទី៤ និងប្រចាំឆ្នាំ ២០១៨ និងថវិកាឆ្នាំ ២០១៩” និងបញ្ជ្រាបការយល់ដឹងអំពីគោលការណ៍ណែនាំស្តីពីការគ្រប់គ្រងហិរញ្ញវត្ថុរបស់អគ្គលេខាធិការដ្ឋាន នៃគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ

# សេចក្តីសន្និដ្ឋាន

យោងតាមខ្លឹមសារដូចដែលបានពណ៌នាក្នុងរបាយការណ៍ ស្តីពីសកម្មភាពការងាររបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុប្រចាំឆមាសទី១ ឆ្នាំ២០១៩ នេះ ពិតជាបានឆ្លុះបញ្ចាំងឱ្យឃើញពីការបំពេញតួនាទីយ៉ាងសកម្មពីគ្រប់អង្គភាពរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ទាំងការងារប្រចាំថ្ងៃ និងការងារកែទម្រង់ហិរញ្ញវត្ថុសាធារណៈ ក្នុងនាមជាសេនាធិការរបស់រាជរដ្ឋាភិបាល លើបេសកកម្មដឹកនាំ និងគ្រប់គ្រងវិស័យសេដ្ឋកិច្ច និងហិរញ្ញវត្ថុនៅកម្ពុជា។ ទន្ទឹមគ្នានេះ របាយការណ៍នេះ ក៏បាន សបញ្ជាក់ពីបទពិសោធន៍ល្អៗ ចំណុចខ្លាំង និងចំណុចមួយចំនួនតូច ដែលនៅមានការខ្វះខាតក្នុងការអនុវត្តការងាររបស់អង្គភាពនីមួយៗ ដែលនេះអាចជាធាតុចូលដ៏មានសារៈសំខាន់សម្រាប់ជាមូលដ្ឋានធ្វើការពិនិត្យ តាមដាន វាយតម្លៃ និងកែលម្អ គុណភាពការងារឱ្យកាន់តែមានប្រសិទ្ធភាព ស័ក្តិសិទ្ធិភាព និងគុណភាព ដើម្បីជាកាតាលីករជំរុញគាំទ្រដល់កត្តាកំណត់ភាពជោគជ័យលើការអនុវត្តការរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុជាចីរកាលតរៀងទៅ។

តាមរយៈលទ្ធផលខាងលើនេះ យើងអាចវាយតម្លៃបានថា ការរៀបចំរបាយការណ៍ស្តីពីសកម្មភាពការងារក្រសួង សេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដែលបានមកពីការបូកសរុបរបាយការណ៍សកម្មភាពការងារនៃគ្រប់អង្គភាពក្រោមឱវាទក្រសួង ពិតជាមានអត្ថប្រយោជន៍ និងគុណតម្លៃខ្ពស់ ដែលយន្តការនេះប្រៀបដូចជាការត្រួតពិនិត្យតាមដានការអនុវត្តការងារដោយផ្អែកលើសមិទ្ធផលជាក់ស្តែងរបស់អង្គភាពនីមួយៗ និងថែមទាំងបានជះឥទ្ធិពលដោយផ្ទាល់ ឬដោយប្រយោលដល់ស្មារតី នៃការអនុវត្តការងាររបស់ថ្នាក់ដឹកនាំ និងបុគ្គលិកមន្ត្រីរាជការ នៃគ្រប់អង្គភាពឱ្យកាន់តែខិតខំប្តេជ្ញាចិត្តបំពេញកិច្ចការងារតាមតួនាទី និងភារកិច្ចរបស់ខ្លួនយ៉ាងខ្ជាប់ខ្ជួនថែមមួយកម្រិតទៀត ហើយវាពិតជាមានសារសំខាន់ណាស់ដែលក្រសួងត្រូវតែបន្តអនុវត្តយន្តការនេះឱ្យបានជាប់ជាប្រចាំ ព្រមទាំងជំរុញកិច្ចការនេះឱ្យកាន់តែមានគុណភាព ប្រសិទ្ធភាព និងគ្រប់ជ្រុងជ្រោយបន្ថែមទៀត។

ស្ថិតក្នុងបរិបទនេះ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ នឹងនៅតែប្រកាន់គោលជំហរខិតខំប្រឹងប្រែងប្រកបដោយផែនការ និងយន្តការច្បាស់លាស់ ក្នុងភាពជាម្ចាស់ និងការទទួលខុសត្រូវខ្ពស់ចំពោះការបំពេញមុខងារភារកិច្ចរបស់ខ្លួន ដើម្បីចូលរួមចំណែកជាមួយរាជរដ្ឋាភិបាលកម្ពុជាក្នុងការធានាចីរភាព នៃកំណើនសេដ្ឋកិច្ច និងអភិវឌ្ឍវិស័យហិរញ្ញវត្ថុនៅកម្ពុជា ឱ្យកាន់តែមានវឌ្ឍនភាពរីកចម្រើនទៅមុខជាលំដាប់។ ទន្ទឹមគ្នានេះ ដើម្បីឈានទៅរកការសម្រេចជោគជ័យស្របតាមគោលបំណងគោលនយោបាយរបស់ក្រសួង វាពិតជាចាំបាច់ណាស់ដែលទាមទារឱ្យមានការចូលរួមចំណែកពីគ្រប់អង្គភាពទាំងអស់ក្រោមឱវាទក្រសួង ព្រមទាំងបន្តខិតខំបង្កើនប្រសិទ្ធភាពការងារបន្ថែមទៀត ដោយឈរលើគោលការណ៍តម្កល់ប្រយោជន៍រួមជាធំ ដើម្បីសម្រេចបានសមិទ្ធផលតាមស្ទូចនាករដែលបានគ្រោងទុក ដែលក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បានកំណត់ទិសដៅសំខាន់ជាយុទ្ធសាស្ត្រ ក្នុងការអភិវឌ្ឍសេដ្ឋកិច្ចនិងហិរញ្ញវត្ថុជាតិ ទាំងក្នុងតួនាទីជានិម្មាបនករ និងជាប្រតិបត្តិករ ស្របតាមយុទ្ធសាស្ត្រ ចតុកោណដំណាក់កាលទី៤ របស់រាជរដ្ឋាភិបាលនីតិកាលទី៦ នៃរដ្ឋសភា ដែលទើបតែត្រូវបានដាក់ឱ្យអនុវត្តកាលពីពេលថ្មីៗកន្លងទៅនេះ។